**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# បទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២

រៀបចំឡើងដោយ៖

និស្សិតឈ្មោះ **ខិន យិនឈីវ**

**ហ៊ូ អ៊ីហាំង**

សាស្ត្រាចារ្យណែនាំ៖

លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រផ្នែក **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ក្រុមខ្ញុំបាទឈ្មោះ **ខិន យិនឈីវ** និង **ហ៊ូ អ៊ីហាំង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨ ដល់ ២០២២។

**សូមលំឱនកាយសម្តែងនូវការគោរពប្រតិបត្តិ និងកតញ្ញូតាធម៌ចំពោះ**

| | |
|---|---|
| លោកឪពុក **អ៊ិត សុខជា** | លោកឪពុក **ម៉ូ សុខហ៊ាង** |
| អ្នកម្តាយ **ស ហាន់ឈិញ** | អ្នកម្តាយ **ហ៊ី តារី** |

ដែលបានផ្តល់កំណើតដល់កូនៗ និងជាមនុស្សដែលរកអ្នកណាមកប្រៀបផ្ទឹមពុំបាន ដែលបានខិតខំពុះពាររាល់គ្រប់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ និងផ្តល់នូវដំបូន្មានល្អៗ ក៏ដូចជាជួយជំរុញលើកទឹកចិត្តកូនៗគ្រប់កាលៈទេសៈ ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់ ការអនុគ្រោះ ព្រហ្មវិហារធម៌ អប់រំកូនៗឱ្យប្រព្រឹត្តខ្លួនដើរតាមគន្លងធម៌ឱ្យក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គម ព្រមទាំងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ និងស្មារតី ជាក់ស្តែងគឺការផ្តល់នូវចំណេះដឹងចំពោះកូនៗតាមរយៈការបញ្ជូនកូនៗទៅសិក្សានៅសាលារៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះដោយភាពរលូន និងទទួលបាននូវភាពជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួល និងរៀបចំកម្មវិធីសិក្សាសម្រាប់សិស្សនិស្សិតគ្រប់ជាន់ថ្នាក់ ក្នុងការគាំទ្រនៃការសិក្សារបស់យើងខ្ញុំប្រកបដោយភាពរលូន និងភាពជឿទុកចិត្ត។ ជាពិសេសនោះគឺ សិស្សនិស្សិតទទួលបាននូវចំណេះដឹងជាច្រើនតាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ហើយក៏ជាផ្លូវមួយសម្រាប់អភិវឌ្ឍប្រទេសជាតិនាពេលអនាគតផងដែរ។

ចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងមោះមុត និងចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវចំណេះដឹងល្អៗដល់ក្រុមខ្ញុំបាទ ទាក់ទងទៅនឹងប្រធានបទស្តីពី បទល្មើសព្រហ្មទណ្ឌ និងការកែតម្រូវនូវកំហុសខុសឆ្គងទាំងឡាយណាដែលមានភាពមិនប្រក្រតី ចំពោះការសរសេរសារណារបស់ក្រុមខ្ញុំតាំងពីចាប់ផ្តើមដំបូង រហូតទទួលបាននូវសមិទ្ធផលដ៏ល្អមួយនេះ។

ជាចុងក្រោយ ក្រុមយើងខ្ញុំទាំងពីរនាក់ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ នូវគុណូបការៈរបស់អ្នកមានគុណទាំងទ្វេ និងលោកសាស្ត្រាចារ្យជាទីគោរព។ កូនសូមលើកដៃទាំងគូឡើងដើម្បីបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់នៅក្នុងលោកយើងនេះ សូមមេត្តាតាមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី ២២ អស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សម្រាប់ឆ្នាំសិក្សា ២០១៨ ដល់ ២០២២ រួចមក ដោយការខិតខំសិក្សារៀនសូត្រ និងការផ្តល់ដំបូន្មានពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យ បានធ្វើឱ្យយើងខ្ញុំទាំងពីររូប ទទួលបានឱកាស ក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទមួយស្តីអំពី **បទល្មើសព្រហ្មទណ្ឌ**។

ចំពោះការលើកយក បទល្មើសព្រហ្មទណ្ឌនេះ មកធ្វើជាប្រធានបទនៃការសរសេរសារណាបញ្ចប់ការសិក្សា គឺមិនមែនជារឿងចៃដន្យនោះទេ ដោយហេតុថាប្រធានបទនេះ គឺមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តផ្ទាល់ ដែលជាផ្នែកមួយនៃការធានាបាននូវភាពយុត្តិធម៌ ក៏ដូចជាគោរពនូវសិទ្ធិនៃការការពារខ្លួនជាដើម។

ក្រុមយើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដែលមានឱកាសក្នុងការស្រាវជ្រាវ សរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទមួយស្តីអំពី **បទល្មើសព្រហ្មទណ្ឌ** និងមានការណែនាំពីលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យមានបទពិសោធន៍ផ្ទាល់ក្នុងសង្គម និង ជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជា នីតិព្រហ្មទណ្ឌនេះតែម្តង ជាពិសេសលោកបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការចែករំលែកបទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់ក្រុមយើងខ្ញុំ។ សារណាមួយនេះស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងឡើង ក្នុងគោលបំណងទុកជាឯកសារ សម្រាប់បំពេញនូវតម្រូវការរបស់សិស្ស និស្សិតជំនាន់ក្រោយៗ អាចយកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីបង្កើននូវចំណេះដឹង ក៏ដូចជាយល់ដឹងអំពីច្បាប់ឱ្យកាន់តែទូលំទូលាយទាក់ទងទៅនឹងប្រធានបទមួយនេះ។ ជាពិសេសទៅទៀត មូលហេតុដែលក្រុមយើងខ្ញុំលើកប្រធានបទនេះមកធ្វើជាសារណាបញ្ចប់ការសិក្សា គឺដោយសារក្រុមយើងខ្ញុំបាទចង់សិក្សា ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅចំពោះរឿងក្តីព្រហ្មទណ្ឌ ជាក់ស្តែងទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌនេះតែម្តង។

ជាចុងក្រោយ ក្រុមយើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ ដែលរួមមានការលើកឡើងអំពីទ្រឹស្តីគតិយុត្ត ព្រមទាំងរួមបញ្ចូលជាមួយការអនុវត្តជាក់ស្តែងមួយចំនួនផងដែរ និងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរ សូមធ្វើការអធ្យាស្រ័យទុកជាមុនចំពោះចំណុចខ្វះខាត កំហុសខុសឆ្គង ទាំងខ្លឹមសារ ឃ្លាប្រយោគ ព្រមទាំងអក្ខរាវិរុទ្ធ ដោយអចេតនាដោយប្រការណាមួយ។ ក្រុមយើងខ្ញុំទាំងពីររូប នឹងរង់ចាំទទួលការរិះគន់ និងការកែតម្រូវ ដើម្បីស្តាបនាគ្រប់បែបយ៉ាងពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអាន និង អ្នកស្តាប់ ដើម្បីឱ្យសារណាមួយនេះកាន់តែមានគុណភាពល្អប្រសើរឡើង។

*សូមអរគុណ!*

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី ១៖ សញ្ញាណទូទៅនៃបទល្មើស

**ផ្នែកទី ១៖ និយមន័យ** ........ ៣

១. តាមអត្ថន័យទូទៅ ........ ៣

២. អត្ថន័យតាមក្រមព្រហ្មទណ្ឌ ........ ៣

៣. តាមសន្ទានុក្រមពាក្យច្បាប់ ........ ៣

**ផ្នែកទី ២៖ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃទៀត** ........ ៤

១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី ........ ៤

២. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ ........ ៥

**ផ្នែកទី ៣៖ ចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ** ........ ៨

១. ចំណាត់ថ្នាក់ផ្អែកលើទម្ងន់នៃបទល្មើសតាមការកំណត់របស់ច្បាប់ ........ ៩

១.១ លក្ខណៈវិនិច្ឆ័យនៃការបែកចែក ........ ៩

ក. បទឧក្រិដ្ឋ ........ ៩

ខ. បទមជ្ឈិម ........ ១០

គ. បទលហុ ........ ១០

១.២ ផលប្រយោជន៍នៃការបែងចែក ........ ១១

ក. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ១២

ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ........ ១២

២. ចំណាត់ថ្នាក់ផ្អែកលើប្រភេទនៃបទល្មើស ........ ១៤

២.១ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសយោធា ........ ១៤

២.២ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសគ្រឿងញៀន ........ ១៥

២.៣ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសនយោបាយ ........ ១៥

៣. ចំណាត់ថ្នាក់ដោយផ្អែកលើបែបបទប្រព្រឹត្តបទល្មើស ........ ១៦

៣.១ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទជាសត្យានុម័តនៃការប្រព្រឹត្តបទល្មើស ........ ១៦

៣.១.១ ចំណាត់ថ្នាក់ទៅតាមប្រភេទនៃអំពើជាសម្ភារៈ ........ ១៦

ក. បទល្មើសសកម្ម ........ ១៦
ខ. បទល្មើសអកម្ម ........ ១៦
៣.១.២ ចំណាត់ថ្នាក់ទៅតាមរយៈពេលប្រព្រឹត្តបទល្មើស ........ ១៧
ក. លក្ខណៈវិនិច្ឆ័យនៃការបែងចែក ........ ១៧
ក១. បទល្មើសភ្លាមៗ ........ ១៧
ក២. បទល្មើសបន្តរៀងហូរហែ ........ ១៨
ក៣. បទល្មើសអូសបន្លាយ ........ ១៩
ខ. ផលប្រយោជន៍នៃការបែងចែក ........ ១៩
ខ១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ១៩
ខ២. ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច ........ ១៩
៣.១.៣ ចំណាត់ថ្នាក់ទៅតាមចំនួននៃអំពើនៅក្នុងបទល្មើស ........ ១៩
ក. លក្ខណៈវិនិច្ឆ័យនៃការបែងចែក ........ ១៩
ក១. បទល្មើសធម្មតា ឬបទល្មើសសាមញ្ញ ........ ២០
ក២. បទល្មើសស្មុគស្មាញ ឬបទល្មើសសាំញ៉ាំ ........ ២០
ក៣. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ ........ ២០
ខ. ផលប្រយោជន៍នៃការបែងចែក ........ ២០
ខ១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ២០
ខ២. ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច ........ ២១
៣.១.៤ ចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃបទល្មើស ........ ២១
ក. បទល្មើសសម្ភារៈ ........ ២១
ខ. បទល្មើសទម្រង់ ឬ បទល្មើសរូបភាព ........ ២២
៣.១.៥ ចំណាត់ថ្នាក់ទៅតាមសភាពនៃអំពើ ........ ២២
ក. បទល្មើសជាក់ស្តែង ........ ២២
ខ. បទល្មើសមិនជាក់ស្តែង ........ ២២
៣.២ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទជាអត្តនោម័តនៃការប្រព្រឹត្តបទល្មើស ........ ២២
ក. បទល្មើសចេតនា ........ ២៣
ខ. បទល្មើសអចេតនា ........ ២៣

៤. បទល្មើសដែលគ្មានអាជ្ញាយុកាល ........................................................................................ ២៣

## ជំពូកទី ២៖ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

**ផ្នែកទី ១៖ ធាតុនីត្យានុកូល ឬធាតុច្បាប់**..............................................................................................២៤
១. អត្ថន័យនៃធាតុនីត្យានុកូល ឬធាតុច្បាប់.......................................................................................២៤
២. គោលការណ៍នីត្យានុកូលភាព.........................................................................................................២៥
២.១ នីត្យានុកូលភាពនៃបទល្មើស....................................................................................................២៥
២.២ នីត្យានុកូលភាពនៃទោស ..........................................................................................................២៥
៣. គោលបំណងនៃគោលការណ៍នីត្យានុកូលភាព...................................................................................២៥
ក. ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ.......................................................................................២៦
ខ. បង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ .......................................................................................២៧
៤. ផលវិបាកនៃគោលការណ៍នីត្យានុកូល ............................................................................................ ២៧
៤.១ ការបកស្រាយច្បាប់ ..................................................................................................................២៧
៤.២ អានុភាពនៃនីតិព្រហ្មទណ្ឌ .........................................................................................................២៨
៤.២.១ ការអនុវត្តនីតិព្រហ្មទណ្ឌក្នុងកាល ឬពេលវេលា......................................................................២៨
ក. គោលការណ៍មិនប្រតិសកម្មនៃនីតិព្រហ្មទណ្ឌ..........................................................................២៩
ខ. គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ......................................................២៩
៤.២.២ ការអនុវត្តនីតិព្រហ្មទណ្ឌក្នុងលំហ ឬដែនដី ...........................................................................៣១
ក. គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា...........................................................៣១
ខ. ស្ថានភាពទាំងប្រាំនៃបទល្មើសដែលចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា....៣២
គ. បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ......................................... ៣៣
**ផ្នែកទី ២៖ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ**.............................................................................................. ៣៥
១. អត្ថន័យនៃធាតុសត្យានុម័ត ឬធាតុសម្ភារៈ .......................................................................................៣៥
២. ទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម ឬចំណងហេតុផល..................................................................៣៦
២.១ អំពើសកម្ម..............................................................................................................................៣៦
២.២ អំពើអកម្ម.............................................................................................................................. ៣៧
**ផ្នែកទី ៣៖ ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ** ........................................................................................ ៣៧
១. អត្ថន័យនៃធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ.................................................................................. ៣៧

២. កំហុសព្រហ្មទណ្ឌ ....................................................................................................................................៣៨
២.១ កំហុសដោយចេតនា ......................................................................................................................៣៨
២.១.១ ប្រភេទនៃចេតនាប្រព្រឹត្តបទល្មើស ឬចេតនាទុច្ចរិត ...........................................................................៣៨
ក. ចេតនាទុច្ចរិតទូទៅ.....................................................................................................................៣៨
ខ. ចេតនាទុច្ចរិតពិសេស ..................................................................................................................៣៨
គ. ចេតនាទុច្ចរិតធ្ងន់ធ្ងរ.....................................................................................................................៣៨
ឃ. ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់.....................................................................................៣៩
ង. ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ...................................................................................................៣៩
២.២ កំហុសដោយអចេតនា...................................................................................................................... ៤០
ក. ការមិនប្រុងប្រយ័ត្ន........................................................................................................................ ៤០
ខ. ការខ្ជីខ្ជា ..................................................................................................................................... ៤០
គ. ការធ្វេសប្រហែស ......................................................................................................................... ៤០
ឃ. ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ.......................................................................................... ៤១
២.៣ ការវាយតម្លៃអំពីកំហុសចេតនា និងកំហុសអចេតនា........................................................................... ៤១
ក. បទឧក្រិដ្ឋ.................................................................................................................................... ៤១
ខ. បទលហុ....................................................................................................................................... ៤១
គ. បទមជ្ឈិម.................................................................................................................................... ៤១

## ជំពូកទី ៣៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

**ផ្នែកទី ១៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ**.................................................................................................... ៤៣
១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល..............................................................................................៤៣
១.១ រូបវន្តបុគ្គលជានីតិជន.......................................................................................................................៤៣
១.២ រូបវន្តបុគ្គលជាអនីតិជន..................................................................................................................... ៤៤
ក. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ទៅដល់ក្រោម ១៨ ឆ្នាំ................................................................ ៤៤
ខ. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ........................................................................................... ៤៤
២. ការទទួលខុសត្រូវរបស់នីតិបុគ្គល ........................................................................................................... ៤៥
២.១ នីតិបុគ្គលជារដ្ឋ.............................................................................................................................. ៤៥
២.២ នីតិបុគ្គលមិនមែនរដ្ឋ ....................................................................................................................... ៤៥

៣. ឋានៈបុគ្គលដែលចូលរួមនៅក្នុងការប្រព្រឹត្តបទល្មើស ... ៤៦
ក. ចារី ... ៤៦
ខ. សហចារី ... ៤៧
គ. អ្នកផ្ដើមគំនិត ... ៤៧
ឃ. អ្នកសមគំនិត ... ៤៨
៤. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស ... ៤៨
ក. ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស ... ៤៨
ខ. ដំណាក់កាលត្រៀមរៀបចំប្រព្រឹត្តបទល្មើស ... ៤៩
គ. ដំណាក់កាលនៃការចាប់ផ្ដើមប្រព្រឹត្តបទល្មើស ... ៥០
ឃ. ដំណាក់កាលនៃការសម្រេចបទល្មើស ឬមិនបានសម្រេចនូវបទល្មើស (ការប៉ុនប៉ង) ... ៥០
៥. ការប៉ុនប៉ង ... ៥១
៥.១ លក្ខខណ្ឌនៃការប៉ុនប៉ង ... ៥១
៥.២ ទណ្ឌកម្មនៃការប៉ុនប៉ង ... ៥២
**ផ្នែកទី ២៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ... ៥៣
១. មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬភាពមិនអាចទម្លាក់កំហុសបាន ... ៥៣
១.១ មូលហេតុវិបល្លាសស្មារតី ... ៥៣
១.២ មូលហេតុដោយសារអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ ... ៥៤
ក. ការបង្ខំផ្លូវកាយ ... ៥៤
ខ. ការបង្ខំផ្លូវចិត្ត ... ៥៥
១.៣ មូលហេតុទាក់ទងនឹងអនីតិភាព ... ៥៥
២. មូលហេតុស្ដីពីអំពើយុត្តិកម្ម ... ៥៥
២.១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ... ៥៦
២.២ ការការពារស្របច្បាប់ និងសច្ចធារណ៍នៃការការពារស្របច្បាប់ ... ៥៦
២.៣ ស្ថានភាពចាំបាច់ ... ៥៨
**ផ្នែកទី ៣៖ ការអនុវត្តទោស** ... ៥៨
១. ស្ថានភាពទូទៅនៃទោសព្រហ្មទណ្ឌ ... ៥៨
១.១ អត្ថន័យនៃទោសព្រហ្មទណ្ឌ ... ៥៨
១.២ គោលបំណងនៃទោសព្រហ្មទណ្ឌ ... ៥៩

ក. គោលបំណងនៃការធ្វើឱ្យរួញរា ឬគោលបំណងនៃការការពារទុកជាមុន ..................... ៥៩
ខ. គោលបំណងនៃការធ្វើសំណងជាប្រាក់ ..................... ៥៩
គ. គោលបំណងនៃការអប់រំកែប្រែ ..................... ៥៩
១.៣ ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ ..................... ៦០
ក. ចរិតលក្ខណៈនីត្យានុកូលនៃទោស ..................... ៦០
ខ. ចរិតលក្ខណៈនៃការប្រកាសទោស ..................... ៦០
១.៤ ផលវិបាកនៃទោសព្រហ្មទណ្ឌ ..................... ៦០
ក. ការឈឺចាប់ ..................... ៦០
ខ. ការបន្ទោស ..................... ៦០
២. ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល ..................... ៦១
២.១ មូលទោស ..................... ៦១
ក. មូលទោសដែលអនុវត្តចំពោះនីតិជន ..................... ៦២
ខ. មូលទោសដែលអនុវត្តចំពោះអនីតិជន ..................... ៦៣
២.២ ទោសបន្ថែម ..................... ៦៤
ក. ទោសបន្ថែមសម្រាប់អនុវត្តចំពោះនីតិជន ..................... ៦៤
ខ. ទោសបន្ថែមសម្រាប់អនុវត្តចំពោះអនីតិជន ..................... ៦៥
២.៣ ទោសជំនួស ..................... ៦៥
ក. ទោសជំនួសដែលអនុវត្តចំពោះនីតិជន ..................... ៦៦
ខ. ទោសជំនួសដែលអនុវត្តចំពោះអនីតិជន ..................... ៦៦
៣. ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល ..................... ៦៧
៣.១ ទោសពិន័យក្នុងឋានៈជាមូលទោស ..................... ៦៧
៣.២ ទោសបន្ថែម ..................... ៦៧
**សេចក្តីសន្និដ្ឋាន** ..................... ៦៩
**អនុសាសន៍** ..................... ៧១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

គ្រប់ប្រទេសទាំងអស់នៅលើសកលលោកយើងនេះ មិនថាប្រទេសនោះធំក្តី តូចក្តី ប្រកាន់នូវរបបនយោបាយសេរីក្តី សង្គមនិយមក្តី ទោះបីជាប្រទេសនោះមានការអភិវឌ្ឍជឿនលឿនយ៉ាងណាក្តី នៅតែមានអំពើដែលជាបទល្មើសកើតឡើង។ **អំពើ** គឺជាសកម្មភាពទាំងឡាយណាដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។ សកម្មភាពខ្លះរបស់មនុស្សក្នុងការប្រើប្រាស់សេរីភាពរបស់ខ្លួន ច្រើនតែហួសព្រំដែន ហើយជួនកាលសកម្មភាពនេះធ្វើឡើងដោយបំពានទាំងកំរោលទៅលើសិទ្ធិរបស់អ្នកដទៃដោយចេតនា ដែលអំពើនេះមិនត្រឹមតែធ្វើឱ្យខូចប្រយោជន៍អ្នកដទៃដែលជាជនរងគ្រោះប៉ុណ្ណោះទេ ហើយវាថែមទាំងបង្កភាពចលាចលដល់សង្គមថែមទៀតផងដូចជាអំពើលួច និងអំពើរំលោភសេពសន្ថវៈជាដើម។ល។ សកម្មភាពទាំងនេះហើយ ដែលជាហេតុធ្វើឱ្យមានទំនាស់កើតឡើងរវាងបុគ្គល និងបុគ្គល ឬរវាងបុគ្គល និងរដ្ឋ។ ហេតុដូច្នេះហើយទើបប្រទេសនីមួយៗ រមែងតែងតែមាននីតិសម្រាប់គ្រប់គ្រងសង្គមរបស់ពួកគេដើម្បីរក្សានូវសណ្តាប់ធ្នាប់ល្អ និងធ្វើឱ្យមានរបៀបរៀបរយក្នុងសង្គម ក៏ដូចជាប្រទេសកម្ពុជាយើងដែរ ដើម្បីបង្ក្រាបនូវបទល្មើសដែលបង្កឱ្យសង្គមមានភាពអសន្តិសុខ ឬធ្វើឱ្យខូចសណ្តាប់ធ្នាប់ផលប្រយោជន៍សង្គម ឬបុគ្គលឯកជន ជាពិសេសនោះគឺ នីតិព្រហ្មទណ្ឌនេះតែម្តង។ នៅពេលដែលមានបទល្មើសកើតឡើង ជនដែលប្រព្រឹត្តអំពើល្មើសដែលច្បាប់បានហាមឃាត់ មិនអាចរួចផុតពីការទទួលទោសបានឡើយ ហើយស្ថាប័នមានសមត្ថកិច្ចនឹងធ្វើចំណាត់ការទៅលើរឿងនេះតាមកិច្ចនីតិវិធីជាធរមាន។ ជាក់ស្តែងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសឱ្យនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានកំណត់អំពីអំពើដែលជាបទល្មើសជាច្រើនសម្រាប់អនុវត្តលើបុគ្គលដែលប្រព្រឹត្តអំពើល្មើសផ្ទុយទៅនឹងបញ្ញត្តច្បាប់ ហើយនឹងត្រូវផ្តន្ទាទោសជាធរមានទៅតាមអំពើដែលខ្លួនប្រព្រឹត្ត។ ក្រមព្រហ្មទណ្ឌនេះផងដែរក៏ បានកំណត់អំពីបទល្មើស និងចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់អំពីទោស ព្រមទាំងបែបបទនៃការអនុវត្តទោសថែមទៀតផង។

**នីតិព្រហ្មទណ្ឌ** គឺជានីតិមួយប្រភេទដែលប្រទេសនានាមិនអាចខ្វះបានឡើយ។ នីតិព្រហ្មទណ្ឌរួមចំណែកបង្កឱ្យមានស្ថានភាពអំណោយផលនានា ដើម្បីធានាឱ្យទំនាក់ទំនងសង្គមមានភាពរីកចម្រើន ព្រមទាំងការពាររាល់ទំនាក់ទំនងនេះឱ្យរួចផុតពីមហន្តរាយ និងភាពអនាធិបតេយ្យ ដែលបង្កឡើងដោយជនល្មើស។

ទំនាក់ទំនងដែលនីតិព្រហ្មទណ្ឌបានការពារនោះរួមមានសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់ប្រជាពលរដ្ឋ។ ហើយនីតិព្រហ្មទណ្ឌនេះ ជាផ្នែកមួយនៃនីតិនានាដែលសិក្សាអំពីការកំណត់បទល្មើស ការស្វែងរកជនល្មើស ការស្វែងរកអំពីពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនល្មើស ការចោទប្រកាន់ ការស៊ើបសួរ ការជំនុំជម្រះ ការប្រកាសទោស និងការអនុវត្តទោសជាដើម។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ យើងនេះ មានគោលបំណងដូចជា៖

- ការពារអាយុជីវិត សុខមាលភាពរបស់ប្រជាពលរដ្ឋក្នុងសង្គម

- ការពារភាពស្ថិតនៅគង់វង្សរបស់រដ្ឋអំណាច និងតំណាងអំណាចរដ្ឋ
- រក្សារបៀបរៀបរយសាធារណៈ សីលធម៌ សន្តិសុខ និងភាពសុខសាន្តក្នុងសង្គម
- ការពារទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន
- ទប់ស្កាត់ និងបញ្ឈប់ជាបន្ទាន់នូវការប្រព្រឹត្តបទល្មើសទាំងបច្ចុប្បន្ន និងអនាគត
- ប្រឆាំងរាល់បុគ្គលដែលបង្កភាពអសន្តិសុខដល់សង្គមជាតិ
- បញ្ចូលទណ្ឌិតចូលក្នុងសង្គមវិញ។

អំពើទាំងឡាយដែលបង្កជាបទល្មើស និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដែលទោសទាំងនោះត្រូវបានកំណត់តាមរយៈប្រភេទនៃបទល្មើស ដូចជា **បទឧក្រិដ្ឋ បទមជ្ឈិម** ឬ **បទលហុ**។ ដោយហេតុនេះហើយ ទើបមានចំណោទគតិយុត្តមួយចំនួនបានលើកឡើងជាចម្ងល់ថា តើមានលក្ខខណ្ឌអ្វីខ្លះ ដែលអាចកំណត់ថាអំពើមួយជាបទល្មើសបាន? តើបុគ្គលដែលប្រព្រឹត្តបទល្មើសនោះ នឹងត្រូវទទួលរងនូវទោសបែបណាខ្លះ?

យោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌបានចែងថា ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ ប៉ុន្តែ ដើម្បីកំណត់អំពើមួយថាជាបទល្មើសបាន លុះត្រាតែអំពើនោះមានធាតុផ្សំគ្រប់គ្រាន់ ដែលធាតុផ្សំទាំងនោះមានដូចជា៖

- **ធាតុនីត្យានុកូល** ឬ **ធាតុច្បាប់**
- **ធាតុសត្យានុម័ត** ឬ **ធាតុសម្ភារៈ** និង
- **ធាតុអត្តនោម័ត** (ធាតុចិត្តសាស្ត្រ)។

ដូច្នេះ ដើម្បីជាការឆ្លើយតប និងជ្រាបឱ្យកាន់តែច្បាស់ទាក់ទងទៅនឹងចំណោទទាំងឡាយខាងលើ ដែលជាបញ្ហានឹងត្រូវដោះស្រាយនោះ ប្រធានបទនៃសារណាបញ្ចប់ការសិក្សាមួយនេះ នឹងបកស្រាយនូវបញ្ហាដែលជាចម្ងល់ដោយពន្យល់យ៉ាងលំអិតពីមួយដំណាក់កាលទៅមួយដំណាក់កាលឱ្យបានស៊ីជម្រៅ។ ដើម្បីសិក្សាឱ្យកាន់តែច្បាស់ និងងាយយល់តាមរយៈការបកស្រាយប្រធានបទស្តីពី **បទល្មើសព្រហ្មទណ្ឌ** នេះ រចនាសម្ព័ន្ធនៃសារណាបញ្ចប់ការសិក្សានេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ជំពូកទី ១ ៖ សញ្ញាណទូទៅនៃបទល្មើស**

**ជំពូកទី ២ ៖ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ**

**ជំពូកទី ៣ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

# ជំពូកទី ១
# សញ្ញាណទូទៅនៃបនល្មើស

# ជំពូកទី ១
# សញ្ញាណទូទៅនៃបទល្មើស

## ផ្នែកទី ១៖ និយមន័យ

### ១. តាមអត្ថន័យទូទៅ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើប្រព្រឹត្តដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលបង្កគ្រោះថ្នាក់ដល់សង្គម ហើយត្រូវផ្តន្ទាទោសតាមការកំណត់របស់ច្បាប់ព្រហ្មទណ្ឌទុកជាមុន។ គេអាចនិយាយបានម្យ៉ាងទៀតថា ជាអំពើបំពានច្បាប់ព្រហ្មទណ្ឌ។ អំពើទាំងឡាយណាដែលប្រព្រឹត្តឡើង ហើយដែលបង្កនូវចរិតគ្រោះថ្នាក់ដល់សង្គមនោះ ជនដែលប្រព្រឹត្តអំពើនោះ នឹងត្រូវទទួលទោសចំពោះអំពើរបស់ខ្លួនតាមការកំណត់របស់ច្បាប់ជាដាច់ខាត។

### ២. អត្ថន័យតាមក្រមព្រហ្មទណ្ឌ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ដោយមូលហេតុថា អំពើនេះបង្កភាពចលាចលដល់សង្គម។ ក្នុងក្រមព្រហ្មទណ្ឌកម្ពុជារបស់យើងដែលប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ត្រង់មាត្រា ២ បានផ្តល់សញ្ញាណខ្លះនៃបទល្មើសព្រហ្មទណ្ឌថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស មានន័យថា ជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សន្តិសុខសង្គម ហេតុដូច្នេះហើយទើបច្បាប់ព្រហ្មទណ្ឌហាមឃាត់។ ការប្រព្រឹត្តអំពើដែលផ្ទុយទៅនឹងច្បាប់ហាមឃាត់នេះ បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ។

### ៣. តាមសន្ទានុក្រមពាក្យច្បាប់

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។[1]

ហេតុដូច្នេះ ដើម្បីចាត់ទុកថាអំពើមួយជាបទល្មើសបាន លុះត្រាតែអំពើនោះបានបង្ហាញនូវចរិតលក្ខណៈគ្រោះថ្នាក់ដល់សង្គមជាតិ ក៏ដូចជាបំផ្លាញនូវសណ្តាប់ធ្នាប់សាធារណៈ។ អំពើដែលជាបទល្មើសដែលច្បាប់បានហាមឃាត់នេះ ជាទូទៅ គឺជាអំពើផ្ទុយទៅនឹងសីលធម៌ ហើយប្រជាពលរដ្ឋ និងសង្គមទាំងមូល ក៏មិនឱ្យតម្លៃទៅលើអំពើទាំងនេះទៀតផង ព្រោះថាវាអាចបង្កគ្រោះថ្នាក់ដែលជាព្យសនកម្មដល់សង្គមផង និងដល់បុគ្គលឯកជនផង។ ក្រមព្រហ្មទណ្ឌបានកំណត់នូវទោសដែលត្រូវទទួលរងចំពោះបទល្មើសនីមួយៗយ៉ាងជាក់លាក់។ ប៉ុន្តែ ចំពោះអំពើទាំងឡាយណាដែលគ្មានច្បាប់ចែងទេ អំពើនោះមិនត្រូវចាត់ទុកថាជាបទល្មើសឡើយ។

[1] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី ១៦៦។

## ផ្នែកទី ២៖ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃទៀត

តាមការពិត នៅក្នុងសង្គមមនុស្សមានអំពើជាច្រើនដែលត្រូវបានចាត់ទុកថាជាអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយដែលច្បាប់ត្រូវតែចាត់វិធានការដោះស្រាយក្នុងគោលដៅដើម្បីរក្សាស្ថិរភាពនៃទំនាក់ទំនងបុគ្គល។ ក្រៅពីបទល្មើសព្រហ្មទណ្ឌដែលជាអំពើបង្កគ្រោះថ្នាក់ខ្លាំងក្លាជាងគេ គេឃើញមានអំពើល្មើសផ្នែករដ្ឋប្បវេណី និងអំពើល្មើសផ្នែកវិន័យ ដែលសុទ្ធសឹងតែជាអំពើបង្ហាញពីចរិតគ្រោះថ្នាក់ដល់សង្គមផងដែរ។

### ១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី

អំពើល្មើសផ្នែករដ្ឋប្បវេណី មានប្រភពបញ្ញត្តមកពីក្រមរដ្ឋប្បវេណី ដែលកំណត់ពីអំពើអនីត្យានុកូល ត្រង់មាត្រា ៧៤៣ កថាខណ្ឌទី១ បានចែងថា បុគ្គលដែលបំពានដោយច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា និងដោយកំហុសអចេតនាត្រូវទទួលខុសត្រូវសងនូវរាល់ការខូចខាតដែលកើតឡើងដោយសារតែអំពើនោះ រីឯបទល្មើសព្រហ្មទណ្ឌវិញ គឺត្រូវតែបានចែងនៅក្នុងច្បាប់ថាជាបទល្មើសព្រហ្មទណ្ឌ។ សម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណីវិញ ព្យសនកម្មគឺជាកត្តាដ៏ចាំបាច់បំផុត ដើម្បីពិចារណាលើការដាក់ទណ្ឌកម្មលើអ្នកដែលបានប្រព្រឹត្ត។ ផ្ទុយទៅវិញ ការបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពុំសុទ្ធតែទាមទារឱ្យមាននូវព្យសនកម្មនោះទេ ដូចជាបទល្មើសជួញដូរគ្រឿងញៀន ឬការបើកបរល្បឿនខុសច្បាប់ជាដើម។ ជាទូទៅ ការបង់សំណងជម្ងឺចិត្តជាទណ្ឌកម្មសម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណី ហើយសំណងនេះត្រូវបានទៅលើជនរងគ្រោះក្នុងការជួសជុលព្យសនកម្មដែលជននោះបានទទួលរងដោយអំពើ។ ចំណែកឯទណ្ឌកម្មព្រហ្មទណ្ឌ គឺមានគោលដៅចម្បងការពារសង្គម និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ហើយទណ្ឌកម្មដែលជាការពិន័យ គឺត្រូវបង់ចូលថវិការដ្ឋ។

អំពើមួយអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេ ដូចជាការល្មើសដោយពុំព្រមឈប់ពេលភ្លើងស្តុបក្រហម និងការជួញដូរគ្រឿងញៀនជាដើម។ ទន្ទឹមនឹងនេះ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គង ប៉ុន្តែមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ ដូចជា អំពើដែលនាំឱ្យខូចទ្រព្យសម្បត្តិអ្នកដទៃដោយអចេតនា ដែលជាហេតុនាំឱ្យមានការបាត់បង់នូវប្រយោជន៍របស់ជនណាម្នាក់។ ផ្ទុយទៅវិញ អំពើមួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង និងជាអំពើល្មើសផ្នែករដ្ឋប្បវេណីផងក៏បានដែរដូចជា អំពើរំលោភសេពសន្ថវៈ ឬអំពើហិង្សាដោយចេតនាជាដើម។ ក្នុងករណីបែបនេះ បណ្តឹងពីរអាចនឹងត្រូវបានកើតឡើងចំពោះអំពើល្មើសនេះ គឺ៖

- **បណ្តឹងអាជ្ញា** ជាបណ្តឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។[2] បណ្តឹងនេះ ត្រូវធ្វើឡើងដោយអង្គការអយ្យការ។[3]

---

[2] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ១៣១។

- **បណ្តឹងរដ្ឋប្បវេណី** គឺជាបណ្តឹងដែលមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[4] បណ្តឹងនេះ អាចធ្វើឡើងដោយគ្រប់បុគ្គលដែលប្រកាសថាខ្លួនជាជនរងគ្រោះ។[5]

## ២. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ

អំពើល្មើសផ្នែកវិន័យ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សមូហភាពនៃក្រុមសង្គមណាមួយដូចជា ពេទ្យ មេធាវី ចៅក្រម ព្រះរាជអាជ្ញា និងយោធិនជាដើម ដោយអំពើទាំងនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ជាទូទៅនោះទេ។ ជាក់ស្តែងដូចជា មាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ បានចែងថា កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឱ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ទណ្ឌកម្មខាងវិន័យ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

ការកំណត់យ៉ាងដូច្នេះពិតជាបានបង្ហាញឱ្យឃើញថា អំពើល្មើសផ្នែកវិន័យសម្រាប់វិជ្ជាជីវៈចៅក្រម ពុំត្រូវបានបញ្ជាក់ឱ្យច្បាស់ជាមុន ដូចក្នុងករណីនៃបទល្មើសព្រហ្មទណ្ឌទេ ពីព្រោះថាអំពើដែលបានបង្កឱ្យប៉ះពាល់ដល់សីលធម៌ ឬកិត្តិយស សេចក្តីថ្លៃថ្នូរចៅក្រម ជាសញ្ញាណមួយមានលក្ខណៈទូលំទូលាយណាស់។ ផ្ទុយទៅវិញ ទោះបីជាមានច្រើនយ៉ាងណាក៏ដោយ បទល្មើសព្រហ្មទណ្ឌក៏សុទ្ធសឹងតែជាអំពើដែលច្បាប់បានកំណត់ទុកយ៉ាងច្បាស់លាស់ជាមុនរួចជាស្រេចអស់ហើយ បានសេចក្តីថា អំពើណាដែលច្បាប់ពុំបានចែងទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌទេនោះ អំពើនោះពុំអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌបានឡើយ។[6]

លើសពីនេះទៅទៀត អំពើល្មើសផ្នែកវិន័យបានធ្វើឱ្យប៉ះពាល់តែផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ។ ក៏ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញ គឺជាអំពើដែលបានបង្កនូវការប៉ះពាល់ដល់សង្គមជាទូទៅ។

ការដាក់ទណ្ឌកម្មលើអំពើល្មើសខាងវិន័យ ត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ ដូចជាក្រុមប្រឹក្សាគណៈមេធាវីសម្រាប់ការដាក់វិន័យលើមេធាវី ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់ការដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញាជាដើម។ ចំណែកឯការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌវិញ ជាសមត្ថកិច្ចរបស់សាលាជម្រះក្តី

[4] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦។

[6] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣។

នៃព្រះរាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានជាលក្ខណៈធ្ងន់ធ្ងររហូតដល់ការដាក់ពន្ធនាគារអស់មួយជីវិតទៀតផង។

ជាងនេះទៅទៀត ក៏ដូចជាបំណែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសផ្នែករដ្ឋប្បវេណីដែរ ការបែងចែករវាងអំពើល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌឆ្លុះបញ្ចាំងឱ្យឃើញថា ក្នុងករណីខ្លះអំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែកវិន័យទេ ដូចជាអំពើលួចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ៣៥៣ ជាដើម។ ទន្ទឹមនឹងគ្នានេះ ពេលខ្លះអំពើមួយត្រូវចាត់ទុកជាអំពើល្មើសផ្នែកវិន័យ ក៏ប៉ុន្តែពុំត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌណាមួយឡើយ។

យ៉ាងណាមិញ អំពើដែលច្បាប់កំណត់ថាជាបទល្មើសមានច្រើន ហើយក៏មិនមែនមានតែក្រមព្រហ្មទណ្ឌទេ ដែលកំណត់អំពីបទល្មើសដែលបង្កចរិតគ្រោះថ្នាក់ដល់សង្គម។ មានច្បាប់ផ្សេងៗទៀត ក៏បានកំណត់អំពីបទល្មើសដែរ ដូចជា ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីព្រៃឈើជាដើម។ល។ ជាងនេះទៅទៀត បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិ ក៏អាចកំណត់ជាបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ផងដែរ។ ដូច្នេះ ដើម្បីដឹងអំពីបទល្មើសទាំងអស់នេះបាន លុះត្រាតែពិនិត្យឱ្យបានគ្រប់ច្បាប់ និងបទដ្ឋានគតិយុត្តទាំងអស់ក្នុងគ្រប់វិស័យដែលពាក់ព័ន្ធ ទើបអាចដឹងបាន។ ដោយហេតុនេះ ហើយយើងនឹងលើកយកក្រមព្រហ្មទណ្ឌដែលប្រកាសឱ្យនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ យកមកសិក្សាជាពិសេសចំពោះប្រធានបទមួយនេះ។

ជាទូទៅ នៅពេលដែលមានបទល្មើស ឬអំពើបំពារបំពានណាមួយកើតមានឡើង គេតែងតែឃើញមានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ ឬក៏ក្រុមគ្រួសាររបស់ជនរងគ្រោះ ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គការអយ្យការដើម្បីទាមទារយុត្តិធម៌ និងសំណងរដ្ឋប្បវេណី។ អង្គការអយ្យការ បានដើរតួនាទីយ៉ាងសំខាន់ដើម្បីពិនិត្យ និងធ្វើការថ្លឹងថ្លែងចំពោះអំពើទាំងនោះ ថាតើគួរធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ (មិនចោទប្រកាន់)។

យោងតាមមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តថា អយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ មានន័យថា ស្ថាប័នអយ្យការជាស្ថាប័នមួយដែលមានសមត្ថកិច្ចកំណត់បានថាសញ្ញាណនៃអំពើល្មើសណាមួយ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវធ្វើការចោទប្រកាន់ និងសុំឱ្យយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះធ្វើចំណាត់ការបន្ត។ នៅក្នុងក្របខណ្ឌនៃនីតិព្រហ្មទណ្ឌ មានគោលការណ៍ចំនួនពីរ សម្រាប់ធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ គឺគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

- **គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់**

ត្រូវបានយកមកប្រើប្រាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជាឆ្នាំ ១៩៩២។ នៅក្នុងគោលការណ៍នេះ ប្រសិនបើបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ព្រះរាជអាជ្ញាដាច់ខាតត្រូវតែធ្វើការចោទប្រកាន់ មិនឱ្យអំពើល្មើស

ណាមួយគេចផុតពីការផ្តន្ទាទោសពីបញ្ញត្តច្បាប់ឡើយ ហើយព្រះរាជអាជ្ញាមិនអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបានឡើយ ទោះបីជាអំពើល្មើសនោះជាអំពើតូចតាចក្តី ឬមានការប៉ះពាល់សណ្តាប់ធ្នាប់ដល់សង្គមតិចតួចក៏ដោយ ពោលគឺឱ្យតែមានអង្គហេតុដែលជាបទល្មើសព្រហ្មទណ្ឌកើតឡើង ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ទាំងអស់។ គោលការណ៍នេះមានភាពវិជ្ជមានត្រង់ថា គ្រប់អង្គហេតុក្នុងរឿងព្រហ្មទណ្ឌទាំងអស់ គឺសុទ្ធតែត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា ដែលអាចផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាជៀសវាងការសម្រេចតម្កល់រឿងទុកឥតចាត់ការដែលអាចមានភាពមិនប្រក្រតីណាមួយ។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលគ្រប់សំណុំរឿងសុទ្ធតែត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា នោះធ្វើឱ្យសំណុំរឿងព្រហ្មទណ្ឌអាចនឹងត្រូវបានកកស្ទះច្រើន ដែលធ្វើឱ្យដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌនីមួយៗ មិនអាចបញ្ចប់ដោយឆាប់រហ័សបាន។ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ត្រូវបាននិរាករណ៍ដោយវត្តមានក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដោយជំនួសមកវិញនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ សម្រាប់ដំណើរការរឿងក្តីព្រហ្មទណ្ឌ។

- **គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**

គឺជាគោលការណ៍មួយក្នុងនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញា ធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមកដើម្បីសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដែលគេអាចហៅបានថាជា ជម្រើសនៃការចោទប្រកាន់។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយ ទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ផ្សេងៗទៀតក៏ដោយ។ ជាគោលការណ៍ព្រះរាជអាជ្ញាអាចពិចារណាអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម (ការខូចខាត) របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលដែលត្រូវទទួលរង។

**ឧទាហរណ៍៖** ករណីលួចផ្លែស្វាយ ២ ទៅ ៣ ផ្លែ ដើម្បីទទួលទាន ដែលតាមរយៈវិធានព្រហ្មទណ្ឌ គឺគ្រប់ធាតុផ្សំនៃបទល្មើសដែលព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ ប៉ុន្តែតាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចពិចារណាថ្លឹងថ្លែងបានថា តើជនរងគ្រោះ និងសង្គមជាតិទាំងមូល បានទទួលរងព្យសនកម្មធ្ងន់ធ្ងរកម្រិតណា ដោយគ្រាន់តែលួចផ្លែស្វាយ ២ ឬ៣ ផ្លែ? តើការផ្តន្ទាទោសទៅលើជនល្មើស អាចផ្តល់ផលចំណេញដែរឬទេដល់សង្គមជាតិ? បើមានការចោទប្រកាន់ និងផ្តន្ទាទោសមែន តើរដ្ឋនឹងត្រូវចំណាយថវិកាប៉ុន្មានដើម្បីចិញ្ចឹមទណ្ឌិត?។ គោលការណ៍នេះផ្តល់ប្រសិទ្ធភាពគ្រប់គ្រាន់ ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ក៏ដូចជាដំណើរការក្តីដោយភាពឆាប់រហ័ស និងកាត់បន្ថយការកកស្ទះសំណុំរឿង។

ប៉ុន្តែករណីមួយចំនួន ប្រសិនបើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវបានសម្រេចដោយព្រះរាជអាជ្ញាដោយមិនបានពិចារណាថ្លឹងថ្លែងច្បាស់លាស់ទេ ក៏អាចជះនូវភាពអវិជ្ជមានផងដែរ។ ដើម្បីជៀសវាងការប្រើប្រាស់

អំណាចជ្រុលពីសំណាក់ព្រះរាជអាជ្ញាតាមរយៈការតម្កល់រឿងទុកឥតចាត់ការ ក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៤១ កថាខណ្ឌទី ៤ និងទី ៦ បានបញ្ញត្តថា ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។ ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញា ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា។

ទន្ទឹមនឹងនេះ មាត្រា ២៩ កថាខណ្ឌទី ១ បានបញ្ញត្តថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយឡើយ។

ក្រោយពីបានសិក្សាស្វែងយល់ពីអត្ថន័យនៃបទល្មើសព្រហ្មទណ្ឌ និងភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃទៀតរួចមក យើងក៏បានជួបប្រទះនូវចម្ងល់ជាច្រើនទាក់ទងទៅនឹងបទល្មើស។ ក្នុងករណីនេះ យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ បានកំណត់អំពីចំណាត់ថ្នាក់នៃបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមស្ថានទម្ងន់នៃបទល្មើសនោះ។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ទាក់ទងទៅនឹងបញ្ហាខាងលើនេះ ថាវាមានអត្ថន័យយ៉ាងដូចម្តេច និងមានលក្ខណៈបែបណានោះ យើងនឹងធ្វើការវែកញែកនូវចំណុចនីមួយៗដូចខាងក្រោមស្តីអំពីចំណាត់ថ្នាក់នៃបទល្មើស។

## ផ្នែកទី ៣៖ ចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ

ដើម្បីស្គាល់ឱ្យកាន់តែច្បាស់នូវប្រភេទនៃបទល្មើសនីមួយៗ គឺជាការចាំបាច់ណាស់ដែលត្រូវធ្វើចំណាត់ថ្នាក់នៃបទល្មើស ក្នុងគោលដៅដើម្បីជាការសម្រួលដល់ការកំណត់ និងស្គាល់នូវរបបគតិយុត្ត ក្នុងការអនុវត្តចំពោះបទល្មើសនីមួយៗ។ យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺបានធ្វើការចាត់ថ្នាក់បទល្មើសព្រហ្មទណ្ឌជា ៣ (បី) ប្រភេទ ទៅតាមទម្ងន់របស់វា។ បទល្មើសព្រហ្មទណ្ឌ ត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។[7] បើតាមបញ្ញត្តនៃក្រមព្រហ្មទណ្ឌ ជាពិសេសត្រង់មាត្រា ៤៦ ដល់មាត្រា ៤៨ គឺមានគោលការណ៍មួយដើម្បីកំណត់ថាបទល្មើសនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ គឺគេត្រូវពិនិត្យមើលទៅលើអតិបរមានៃទោស

[7] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២១

ដាក់ពន្ធនាគារដែលច្បាប់បានកំណត់សម្រាប់បទល្មើសនោះ បានន័យថា គឺត្រូវពិនិត្យទៅលើអតិបរមានៃទោសដាក់គុកដែលមានចែងនៅក្នុងមាត្រានីមួយៗជាក់ស្តែងតែម្តង។

**១. ចំណាត់ថ្នាក់ផ្អែកលើទម្ងន់នៃបទល្មើសតាមការកំណត់របស់ច្បាប់**

បទល្មើសត្រូវបែងចែកទៅតាមភាពធ្ងន់ធ្ងរនៃអំពើនីមួយៗ។ មាត្រា ២ វាក្យខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌចែងថា បទល្មើសត្រូវចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើស។

ការបែងចែកបទល្មើសជាបីប្រភេទ ដោយយោងតាមទម្ងន់នៃបទល្មើសនេះមានសារៈសំខាន់ណាស់ក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថាការបែងចែកនេះបាននាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្ត ដែលច្បាប់រមែងផ្សារភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើសយ៉ាងជាក់ច្បាស់។

**១.១ លក្ខណៈវិនិច្ឆ័យនៃការបែកចែក**

ក្រមព្រហ្មទណ្ឌដែលកំពុងអនុវត្តបច្ចុប្បន្ននេះ បានបញ្ញត្តយ៉ាងជាក់លាក់អំពីលក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រភេទនៃបទល្មើសទៅតាមទម្ងន់នៃបទល្មើសនីមួយៗ។ គួរកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌបានកំណត់យកអតិបរមានៃទោសដែលត្រូវផ្តន្ទា ពោលគឺទោសដែលច្បាប់តម្រូវឱ្យផ្តន្ទាទៅតាមប្រភេទនីមួយៗនៃបទល្មើស មកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ។ បើយើងយោងទៅតាមការបកស្រាយនៅក្នុងទូរទស្សន៍ជាតិ ដោយវាគ្មិនរបស់ក្រសួងយុត្តិធម៌ ក៏ដូចជាការបកស្រាយរបស់បណ្ឌិត សាស្ត្រាចារ្យផ្សេងៗទៀត យើងឃើញថាមានការបកស្រាយយ៉ាងសាមញ្ញដូចខាងក្រោម៖

**ក. បទឧក្រិដ្ឋ**

បទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ហើយទោសដែលត្រូវទទួលក៏ធ្ងន់ធ្ងរផងដែរ។ យោងតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ ២០០៩ ក្នុងបទឧក្រិដ្ឋត្រូវបានកំណត់ជាពីរគឺ៖

- ➢ ទោសដាក់ពន្ធនាគារអស់មួយជីវិត និង
- ➢ អតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំឡើងទៅ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

**ឧទាហរណ៍៖**

- បទរំលោភសេពសន្ថវៈ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ដូច្នេះយើងឃើញថាអតិបរមានៃទោសដាក់ពន្ធនាគារសម្រាប់បទរំលោសេពសន្ថវៈ ដែលបានកំណត់អំពីអតិបរមានៃទោសដាក់ពន្ធនាគារចំនួន ១០ (ដប់) ឆ្នាំ គឺជាបទឧក្រិដ្ឋ (មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ)។
- បទឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ)។
- បទទារុណកម្ម និងអំពើឃោឃៅ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ (មាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ)។

- បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ (មាត្រា ២៥៦ នៃក្រមព្រហ្មទណ្ឌ)។
- បទឧបឃាត សំដៅលើអំពើប្រព្រឹត្តមួយ ឬច្រើន ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ (មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ)។

**ខ. បទមជ្ឈិម**

បទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលស្ថិតនៅចន្លោះបទឧក្រិដ្ឋ និងបទលហុ ហើយកម្រិតគ្រោះថ្នាក់ដល់សង្គមនោះមិនធ្ងន់ធ្ងរពេក ក៏មិនស្រាលពេក ហើយទោសដែលត្រូវទទួលក៏មិនធ្ងន់ធ្ងរពេក ហើយក៏មិនស្រាលពេកដែរ គឺមានលក្ខណៈធួនល្មម។ នៅក្នុងមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ បទមជ្ឈិមត្រូវបានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

**ឧទាហរណ៍៖**

- បទលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ដូច្នេះអតិបរមានៃទោសដាក់ពន្ធនាគារដែលកំណត់ ៣ (បី) ឆ្នាំ គឺក្រោម ៥ (ប្រាំ) ឆ្នាំ ដូច្នេះជាបទមជ្ឈិម (មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ) ។
- បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ (មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ)។
- បទគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ (មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ)។
- បទរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ (មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ)។
- បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ (មាត្រា ៣៤៥ នៃក្រមព្រហ្មទណ្ឌ)។

**គ. បទលហុ**

បទលហុ គឺជាបទល្មើសមួយដែលជនល្មើសបានប្រព្រឹត្តអំពើដែលនាំឱ្យប៉ះពាល់ដល់សង្គមយ៉ាងតិចតួចស្តួចស្តើង ឬប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល ហើយទណ្ឌកម្មដែលត្រូវផ្តន្ទាទោសទៅលើជនល្មើសក៏ស្រាលដែរ។ បទលហុនៅក្នុងមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ គឺយើងមើលទៅលើគោលការណ៍ពីរយ៉ាង គឺ៖

- គោលការណ៍ទី ១ ត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលក្រោម ឬស្មើនឹង ៦

(ប្រាំមួយ) ថ្ងៃ និង

➢ គោលការណ៍ទី ២ មើលទៅលើបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

ដូច្នេះ យើងពិនិត្យឱ្យលម្អិតទៅឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះមានបទល្មើសដែលផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ បើទោះបីជាចំនួនប្រាក់ដែលត្រូវបានពិន័យនោះប៉ុន្មានក៏ដោយ ក៏នៅតែជាបទលហុដែរ។

**ឧទាហរណ៍៖**

- បទស្រវឹងជាក់ស្តែង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល គឺពិន័យត្រឹមតែជាប្រាក់ប៉ុណ្ណោះ (មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ)។
- បទហិង្សាស្រាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល (មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ)។
- បទបរិហារកេរ្តិ៍ជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល (មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ)។
- បទជេរប្រមាថជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល (មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ)។
- បទហៅអ្នកដទៃនៅទីសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល (មាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌ)។

**សម្គាល់៖**[8] ការមើលអំពីចំណាត់ថ្នាក់នៃបទល្មើស គឺត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារដែលចែងនៅក្នុងច្បាប់ ឬមានចែងនៅក្នុងមាត្រានីមួយៗនៃច្បាប់ជាក់ស្តែងដែលយើងឃើញតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ មិនត្រូវមើលទៅលើ អប្បបរមានៃទោសដាក់ពន្ធនាគារដែលមានចែងនៅក្នុងច្បាប់ជាក់ស្តែង ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស ករណីអនុវត្តចំពោះអនីតិជន ឬសេចក្តីសម្រេចរបស់តុលាការទេ (សាលក្រម ឬសាលដីកា)។

### ១.២ ផលប្រយោជន៍នៃការបែងចែក

ការបែងចែកបទល្មើសទាំងបីប្រភេទខាងលើនេះ មានផលប្រយោជន៍ដែលច្បាប់កំណត់យក ហើយមានផលប្រយោជន៍សំខាន់ៗដូចជា៖

[8] សាស្ត្រាចារ្យ **កៅ សីហា**, សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ, ២០១៣។

**ក. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល**

អាជ្ញាយុកាល គឺជារយៈពេលដែលមានសិទ្ធិប្ដឹង រយៈពេលដែលដើមបណ្ដឹងព្រហ្មទណ្ឌមានសិទ្ធិប្ដឹងពីជនល្មើស ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[9] ក្នុងច្បាប់ព្រហ្មទណ្ឌ គេសង្កេតឃើញមានអាជ្ញាយុកាលពីរប្រភេទគឺ អាជ្ញាយុកាលនៃបទល្មើស (អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា) និងអាជ្ញាយុកាលនៃទោស។

**ក១. អាជ្ញាយុកាលនៃបទល្មើស (អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា)**

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចនឹងធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាបានឡើយ។ ចិរវេលានៃអាជ្ញាយុកាលប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានដូចតទៅគឺះ

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម និង
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ។[10]

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើសត្រូវចាប់ផ្ដើមចាប់ពីពេលប្រព្រឹត្តបទល្មើស។

**ក២. អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ។ ក្រមព្រហ្មទណ្ឌ បានកំណត់ចិរវេលានៃអាជ្ញាយុកាលនៃទោសដូចតទៅះ

- ទោសដែលត្រូវប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ
- ទោសដែលត្រូវប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ និង
- ទោសដែលត្រូវប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ។[11]

ចិរវេលាដែលបានកំណត់ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានក្លាយជាស្ថាពរ។

**ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី**

នៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិបញ្ញត្តិខ្មែរគឺកំណត់នូវគោលការណ៍មួយចំនួនដោយផ្អែកលើប្រភេទនៃបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិម។

---

[9] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី ២៣៧។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០។

[11] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៤។

**ឧទាហរណ៍៖**

- **ក្នុងករណីជាបទឧក្រិដ្ឋ** ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះបទមជ្ឈិម ព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសក្នុងការបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬក៏ប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន កាលបើលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។ ប្រសិនបើជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់តាមមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **ក្នុងករណីជាបទឧក្រិដ្ឋ** ការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយចៅក្រមបីរូបដែលសម្រេចជាក្រុមសមូលហភាព ឬហៅថាក្រុមប្រឹក្សាជំនុំជម្រះដោយមានការចូលរួមពីសំណាក់តំណាងអយ្យការមួយរូប។ ចំពោះបទមជ្ឈិម និងបទលហុ សាលាដំបូងជំនុំជម្រះជាចៅក្រមទោល (យោងតាមមាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- **ការប៉ុនប៉ង**

តាមអត្ថន័យមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវតែមានទោស កាលបើលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រានេះ ត្រូវបានបំពេញគ្រប់គ្រាន់។ ជាក់ស្តែង ចាប់ពីមាត្រា ២៣៩ ដល់មាត្រា ២៤៥ នៃក្រមព្រហ្មទណ្ឌត្រូវបានបញ្ញត្តនៅក្រោមផ្នែកទី ១ ស្តីពីបទរំលោភសេពសន្ថវៈនៃជំពូកទី ៣ ស្តីពីការបំពានខាងផ្លូវភេទ។ នៅក្នុងបទប្បញ្ញត្តិខាងលើនេះ ពុំឃើញមានបទប្បញ្ញត្តិណាមួយដែលចែងថា ការប៉ុនប៉ងរំលោភសេពសន្ថវៈត្រូវមានទោសទេ ក៏ប៉ុន្តែនេះមិនមានន័យថា ការប៉ុនប៉ងរំលោភសេពសន្ថវៈមិនមានទោសឡើយ។ យោងតាមអត្ថន័យនៃមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងក្នុងបទរំលោភដែលជាបទឧក្រិដ្ឋ ត្រូវតែទទួលការផ្តន្ទាទោស កាលបើលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ។

ចំណែកឯការប៉ុនប៉ងក្នុងបទមជ្ឈិម ត្រូវមានទោសក្នុងករណីដែលច្បាប់បានចែងទុកជាមុនតែប៉ុណ្ណោះ។ ជាក់ស្តែងដូចជាបទប្រទូស្តកេរខ្មាស បទបង្ហាញកេរភេទ និងបទរុកគួនខាងផ្លូវភេទ ដែលមានចែងត្រង់មាត្រា ២៤៦ មាត្រា ២៤៩ និងមាត្រា ២៥០ ស្ថិតក្នុងផ្នែកទី ២ ស្តីពីការបំពានខាងផ្លូវភេទដទៃទៀត ក្នុងជំពូកទី ៣ ស្តីពីការបំពានខាងផ្លូវភេទ គឺជាបទមជ្ឈិម។ ហេតុនេះហើយទើបអ្នកនីតិបញ្ញត្តិបន្ថែមមាត្រា ២៥១ អំពីការប៉ុនប៉ងដែលបានចែងថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទមជ្ឈិមខាងលើដែរ។

រីឯការប៉ុនប៉ងក្នុងបទលហុ ពុំត្រូវទទួលការផ្តន្ទាទោសឡើយ។

**ឧទាហរណ៍៖** ឈ្មោះ **ក** បានបើកបរម៉ូតូរបស់ខ្លួនបម្រុងនឹងឆ្លងកាត់ផ្លូវ ដែលមានភ្លើងសញ្ញាពណ៌ក្រហម ដោយបម្រុងនឹងឆ្លងកាត់ផ្លូវហើយ ក៏ប៉ុន្តែឈ្មោះ **ក** បែរជាបញ្ឈប់សកម្មភាពរបស់ខ្លួនទៅវិញ ដោយសារតែបានឃើញវត្តមានរបស់សមត្ថកិច្ចនគរបាលពីចម្ងាយ ។ អំពើរបស់ឈ្មោះ **ក** គឺជាការប៉ុនប៉ងប្រព្រឹត្តបទលហុ ដែលមិនត្រូវមានទោសឡើយ ។

- **ការផ្តើមគំនិត និងការសមគំនិត**

ការផ្តើមគំនិត និងការសមគំនិតដែលបំពេញលក្ខខណ្ឌច្បាប់កំណត់ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម សុទ្ធសឹងតែមានទោសទាំងអស់ (យោងតាមមាត្រា ២៨ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ) ។ ក៏ប៉ុន្តែមាត្រា ២៨ និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ពុំបានចែងពីការផ្តើមគំនិត ឬការសមគំនិត ក្នុងបទលហុទេ គឺមានន័យថាការផ្តើមគំនិត និងការសមគំនិតក្នុងបទលហុ មិនត្រូវទទួលការផ្តន្ទាទោសឡើយ ។

**ឧទាហរណ៍៖** នៅក្នុងវិវាទរវាងឈ្មោះ **ក** និងឈ្មោះ **ខ** ក៏ស្រាប់តែ ឈ្មោះ **គ** បាននិយាយទៅកាន់ប្អូនស្រីរបស់ ខ្លួនឈ្មោះ **ក** ថាឱ្យជេរបញ្ចោរឈ្មោះ **ខ** ទៅ។ គ្រាន់តែផុតសំដីរបស់ឈ្មោះ **គ** ឈ្មោះ **ក** ក៏ចាប់ផ្តើមជេរប្រមាថឈ្មោះ **ខ** ភ្លាម។ អំពើរបស់ឈ្មោះ **គ** គឺជាការចាប់ផ្តើមគំនិតនាំឱ្យឈ្មោះ **ក** ជេរប្រមាថឈ្មោះ **ខ** ក៏ប៉ុន្តែអំពើរបស់ឈ្មោះ **គ** មិន អាចទទួលរងនូវការផ្តន្ទាទោសឡើយ ។

## ២. ចំណាត់ថ្នាក់ផ្អែកលើប្រភេទនៃបទល្មើស

ការចាត់ថ្នាក់តាមប្រភេទនៃបទល្មើសអាចធ្វើបានរវាងបទល្មើសសាមញ្ញ បទល្មើសយោធា បទល្មើសគ្រឿង ញៀន និងបទល្មើសនយោបាយ។

### ២.១ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសយោធា

បទល្មើសភាគច្រើនត្រូវបានចាត់ទុកជាបទល្មើសសាមញ្ញ ដោយហេតុថាបទល្មើសទាំងនោះ ស្ថិតក្រោម ច្បាប់ព្រហ្មទណ្ឌទូទៅ ទាំងវិធានជាគ្រឹះ (ខ្លឹមសារ ឬច្បាប់សារធាតុ) និងជាវិធានជាទម្រង់ (រូបភាព ឬច្បាប់នីតិវិធី) ។

បទល្មើសយោធា ជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធទៅនឹងវិន័យ កងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។[12] ចំណែកឯមាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរ កាល ក៏បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នានេះដែរ ដោយចែងថា បទល្មើសយោធាជាបទល្មើសដែលទាក់ទិនដល់ យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាត ទ្រព្យសម្បត្តិយោធា។

យោងតាមនិយមន័យខាងលើ បានបង្ហាញឱ្យឃើញថា មានតែយោធិនទេដែលអាចប្រព្រឹត្តបទល្មើសយោធា បាន បុគ្គលសាមញ្ញពុំអាចនឹងប្រព្រឹត្តបទល្មើសយោធាបានឡើយ។ ម៉្យាងវិញទៀត រាល់បទល្មើសទាំងឡាយ ដែល ប្រព្រឹត្តដោយយោធិនពុំសុទ្ធសឹងតែជាបទល្មើសយោធាទេ ពីព្រោះបញ្ញត្តខាងលើនេះបានកំណត់ថា អំពើល្មើសនឹង ច្បាប់សាមញ្ញប្រព្រឹត្តដោយយោធិនពុំត្រូវចាត់ចូលជាបទល្មើសយោធាឡើយ។

**ឧទាហរណ៍៖**

- យោធិន **ក** បានរត់ចោលជួរ ជាយោធិនដែលប្រព្រឹត្តបទល្មើសទៅនឹងវិន័យកងទ័ព។

[12] ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, ០៨ កុម្ភៈ ១៩៩៣, មាត្រា ៩។

- យោធិន ខ បានលួចទ្រព្យសម្បត្តិ ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិយោធា ក៏ត្រូវចាត់ទុកជាជនដែលបានប្រព្រឹត្ត បទល្មើសយោធាផងដែរ។

ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសយោធាមានសារៈប្រយោជន៍ត្រង់ថា បទល្មើសទាំងពីរមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដូចគ្នាទេ។ ចំពោះបទល្មើសយោធា តុលាការយោធាជាតុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះ រីឯបទល្មើសសាមញ្ញវិញ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីខេត្ត។

### ២.២ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសគ្រឿងញៀន

ការប្រើពាក្យថា បទល្មើសគ្រឿងញៀន មានន័យទូលំទូលាយដែលគ្របដណ្តប់លើគ្រប់បទល្មើសទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងគ្រឿងញៀន ហើយដែលមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ឧទាហរណ៍៖** បទល្មើសជួញដូរគ្រឿងញៀនខុសច្បាប់ បទល្មើសចែកចាយគ្រឿងញៀនខុសច្បាប់ បទល្មើសផ្តល់ទីតាំងដោយចេតនាឱ្យជនណាម្នាក់ប្រើប្រាស់គ្រឿងញៀនជាដើម។

ចំពោះបទល្មើសគ្រឿងញៀនដូចបានរៀបរាប់ខាងលើ ច្បាប់បានបញ្ញត្តនូវវិធានពិសេសសម្រាប់គ្រប់គ្រង និងផ្តន្ទាទោសជនដែលប្រព្រឹត្តបទល្មើសទាំងនេះ។ ម្យ៉ាងវិញទៀត ចំពោះបទល្មើសខាងលើនេះ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវចាត់គ្រូពេទ្យឱ្យមកពិនិត្យជនឃាត់ខ្លួន ២៤ (ម្ភៃបួន) ម៉ោងម្តង ចំណែកឯចំពោះបទល្មើសសាមញ្ញវិញ នីតិវិធីបែបនេះពុំឃើញមានចែងឡើយ ។

### ២.៣ ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសនយោបាយ

សញ្ញាណនៃពាក្យ បទល្មើសនយោបាយ ត្រូវបានច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងយកមកប្រើប្រាស់ផងដែរ។ បើមើលលើមាត្រា ៥៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌសំដៅលើអំពើដែលមានលក្ខណៈនយោបាយផង និងបទល្មើសនយោបាយផង ។ក៏ប៉ុន្តែ បញ្ញត្តនេះពុំបានឱ្យនិយមន័យជាក់ស្តែងស្តីពីបទល្មើសនយោបាយឡើយ ពោលគឺគ្រាន់តែបានផ្តល់ជា ឧទាហរណ៍អំពីបទល្មើសមួយចំនួនដែលមិនត្រូវបានចាត់ទុកថា ជាបទល្មើសនយោបាយតែប៉ុណ្ណោះ។

បើពិនិត្យទៅលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្តីពីបត្យាប័នចំនួនបួន ដែលព្រះរាជាណាចក្រកម្ពុជាបានព្រមព្រៀងជាមួយប្រទេសថៃ ប្រទេសចិន ប្រទេសឡាវ និងសាធារណរដ្ឋកូរ៉េវិញ ក៏ពុំឃើញមាននិយមន័យនៃបទល្មើសនយោបាយដែរ ចំពោះការធ្វើឃាត ការបំពារបំពាន លើរូបកាយរបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវីរៈជនទាំងនោះ។ យោងតាមវចនានុក្រមច្បាប់អង់គ្លេស~ខ្មែរ បោះពុម្ពផ្សាយនៅឆ្នាំ ១៩៩៧ ដោយអង្គការមូលនិធិអាស៊ី បានឱ្យនិយមន័យបទល្មើសនយោបាយថា ជាអំពើមួយដែលធ្វើឡើងក្នុងគោលបំណងនយោបាយ ឬមកពីមូលហេតុនយោបាយ។ ចំណែកឯសទ្ទានុក្រមច្បាប់បារាំង~ខ្មែរវិញ បានឱ្យនិយមន័យបទល្មើសនយោបាយតាមទស្សនៈសត្យានុម័តថា បទល្មើសនយោបាយសំដៅលើរាល់អំពើប្រព្រឹត្តទាំងឡាយណាដែលប៉ះពាល់ដោយផ្ទាល់ដល់ផលប្រយោជន៍ ឬបុព្វសិទ្ធិដែលមានលក្ខណៈនយោបាយ ដូចជាការប៉ះពាល់ដល់អត្ថិភាព ឬ ដល់ស្ថាប័នរដ្ឋ។ និយាយម្យ៉ាងទៀតគឺសំដៅលើការប៉ះពាល់ដល់តម្លៃសង្គម ដែលច្បាប់ព្រហ្មទណ្ឌកំណត់ថាមានលក្ខណៈនយោបាយ ។

**ឧទាហរណ៍៖** ការប៉ះពាល់ដល់ដំណើរការនៃអំណាចរដ្ឋធម្មនុញ្ញ។ តាមទស្សនៈអត្តនោម័ត បទល្មើសមួយគឺជាបទល្មើសនយោបាយ កាលណាមូលហេតុដែលនាំឱ្យកើតមាននូវបទល្មើសនោះ បានគំរាមកំហែងដល់ផលប្រយោជន៍ ឬបុព្វសិទ្ធិដែលមានលក្ខណៈនយោបាយ។ ក្នុងន័យនេះត្រូវចាត់ទុកថា ជាបទល្មើសនយោបាយ ចំពោះការធ្វើរដ្ឋប្រហារផ្តួលរំលំរបបនយោបាយចាស់ ការបរិហារពីការដឹកនាំរបស់អ្នកកាន់អំណាច។ល។

និយាយជារួម បទល្មើសនយោបាយ គឺជាសញ្ញាណមួយដែលមានលក្ខណៈមិនសូវច្បាស់លាស់ ហើយយុត្តិសាស្ត្ររបស់តុលាការកម្ពុជា នឹងធ្វើការកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃបទល្មើសនយោបាយទៅតាមករណីនីមួយៗនៅពេលក្រោយទៀត ។

### ៣. ចំណាត់ថ្នាក់ដោយផ្អែកលើបែបបទប្រព្រឹត្តបទល្មើស

បទល្មើសអាចត្រូវបានធ្វើការបែងចែក ដោយយោងទៅតាមទិដ្ឋភាពជាសត្យានុម័ត និងទិដ្ឋភាពជាអត្តនោម័តនៃបែបបទប្រព្រឹត្តបទល្មើស។

### ៣.១ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទជាសត្យានុម័តនៃការប្រព្រឹត្តបទល្មើស

យោងតាមអំពើជាសត្យានុម័តនៃបទល្មើសនីមួយៗ គេអាចបែងចែកបទល្មើសដូចខាងក្រោម៖

#### ៣.១.១ ចំណាត់ថ្នាក់ទៅតាមប្រភេទនៃអំពើជាសម្ភារៈ

ប្រភេទនៃអំពើជាសម្ភារៈនៃបទល្មើសមួយ អាចជាការប្រព្រឹត្តសកម្មភាពណាមួយ ឬការមិនប្រព្រឹត្តសកម្មភាពណាមួយ ។ បើសិនអំពើជាសម្ភារៈជាការប្រព្រឹត្តសកម្មភាព បទល្មើសមានឈ្មោះថា បទល្មើសសកម្ម។ ផ្ទុយទៅវិញ បើសិនអំពើជាសម្ភារៈជាការមិនប្រព្រឹត្តសកម្មភាព ឬ អនុបវាទ បទល្មើសមានឈ្មោះថា បទល្មើសអកម្ម។

#### ក. បទល្មើសសកម្ម

បទល្មើសសកម្ម ជាសកម្មភាពនៃការប្រព្រឹត្តទង្វើណាមួយយ៉ាងខិតខំរបស់ជនល្មើស ពោលគឺអំពើប្រព្រឹត្តជាវិជ្ជមាន ហើយអំពើនេះបំពារបំពានលើការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌ។[13]

**ឧទាហរណ៍៖** អំពើជាសត្យានុម័តនៃអំពើលួច គឺជាអំពើដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ។

អំពើជាវិជ្ជមានដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើស អាចជាកាយវិការណាមួយដូចជា ការសម្លាប់មនុស្ស ការធ្វើឱ្យរបួសដោយការកេះកៃកាំភ្លើង ការលួចដោយដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។ល។ អំពើក៏អាចជាពាក្យសំដី ឬក៏ជាសំណេរណាមួយផងដែរ ដូចជា បទបរិហារកេរ្តិ៍ជាសាធារណៈ ឬបទជេរប្រមាថជាសាធារណៈជាដើម។

#### ខ. បទល្មើសអកម្ម

បទល្មើសអកម្ម សំដៅលើអំពើជាសម្ភារៈដែលចាត់ទុកថាជាធាតុផ្សំនៃបទល្មើសអាចជា**អនុបវាទ** ឬជាអំពើអវិជ្ជមានណាមួយ មានន័យថាចារីមិនបានធ្វើអំពើដែលច្បាប់តម្រូវឱ្យធ្វើ។

[13] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

ក្នុងករណីដែលច្បាប់បានតម្រូវឱ្យជនណាម្នាក់ធ្វើអំពើណាមួយ ការណ៍ដែលមិនបានបំពេញកាតព្វកិច្ចដែលច្បាប់តម្រូវ គឺជា**អនុបវាទ** ពោលគឺជាធាតុផ្សំសម្ភារៈ ឬជាធាតុផ្សំសត្យានុម័តនៃបទល្មើស ។

**ឧទាហរណ៍៖** មាត្រា ៣២៦ នៃក្រមព្រហ្មទណ្ឌ ចាត់ទុកជាបទមិនព្រមប្រគល់អនីតិជន ចំពោះអំពើប្រព្រឹត្តដោយគំនិតទុច្ចរិត មិនព្រមប្រគល់អនីតិជនឱ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**៣.១.២ ចំណាត់ថ្នាក់ទៅតាមរយៈពេលប្រព្រឹត្តបទល្មើស**

យោងទៅតាមរយៈពេលដែលប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស យើងឃើញមានរូបភាពនៃបទល្មើស ៣ (បី) យ៉ាងគឺ បទល្មើសភ្លាមៗ បទល្មើសបន្តរៀងហូរហែ និងបទល្មើសអូសបន្លាយ។ ការសិក្សាអំពីលក្ខណៈវិនិច្ឆ័យនានានៃការបែងចែកបទល្មើសទាំងបីខាងលើនេះ ធ្វើឱ្យយល់កាន់តែច្បាស់ អំពីប្រភេទនៃបទល្មើសនីមួយៗ ព្រមទាំងផលប្រយោជន៍ និងរបបគតិយុត្តដែលអនុវត្តលើប្រភេទនៃបទល្មើសទាំងនោះផងដែរ។

**ក. លក្ខណៈវិនិច្ឆ័យនៃការបែងចែក**

ការវាយតម្លៃថាបទល្មើសណាមួយជាបទល្មើសភ្លាមៗ ជាបទល្មើសបន្តរៀងហូរហែ ឬក៏ជាបទល្មើសអូសបន្លាយ គឺអាស្រ័យទៅតាមអាកប្បកិរិយាដែលបទប្បញ្ញត្តិច្បាប់បានចែងទុកថាវាជាបទល្មើស ផ្ទុយទៅវិញ គឺមិនមែនអាស្រ័យទៅតាមការវាយតម្លៃទៅលើស្ថានភាពដែលបានកើតឡើងដោយជាក់ស្តែងនោះទេ ។

**ក១. បទល្មើសភ្លាមៗ**

នៅពេលដែលបទល្មើសអាចសម្រេចបានក្នុងពេលតែមួយភ្លែត បានន័យថាបទល្មើសដែលកើតឡើងក្នុងពេលតែមួយជាមួយនឹងអំពើប្រព្រឹត្ត គឺបទល្មើសនោះត្រូវចាត់ទុកថាជាបទល្មើសភ្លាមៗ។ យើងអាចនិយាយម្យ៉ាងទៀតថា ការសម្រេច(ការប្រមូលផ្តុំនូវធាតុផ្សំទាំងអស់នៃបទល្មើស)នូវបទល្មើសភ្លាមៗបានកើតឡើងភ្លាមហើយក៏បញ្ចប់ទៅវិញភ្លាមៗដែរ។

**ឧទាហរណ៍៖** អំពើលួច[14] បានសម្រេចនៅពេលដែលជនល្មើសបានដកហូតយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត។ គួរកត់សម្គាល់ផងដែរថា បើទោះបីជាពេលខ្លះ ជនល្មើសត្រូវប្រើពេលវេលាវែងដូចជា ១ (មួយ) ម៉ោង ឬ ២ (ពីរ) ម៉ោង ដើម្បីគាស់ទម្លុះទម្លាយទូដែកយកទ្រព្យសម្បត្តិក៏ដោយ ក៏អំពើលួចនៅតែជាបទល្មើសភ្លាមៗដដែល ពីព្រោះថានៅពេលដែលជនល្មើសកំពុងតែគាស់ទូដែក អំពើលួចពុំទាន់បានសម្រេចផលនៅឡើយទេ ។

[14] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ **អំពើលួច** ជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

### ក២. បទល្មើសបន្តរៀងហូរហែ

បទល្មើសបន្តរៀងហូរហែ ជាបទល្មើសដែលអំពើជាសម្ភារៈប្រព្រឹត្តឡើងបន្តគ្នាជាហូរហែ និង ដោយស៊ីសង្វាក់គ្នានៅក្នុងពេលវេលា។ និយាយម្យ៉ាងទៀតថា ផ្ទុយពីបទល្មើសភ្លាមៗ បទល្មើសបន្តរៀងហូរហែ គឺជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់គ្នាក្នុងរយៈពេលមួយ ដែលបានបង្ហាញឱ្យឃើញពីចេតនាទុច្ចរិតដែលស្ថិតនៅជាដរាប។ សម្រាប់បទល្មើសបន្តរៀងហូរហែ អ្នកនីតិបញ្ញត្តិបានចាត់ទុកថា ជាអំពើប្រព្រឹត្តនូវបទល្មើសណាមួយដែលកើតឡើងក្នុងពេលវេលាណាមួយ។ ដើម្បីអាចចាត់ទុកថាបទល្មើសណាមួយគឺ ជាបទល្មើសបន្តរៀងហូរហែ គេចាំបាច់ត្រូវពិនិត្យទៅលើសកម្មភាពដែលអ្នកនីតិបញ្ញត្តិចាត់ទុកជាបទល្មើស ពោលគឺត្រូវពិនិត្យមើលថាតើសកម្មភាពនោះ កើតឡើងដោយទាមទារឱ្យមានរយៈពេលណាមួយ ឬក៏កើតឡើងភ្លាមៗ។ ប្រសិនបើសកម្មភាព នោះកើតឡើងដោយទាមទារឱ្យមានរយៈពេលណាមួយ នោះគឺជាបទល្មើសបន្តរៀងហូរហែ ។

**ឧទាហរណ៍៖** បទទទួលផលចោរកម្ម[15] ត្រូវបានបង្កើតឡើងចាប់ពីពេលដែលបុគ្គលម្នាក់ទទួលទិញវត្ថុណាមួយ ដោយដឹងជាក់ច្បាស់ថាវត្ថុនោះបានមកដោយសារតែការប្រព្រឹត្តបទល្មើស (ដូចជាអំពើលួចជាដើម) ។ ដរាបណាជនទទួលផលចោរកម្មបន្តកាន់កាប់វត្ថុទិញនោះ បទល្មើសត្រូវបានចាត់ទុកថានៅតែបន្តប្រព្រឹត្តទៅទៀតពុំទាន់បានចប់សព្វគ្រប់នៅឡើយ។ បទទទួលផលចោរកម្ម ត្រូវបានបញ្ចប់នៅពេលណាដែលជនទទួលផលចោរកម្មយកវត្ថុល្មើសចេញពីរូបខ្លួន ដោយលក់ចេញទៅឱ្យតតិយជនជាដើម ។

### ក៣. បទល្មើសអូសបន្លាយ

បទល្មើសអូសបន្លាយ គឺជាបទល្មើសដែលអំពើបង្កគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែគ្មានអាក់ខានក្នុងរយៈពេលណាមួយឡើយ។ និយាយម្យ៉ាងទៀតថា បទល្មើសអូសបន្លាយ សំដៅលើបទល្មើសដែលបង្កើតឡើងដោយបណ្តាអំពើជាច្រើនប្រហាក់ប្រហែលគ្នា ដោយអំពើនីមួយៗក៏ត្រូវចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែដោយសារឯកភាពនៃសេចក្តីសម្រេចចិត្ត(គោលដៅរបស់ជនល្មើស) និង ភាពដូចគ្នានៃច្បាប់ដែលជនល្មើសបានបំពាន អំពើច្រើនប្រហាក់ប្រហែលគ្នានោះ គួរតែចាត់ទុកថាជាបទល្មើសតែមួយប៉ុណ្ណោះ ។

**ឧទាហរណ៍៖** បទផិត[16] ត្រូវកើតឡើងនៅពេលដែលបុរស ឬ ស្ត្រីដែលមានសហព័ទ្ធត្រឹមត្រូវតាមច្បាប់រួចហើយ បែរជាទៅរួមសេវនកិច្ចជាមួយនឹងស្ត្រី ឬបុរសផ្សេងទៀត ។ ឧបមាថា ជនល្មើសបានរួមសេវនកិច្ច ៥ (ប្រាំ) ដងជាមួយនឹងបុរស ឬ ស្ត្រីដទៃទៀតដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន។ ប្រសិនបើបទល្មើសបានកើតឡើងចំនួន ៥ (ប្រាំ) ដង គួរចាត់ទុកថាមានបទល្មើសតែមួយប៉ុណ្ណោះដែលកើតឡើង មិនមែនមានបទល្មើសចំនួន ៥ (ប្រាំ) ទេ ដោយ

---

[15] មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ **អំពើទទួលផលចោរកម្ម** គឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

[16] មាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាព **អំពើផិត** គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។

ហេតុថាគោលដៅរបស់ជនល្មើសមានតែមួយប៉ុណ្ណោះ ហើយច្បាប់ដែលត្រូវផ្តន្ទាទោសលើអំពើនេះ ក៏ជាច្បាប់តែមួយដែរ។

**ខ. ផលប្រយោជន៏នៃការបែងចែក**

**ខ១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល**

យោងតាមមាត្រា ១១ វាក្យខ័ណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចិរវេលារបស់អាជ្ញាយុកាលនៃបទល្មើសត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ ការចាប់ផ្តើមគិតបែបនេះ ត្រូវយកមកអនុវត្តសម្រាប់បទល្មើសភ្លាមៗ ។

**ឧទាហរណ៍៖** ចំពោះបទល្មើសឃាតកម្មដែលជាបទល្មើសភ្លាមៗ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស បានន័យថា ចាប់ពីពេលដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិត ។

ចំណែកឯចិរវេលានៃអាជ្ញាយុកាល សម្រាប់បទល្មើសបន្តរៀងហូរហែ និងបទល្មើសអូសបន្លាយ ត្រូវចាប់ផ្តើមគិតពីពេលដែលអំពើល្មើសបានបញ្ចប់ តែមិនមែនចាប់ផ្តើមគិតពីពេលដែលអំពើល្មើសបានចាប់ផ្តើមឡើយ។

**ឧទាហរណ៍៖** ចំពោះបទទទួលផលចោរកម្មដែលជាបទល្មើសបន្តរៀងហូរហែ ចិរវេលារបស់អាជ្ញាយុកាលនៃបទល្មើស ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលជនល្មើស លែងរក្សាទុកវត្ថុនៅនឹងខ្លួនតទៅទៀត ដូចជាថ្ងៃដែលជនល្មើសបានយកកម្មវត្ថុនៃបទល្មើសទៅលក់ចេញជាដើម។ រីឯបទផិតវិញ (បទល្មើសអូសបន្លាយ) ចិរវេលានៃអាជ្ញាយុកាលនៃបទល្មើស ត្រូវគិតចាប់ពីថ្ងៃដែលអំពើប្រព្រឹត្តរបស់ជនល្មើសចុងក្រោយបង្អស់ មិនមែនគិតចាប់ពីពេលប្រព្រឹត្តបទល្មើសដំបូងនោះទេ។

**ខ២. ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច**

ជាទូទៅ តុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទល្មើស គឺជាតុលាការនៃទីកន្លែងប្រព្រឹត្តបទល្មើស។[17] ដូច្នេះសម្រាប់បទល្មើសភ្លាមៗ តុលាការមានសមត្ថកិច្ចអាចមានតែមួយប៉ុណ្ណោះ បើយោងតាមគោលការណ៍ខាងលើ ផ្ទុយទៅវិញ ចំពោះបទល្មើសអូសបន្លាយ និងបទល្មើសបន្តរៀងហូរហែវិញ អំពើល្មើសអាចប្រព្រឹត្តនៅទីកន្លែងខុសៗគ្នា ពោលគឺតុលាការនៃទីកន្លែងផ្សេងៗគ្នាសុទ្ធតែអាចជាតុលាការមានសមត្ថកិច្ចទាំងអស់ ។

**៣.១.៣ ចំណាត់ថ្នាក់ទៅតាមចំនួននៃអំពើនៅក្នុងបទល្មើស**

ដោយផ្អែកទៅលើចំនួននៃអំពើនៅក្នុងបទល្មើសមួយ គេអាចធ្វើការបែងចែកបទល្មើសជា បទល្មើសធម្មតា បទល្មើសស្មុគស្មាញ និង បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ ហើយការបែងចែកនេះបានផ្តល់នូវផលប្រយោជន៍ផ្នែកគតិយុត្តមួយចំនួនផងដែរ។

**ក. លក្ខណៈវិនិច្ឆ័យនៃការបែងចែក**

ដើម្បីកំណត់បទល្មើសទាំងនេះ គឺអាស្រ័យទៅតាមចំនួន ព្រមទាំងលក្ខណៈនៃអំពើ ដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើសនោះ។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩០។

**ក១. បទល្មើសធម្មតា ឬបទល្មើសសាមញ្ញ**

បទល្មើសធម្មតា គឺជាបទល្មើសដែលត្រូវបានសម្រេចឡើងដោយ អំពើជាសត្យានុម័តតែមួយគត់ប៉ុណ្ណោះ ។

**ឧទាហរណ៍៖** មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ហេតុដូចនេះ អំពើជាសត្យានុម័តដែលជាធាតុផ្សំនៃអំពើលួចមានតែមួយគត់ គឺជាការដកហូតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ ។

**ក២. បទល្មើសស្មុគស្មាញ ឬបទល្មើសសាំញ៉ាំ**

បទល្មើសស្មុគស្មាញ គឺជាបទល្មើសដែលបានសម្រេចឡើងដោយមានអំពើជាសត្យានុម័តច្រើនគួបផ្សំគ្នា។ បទល្មើសស្មុគស្មាញ គឺជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ ក៏ប៉ុន្តែគឺជាបទល្មើសដែលកើតឡើងភ្លាមៗ។

**ឧទាហរណ៍៖** មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា អំពើលួចដោយប្រព្រឹត្តអំពើហិង្សា មានធាតុសត្យានុម័តចំនួនពីរគឺ៖

- ការប្រើប្រាស់ហិង្សាបំពារបំពានរូបរាងកាយ ឬអាយុជីវិតអ្នកដទៃ និង
- ការដណ្តើមយកទ្រព្យសម្បត្តិដែលមិនមែនជារបស់ខ្លួន។

**ក៣. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់**

បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ គឺជាបទល្មើសដែលកើតឡើងដោយសារអំពើដែលកើតឡើងពីការប្រព្រឹត្តអំពើដដែលៗ ម្តងហើយម្តងទៀតគឺ បង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោស ។ ក្នុងន័យនេះ បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ គឺជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ ។ ថ្វីត្បិតតែជាបទល្មើសដែលត្រូវអនុវត្តជាបន្តបន្ទាប់ក្តី បទល្មើសនេះត្រូវកើតឡើងភ្លាមៗ នៅពេលដែលមានអំពើចុងក្រោយដែលជាធាតុផ្សំនៃបទល្មើស (ទម្លាប់) ។

**ឧទាហរណ៍៖** អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គលដែលធ្វើដោយផ្ទាល់មាត់ ឬតាមលិខិត រូបភាព ឬវត្ថុអ្វីមួយ គឺជាបទល្មើស និងត្រូវផ្តន្ទាទោសតាមមាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត។ ក្នុងន័យនេះ បើអំពើគំរាមកំហែងធ្វើឡើងតែម្តងគត់ មិនត្រូវបានចាត់ទុកជាបទល្មើសទេ ។

**ខ. ផលប្រយោជន៏នៃការបែងចែក**

**ខ១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល**

សម្រាប់បទល្មើសស្មុគស្មាញ និងបទល្មើសដែលកើតចេញមកពីអំពើប្រព្រឹត្តជាទម្លាប់ អាជ្ញាយុកាលនៃបទល្មើសត្រូវចាប់រាប់ពីការសម្រេចអំពើចុងក្រោយនៃបទល្មើស ពីព្រោះថា បទល្មើសនឹងសម្រេចទាំងស្រុងចាប់ពីពេលសម្រេចអំពើចុងក្រោយនៃបទល្មើស តែមិនមែនចាប់ពីអំពើទីមួយនៃបទល្មើសនោះទេ បើទោះបីជាមានគម្លាតរយៈ

ពេលយូរយ៉ាងណារវាងអំពើទីមួយ និងអំពើទីពីរក៏ដោយ ។

**ឧទាហរណ៍៖** ឈ្មោះ **ក** បានគំរាមកំហែងជនរងគ្រោះតាមទូរស័ព្ទជាលើកទី ១ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ និងជាលើកទី ២ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១។ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្ដើមគិតពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ តែមិនមែនចាប់គិតពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០ ឡើយ ពីព្រោះថាបទល្មើសបានកើតឡើងនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ ដែលជាអំពើចុងក្រោយនៃធាតុផ្សំបទគំរាមកំហែង។

**ខ២. ផលប្រយោជន៍ទាក់ទងនឹងតុលាការមានសមត្ថកិច្ច**

តុលាការច្រើនអាចមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទល្មើស នៅពេលដែលអំពើជាធាតុផ្សំសត្យានុម័តនៃបទល្មើសត្រូវបានប្រព្រឹត្តនៅទីកន្លែងខុសៗគ្នា។

**ឧទាហរណ៍៖** ជនល្មើស បានគំរាមកំហែងជនរងគ្រោះលើកទី ១ នៅរាជធានីភ្នំពេញ លើកទី ២ នៅខេត្តកណ្ដាល និងលើកទី ៣ នៅខេត្តកំពង់ស្ពឺ។ ក្នុងករណីបែបនេះ តុលាការមានសមត្ថកិច្ចអាចជាសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្ដាល និងសាលាដំបូងខេត្តកំពង់ស្ពឺ ។

**៣.១.៤ ចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃបទល្មើស**

លទ្ធផលនៃបទល្មើសសំដៅទៅលើ**ព្យសនកម្ម** ដែលជាផលវិបាកនៃអំពើសត្យានុម័តរបស់ចារី។ លទ្ធផលនៃអំពើល្មើស គឺជាព្យសនកម្ម ឬជាការនាំឱ្យអន្តរាយដល់សង្គមមានដូចជា ព្យសនកម្មសម្ភារៈ ព្យសនកម្មផ្លូវកាយ និង ព្យសនកម្មផ្លូវចិត្ត។[18]

ដោយយោងទៅលើលទ្ធផលនៃបទល្មើស បទល្មើសត្រូវបានបែងចែកជាពីរប្រភេទគឺ បទល្មើសសម្ភារៈ និង បទល្មើសទម្រង់ ឬហៅម្យ៉ាងទៀតថា បទល្មើសរូបភាព។

**ក. បទល្មើសសម្ភារៈ**

បទល្មើសមួយគឺជាបទល្មើសសម្ភារៈ នៅពេលដែលច្បាប់តម្រូវឱ្យមានភស្តុតាងអំពីលទ្ធផលណាមួយជាកំណត់ដើម្បីអាចឱ្យចាត់ទុកថាជាបទបានសម្រេចផល។ ដូច្នេះ លទ្ធផលនៃអំពើល្មើសជាធាតុផ្សំមួយនៃបទល្មើស ហើយបទល្មើសអាចបានផល នៅពេលដែលលទ្ធផលបានទទួល ឬនិយាយម្យ៉ាងទៀតថា ជនរងគ្រោះបានទទួលរងនូវព្យសនកម្មពិតប្រាកដ ដែលចារីបានគ្រោងទុកជាមុន។

**ឧទាហរណ៍៖** បទឃាតកម្ម[19] បានសម្រេចនៅពេលដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិត។ មរណភាពរបស់ជនរងគ្រោះត្រូវតែមានហេតុនៅក្នុងអំពើរបស់ចារី ដែលអាចជាអំពើចាក់នឹងកាំបិត ឬបាញ់នឹងកាំភ្លើងជាដើម ហើយក៏ដោយសារតែអំពើចាក់ ឬអំពើបាញ់ពីសំណាក់ចារីនេះឯង ទើបបណ្ដាលឱ្យជនរងគ្រោះបាត់បង់ជីវិត។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣។

[19] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ **បទឃាតកម្ម** គឺជាអំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ណាមួយ ដូចបានកំណត់ក្នុងមាត្រា ២០០ ដល់មាត្រា ២០៥។

**ខ. បទល្មើសទម្រង់ ឬ បទល្មើសរូបភាព**

បទល្មើសនេះផ្ទុយពីបទល្មើសសម្ភារៈ បទល្មើសរូបភាពក៏អាចត្រូវផ្តន្ទាទោសបានផងដែរ ដោយមិនអាស្រ័យទៅលើលទ្ធផលនៃបទល្មើសឡើយ ពោលគឺចាត់ទុកថាជាបទល្មើសបានសម្រេច ទោះបីជាលទ្ធផលដែលជនល្មើសប្រាថ្នាចង់បាន បែរជាមិនបានទទួលក៏ដោយ។

**ឧទាហរណ៍៖** បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង កើតឡើងនៅពេលដែលជនល្មើសបានគំរាមកំហែង ដើម្បីញុះញង់ឱ្យជនរងគ្រោះកុំឱ្យដាក់ពាក្យបណ្តឹង ឬ ដកពាក្យបណ្តឹងរបស់ខ្លួន។ លទ្ធផលដែលចារីចង់បានពីបទល្មើសនេះ គឺធ្វើយ៉ាងណាឱ្យជនរងគ្រោះភ័យខ្លាច ហើយមិនដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងដែលបានដាក់រួចហើយ។ ក៏ប៉ុន្តែមាត្រា ៥២៧ នៃក្រមព្រហ្មទណ្ឌ ចាត់ទុកថាជាបទល្មើស ទោះបីជាជនរងគ្រោះធ្វើតាមបំណងប្រាថ្នារបស់ជនល្មើស ឬក៏មិនធ្វើតាមក៏ដោយ ។

**៣.១.៥ ចំណាត់ថ្នាក់ទៅតាមសភាពនៃអំពើ**

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ បានកំណត់នូវសញ្ញាណពីរទាក់ទងនឹងបទល្មើសគឺ បទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែង។

**ក. បទល្មើសជាក់ស្តែង**

បទល្មើសជាក់ស្តែង គឺជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលបច្ចុប្បន្នកំពុងប្រព្រឹត្ត ឬដែលទើបនឹងប្រព្រឹត្ត ឬជនសង្ស័យត្រូវបានសាក្សី ឬជនរងគ្រោះចង្អុលបង្ហាញនូវនឹងកន្លែងដែលប្រព្រឹត្តបទល្មើស។[20]

**ឧទាហរណ៍៖** លោក ខ បានដើរសំដៅទៅវាយលោក **ក** ដោយហេតុថាលោក **ក** ច្រៀងស្តាប់មិនបាននៅក្នុងកម្មវិធីមួយកន្លែង កំឡុងពេលប្រព្រឹត្តអំពើរបស់លោក ខ នោះផងដែរ ម្ចាស់កម្មវិធីក៏បានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់ការរឿងនេះតាមនីតិវិធី។

**ខ. បទល្មើសមិនជាក់ស្តែង**

បទល្មើសមិនជាក់ស្តែងផ្ទុយនឹងបទល្មើសជាក់ស្តែង ពោលគឺជាបទល្មើសទាំងឡាយណាដែលការប្រព្រឹត្តបានចប់សព្វគ្រប់ទៅហើយ។

**ឧទាហរណ៍៖** ការប្រទះឃើញមានសាកសពមួយដេកស្លាប់នៅក្នុងព្រៃ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតបឋម ស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**៣.២ ចំណាត់ថ្នាក់បទល្មើសផ្អែកលើបែបបទជាអត្តនោម័តនៃការប្រព្រឹត្តបទល្មើស**

យោងទៅលើធាតុផ្សំអត្តនោម័តនៃបទល្មើសមួយ គេអាចបែងចែកបទល្មើសជាបទល្មើសចេតនា និងបទល្មើសអចេតនា។

---

[20] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៦។

**ក. បទល្មើសចេតនា**

បទល្មើសចេតនា គឺជាបទល្មើសទាំងឡាយណា ដែលចារីមានចេតនាប្រព្រឹត្តយ៉ាងពិតប្រាកដ។

**ឧទាហរណ៍៖** អំពើលួច គឺចារីមានចេតនាទុច្ចរិតចង់ដកហូតយកវត្ថុរបស់អ្នកដទៃ បានន័យថា ជនល្មើសបានប្រព្រឹត្តអំពើដកហូតដោយចេតនា និងមានបំណងយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

**ខ. បទល្មើសអចេតនា**

បទល្មើសអចេតនា គឺជាបទល្មើសទាំងឡាយណា ដែលជនល្មើសគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែបទល្មើសនៅតែមាន ពីព្រោះថាបទល្មើសកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយ ទ្បៀកណាមួយ។

**ឧទាហរណ៍៖** បទបង្ករបួសស្នាមដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃ ដោយការមិនប្រុងប្រយ័ត្នរបស់ចារី។

**៤. បទល្មើសដែលគ្មានអាជ្ញាយុកាល**

យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ២០០៧ ត្រង់មាត្រា ៩ បានកំណត់អំពីប្រភេទនៃបទល្មើសធំៗមួយចំនួនដែលគ្មានអាជ្ញាយុកាលរួមមាន បទឧក្រិដ្ឋប្រល័យពូជសាសន៍[21] បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[22] និងបទឧក្រិដ្ឋសង្គ្រាម[23] ដោយហេតុថាបទល្មើសទាំងនេះ មានចរិតលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គមជាតិយ៉ាងធ្ងន់ធ្ងរ។ មានន័យថា បើទោះបីជានៅក្រោយពេលប្រព្រឹត្តអំពើល្មើសប៉ុន្មានឆ្នាំក៏ដោយ ក៏ស្ថាប័នមានសមត្ថកិច្ចអាចធ្វើការចោទប្រកាន់ និងអាចយកជនល្មើសមកកាត់ទោសតាមច្បាប់បានដែរ។

---

[21] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៨៣។

[22] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៨៤។

[23] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៩៣។

# ជំពូកទី ២

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

# ជំពូកទី ២

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

បទល្មើស គឺជាអំពើប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តី ដែលបង្កគ្រោះថ្នាក់ដល់សង្គម ហើយត្រូវផ្តន្ទាទោសតាមការកំណត់របស់ច្បាប់ព្រហ្មទណ្ឌទុកជាមុន។ គេអាចនិយាយបានម្យ៉ាងទៀតថា ជាអំពើបំពានច្បាប់ព្រហ្មទណ្ឌ។ អំពើទាំងឡាយណាដែលប្រព្រឹត្តឡើង ហើយដែលបង្កនូវចរិតគ្រោះថ្នាក់ដល់សង្គមនោះ ជនដែលប្រព្រឹត្តអំពើនោះនឹងត្រូវទទួលទោសចំពោះអំពើរបស់ខ្លួនតាមការកំណត់របស់ច្បាប់ជាដាច់ខាត។

ជាគោលការណ៍ ដើម្បីកំណត់ថាអំពើណាមួយគឺជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ លុះត្រាតែមានធាតុផ្សំ ៣ (បី) ជាចម្បង ដើម្បីរួមផ្សំបង្កើតឱ្យមានជាបទល្មើសព្រហ្មទណ្ឌបាន។ ធាតុផ្សំទាំងនោះ រួមមាន៖

- ធាតុនីត្យានុកូល ឬធាតុច្បាប់
- ធាតុសត្យានុម័ត ឬធាតុសម្ភារៈ និង
- ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ។

ជាទូទៅ បទល្មើសនីមួយៗតែងតែមានធាតុផ្សំទាំងបីខាងលើជាដាច់ខាត។[24] មានន័យថា ដើម្បីចោទប្រកាន់បុគ្គលណាមួយថាបានប្រព្រឹត្តបទល្មើសនោះ លុះត្រាតែបានបំពេញធាតុផ្សំទាំង ៣ (បី) នេះ។ តុលាការអាចសម្រេច និងប្រកាសថាជនជាប់ចោទមានពិរុទ្ធ លុះត្រាតែបានពិនិត្យមើលជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។[25]

## ផ្នែកទី ១៖ ធាតុនីត្យានុកូល ឬធាតុច្បាប់

### ១. អត្ថន័យនៃធាតុនីត្យានុកូល ឬធាតុច្បាប់

ធាតុនីត្យានុកូល ឬធាតុច្បាប់ មានន័យថា ដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបាន លុះត្រាតែមានច្បាប់ចែងយ៉ាងច្បាស់លាស់។ ប្រសិនបើច្បាប់ពុំបានចែងថា អំពើនេះ ឬអំពើនោះជាបទល្មើសទេនោះ យើងមិនអាចថាជាបទល្មើសបានឡើយ។ ហេតុនេះហើយ បានជាគេឃើញមានគោលការណ៍បារាំងមួយបាននិយាយថា គ្មានបទល្មើសណាមួយដែលច្បាប់មិនបានចែងទេ។ លើសពីនេះទៅទៀត គេក៏ឃើញមានគោលការណ៍បារាំងមួយទៀតបាននិយាយថា អ្វីៗទាំងអស់ដែលគេមិនបានហាមឃាត់ គឺគេអនុញ្ញាតឱ្យធ្វើ។[26]

គោលការណ៍នីត្យានុកូលភាព ត្រូវបានចែកចេញជាពីរ គឺ៖

- នីត្យានុកូលភាពនៃបទល្មើស និង
- នីត្យានុកូលភាពនៃទោស។

[24] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៣។

[26] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

## ២. គោលការណ៍នីត្យានុកូលភាព

យោងតាមក្រមព្រហ្មទណ្ឌមាត្រា ៣ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីគោលការណ៍នីត្យានុកូលភាព ដែលគោលការណ៍នេះ ត្រូវបានបែងចែកជា ២ (ពីរ) គឺ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស។ គោលការណ៍នីត្យានុកូលភាពនេះ មានចរិតជាបញ្ញត្តគ្រឹះនៅក្នុងប្រព័ន្ធនៃនីតិព្រហ្មទណ្ឌតែម្តង ដោយហេតុថា ច្បាប់ព្រហ្មទណ្ឌ គឺបានបញ្ញត្តដើម្បីបង្កើតនូវបញ្ជីនៃបទល្មើស មានន័យថាជាបញ្ជីនៃអំពើដែលសង្គមបានហាមឃាត់ និងបានបញ្ញត្តដើម្បីបង្កើតនូវបញ្ជីនៃទោស ព្រមទាំងគោលការណ៍មួយចំនួនទាក់ទងដល់ការកំណត់អំពីទោស ក៏ដូចជាការអនុវត្តទោសផងដែរ។[27]

### ២.១ នីត្យានុកូលភាពនៃបទល្មើស

នីត្យានុកូលភាពនៃបទល្មើស មានន័យថា អំពើណាមួយដែលគេអាចចាត់ទុកថាជាបទល្មើស លុះត្រាតែអំពើនោះ មានចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នេះទេ តុលាការមិនអាចផ្តន្ទាទោសជនដែលប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាគេមានគោលការណ៍មួយបាននិយាយថា គ្មានបទល្មើសណាដែលច្បាប់មិនបានចែងឡើយ។

**ឧទាហរណ៍៖** បទឃាតកម្ម ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ត្រង់មាត្រា ១៩៩ បានបញ្ញត្តថា ជាអំពើសម្លាប់មនុស្សដោយចេតនា គឺជាបទល្មើសឃាតកម្ម។

### ២.២ នីត្យានុកូលភាពនៃទោស

នីត្យានុកូលភាពនៃទោស បានន័យថា ដើម្បីយកទោសណាមួយទៅផ្តន្ទាលើជនណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នោះទេ គេមិនអាចអនុវត្តទោសទៅលើបុគ្គលនោះបានឡើយ។ ហេតុនេះហើយ បានជាគេឃើញមានគោលការណ៍មួយទៀតចែងថា គ្មានទោសដែលច្បាប់មិនបានចែងនោះឡើយ។[28]

**ឧទាហរណ៍៖** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ១៩៩ បានបញ្ញត្តពីបទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ។

## ៣. គោលបំណងនៃគោលការណ៍នីត្យានុកូលភាព

គោលការណ៍នីត្យានុកូលភាព មានសារៈសំខាន់ណាស់នៅក្នុងប្រព័ន្ធនីតិសាស្ត្រ ជាពិសេសសម្រាប់នីតិព្រហ្មទណ្ឌ ពីព្រោះថាគោលការណ៍នេះមានគោលបំណងសំខាន់ៗចំនួន ២ (ពីរ) គឺ៖

---

[27] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[28] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

### ក. ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ

ចំណុចនេះជាបញ្ញត្តគ្រឹះដើម្បីការពារនូវសេរីភាពរបស់បុគ្គល ។ មានន័យថា ប្រជាពលរដ្ឋ ឬមួយក៏សមាជិកសង្គមទាំងអស់ ប្រមូលផ្តុំគ្នារស់នៅក្នុងសង្គម តាមរយៈ**កិច្ចសន្យាសង្គម** ។ កិច្ចសន្យាសង្គមនេះ គឺជាច្បាប់ ដែលច្បាប់នេះគឺជាការសម្តែងនូវឆន្ទៈទូទៅរបស់សមាជិកសង្គមទាំងអស់ តាមរយៈអ្នកតំណាងរបស់ខ្លួន ដែលជាអង្គការនីតិប្បញ្ញត្តិ។ ដូច្នេះ ច្បាប់ដែលអ្នកតំណាងរបស់សមាជិកនៃសង្គមបានធ្វើឡើង ត្រូវបានចាត់ទុកថាជាឆន្ទៈទូទៅរបស់ប្រជាពលរដ្ឋ ដែលជាសមាជិកសង្គមទាំងមូល។ ដើម្បីអាចកំណត់ថាអំពើណាមួយគឺជាបទល្មើស ហើយអាចផ្តន្ទាទោសអំពើនោះបាន លុះត្រាតែមានច្បាប់ចែងកំណត់ជាមុនប្រាប់ទៅដល់សមាជិក សង្គមទាំងអស់ថាអំពើនេះគឺជាបទល្មើស ដូចដែលបានបញ្ជាក់ថាច្បាប់ព្រហ្មទណ្ឌស្តែងឡើងហាក់បីដូចជា បញ្ជីនៃការហាមឃាត់ បញ្ជីនៃបទល្មើសព្រហ្មទណ្ឌ ឬមួយបញ្ជីនៃទោស មានន័យថាច្បាប់ព្រហ្មទណ្ឌនេះគឺ កំណត់អំពីព្រំដែននៃសិទ្ធិសេរីភាព រហូតដល់មានអ្នកច្បាប់មួយចំនួនគេបាន កំណត់ថាច្បាប់ព្រហ្មទណ្ឌគឺជាព្រំដែននៃសិទ្ធិ មានន័យស្មើនឹងការប្រាប់ទៅដល់ប្រជាពលរដ្ឋឱ្យបានដឹងថា តើអំពើណាខ្លះគឺជាអំពើហាមឃាត់ ហើយអ្វីដែលមិនបានហាមឃាត់ដោយច្បាប់ព្រហ្មទណ្ឌ យើងអាចចាត់ទុកថាអំពើនោះជាសេរីភាពរបស់បុគ្គលគ្រប់រូប។ ប៉ុន្តែ អ្វីដែលបានចែងចូលទៅក្នុងបញ្ជីនៃបទប្បញ្ញត្តិព្រហ្មទណ្ឌ មានន័យថា គេត្រូវបានកំណត់ថាប្រសិនបើអ្នកណាប្រព្រឹត្តអំពើទាំងឡាយណាដែលរំលោភទៅលើបញ្ជីនៃបទល្មើសនេះ អ្នកនោះនឹងត្រូវផ្តន្ទាទោសទៅតាមបញ្ជីនៃច្បាប់ព្រហ្មទណ្ឌជាធរមានជាក់ស្តែង ពិសេសគឺក្រមព្រហ្មទណ្ឌថ្មីឆ្នាំ ២០០៩ នេះឯង។ ផ្ទុយទៅវិញ ប្រសិនបើជាអ្វីដែលមិនមានចែងច្បាស់នោះទេ យើងអាចចាត់ទុកថា បុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបាន លើកលែងតែអំពើនោះវាប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ[29] ហើយបើប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ គឺគេអាចប្រើប្រាស់នូវសិទ្ធិតាមនីតិរដ្ឋប្បវេណី ពិសេសគឺក្រមរដ្ឋប្បវេណី ដើម្បីទាមទារនូវសំណងជួសជុលនូវព្យសនកម្ម(ការខូចខាត)ផ្សេងៗបាន។

**ឧទាហរណ៍៖** ការបរិហារកេរ្តិ៍ និងការជេរប្រមាថ ក្រមព្រហ្មទណ្ឌ បានចាត់ទុកថាអំពើទាំងនេះគឺត្រូវស្ថិតនៅក្នុងបញ្ជីមួយនៃបទល្មើសព្រហ្មទណ្ឌ ការជេរប្រមាថ និងការបរិហារកេរ្តិ៍ទៅលើអ្នកដទៃ គឺជាអំពើផ្ទុយទៅនឹងសីលធម៌សង្គម និងប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃ។ ហេតុនេះហើយ ទើបបានជាក្រមព្រហ្មទណ្ឌនៅតែរក្សាបទប្បញ្ញត្តិនេះដោយចាត់ទុកថាអំពើទាំងនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដើម្បីជៀសវាងមានការបកស្រាយថា បើសិនជាយើងមិនចែងពីបទល្មើសបរិហារកេរ្តិ៍ ក៏ដូចជាបទជេរប្រមាថអ្នកដទៃចូលទៅក្នុងក្រមព្រហ្មទណ្ឌដោយចាត់ទុកវាថា គឺជាឈ្មោះបទល្មើសនៅក្នុងតារាងនៃបញ្ជីព្រហ្មទណ្ឌទេនោះ វានឹងអាចមានអ្នកដទៃគេយកទៅធ្វើការពិនិត្យ និងបកស្រាយថាទាំងនោះគឺជាសិទ្ធិរបស់គេក្នុងការជេរប្រមាថ ឬបរិហារកេរ្តិ៍អ្នកដទៃ។ ដូច្នេះ យើងមិនទទួលស្គាល់នូវអំពើបែបនេះថាមិនមែនជាបទល្មើសទេ ព្រោះនៅក្នុងសង្គមកម្ពុជាដែលមានទំនៀមទម្លាប់ និងប្រពៃណីដ៏ល្អផូផង់ យើងមិនចាត់ទុកថាគឺជាសិទ្ធិនោះទេ។

---

[29] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ៣១។

### ខ. បង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ

ពាក់ព័ន្ធជាមួយនឹងការបង្ការទុកជាមុននូវបទល្មើសព្រហ្មទណ្ឌ មានការស្រាវជ្រាវជាច្រើននៅក្នុងបញ្ហានេះ ជាពិសេសសម្រាប់ឧក្រិដ្ឋវិទូ ឬអ្នកប្រាជ្ញខាង**ឧក្រិដ្ឋវិជ្ជា** ព្រោះនៅក្នុងទ្រឹស្តីឧក្រិដ្ឋវិជ្ជា គេបានចាត់ទុកថាការដែលចែងទុកជាមុននៅក្នុងអត្ថបទច្បាប់ ជាពិសេសគឺដើម្បីឱ្យប្រជាពលរដ្ឋដឹងថាតើអំពើណាខ្លះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសនោះ នឹងអាចចូលរួមបាននូវការកាត់បន្ថយនូវបទល្មើសព្រហ្មទណ្ឌ។[30]

**ឧទាហរណ៍៖** ប្រសិនបើយើងមិនចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌដោយបញ្ជាក់ថា បទល្មើសណាមួយត្រូវបានផ្តន្ទាទោសដាក់គុកពីប៉ុណ្ណេះទៅប៉ុណ្ណោះទេ វានឹងនាំឱ្យបុគ្គលនោះ គាត់អាចយល់ឃើញថានេះគឺជាសេរីភាព ដូច្នេះគាត់អាចប្រព្រឹត្តបទល្មើស។ នៅក្នុងករណីដែលច្បាប់ចែងយ៉ាងជាក់លាក់ថា អំពើដែលយើងប្រព្រឹត្តនោះ ជាបទល្មើសព្រហ្មទណ្ឌ ដូច្នេះការចែងទុកជាមុននេះ អាចធ្វើឱ្យបុគ្គលនោះរាងចាល ឬមួយក៏ខ្លាចរអានឹងការប្រព្រឹត្តបទល្មើស។ ហេតុនេះហើយបានជាគោលការណ៍នេះ យើងអាចចាត់ទុកថាជាគោលការណ៍មួយដែលចូលរួមនៅក្នុងការបង្ការបទល្មើសមួយផ្នែក។

## ៤. ផលវិបាកនៃគោលការណ៍នីត្យានុកូល

### ៤.១ ការបកស្រាយច្បាប់

ការបកស្រាយនូវច្បាប់ព្រហ្មទណ្ឌ គឺជាការបកស្រាយដើម្បីធានានូវការគោរពដល់គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស បានន័យថា ត្រូវមានបទប្បញ្ញត្តិច្បាប់ចែងទុកជាមុនថាអំពើនោះគឺជាបទល្មើស ហើយនឹងត្រូវផ្តន្ទាទោស គឺដើម្បីធានានូវការគោរពច្បាប់ឱ្យបានច្បាស់លាស់ត្រឹមត្រូវ ទើបនៅក្នុងក្រមព្រហ្មទណ្ឌ តាមរយៈបទប្បញ្ញត្តិនៃមាត្រា ៥ បានចែងអំពីគោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ។ នៅក្នុងរឿងព្រហ្មទណ្ឌ គឺច្បាប់មិនអនុញ្ញាតឱ្យចៅក្រមធ្វើការបកស្រាយដោយពង្រីកវិសាលភាពនោះទេ ហើយច្បាប់ក៏មិនអនុញ្ញាតឱ្យចៅក្រមប្រើវិធីសាស្ត្រក្នុងការបកស្រាយតាមន័យជាការអនុវត្តបែប**សទិសភាព**ដែរ បានន័យថា ចៅក្រមត្រូវបកស្រាយក្រមព្រហ្មទណ្ឌ ឬក៏ច្បាប់ព្រហ្មទណ្ឌ ដែលជាបទប្បញ្ញត្តិមានចែងអំពីបទល្មើស និងទោសនេះក្នុងអត្ថន័យមួយយ៉ាង**តឹងរ៉ឹង** ដើម្បីកុំឱ្យឃ្លាតចាកពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស។

ហេតុដូច្នេះ ចៅក្រមត្រូវតែអនុវត្តនូវអ្វីដែលច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌបានចែងថា អំពើបែបនោះ គឺជាបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែនៅពេលដែលមានស្ថានភាពមួយប្រហាក់ប្រហែលទៅនឹងស្ថានភាពដែលច្បាប់បានចែងកើតឡើង ចៅក្រមមើលទៅឃើញថាវាអាចស្រដៀងគ្នា ឬប្រហាក់ប្រហែលគ្នា ហើយចៅក្រមនោះយល់ឃើញថា អំពើ

---

[30] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

បែបនេះអាចប៉ះពាល់ខ្លះៗដែរ ក៏ស្រាប់តែគាត់ទៅយកស្ថានភាពប្រហាក់ប្រហែល ឬស្រដៀងនោះមកបកស្រាយ នោះបើតាមមាត្រា ៥ នៃក្រមព្រហ្មទណ្ឌថ្មី មិនអនុញ្ញាតឱ្យចៅក្រមបកស្រាយតាមន័យសទិសភាពឡើយ។[31]

**ឧទាហរណ៍៖** នារីម្នាក់ បានស្រឡាញ់គ្នាជាមួយនឹងបុរសម្នាក់។ មួយរយៈក្រោយមក ដោយមនោសញ្ចេតនាកាន់តែស៊ីជម្រៅ ពួកគេទាំងពីរបានរួមសមគ្គសង្វាស (រួមដំណេក) ជាមួយគ្នា ដោយភាគីជាបុរសបានសន្យានឹងរៀបការជាមួយនឹងនារីម្នាក់នោះ។ មួយរយៈពេលក្រោយមក បុរសនោះក៏បានដកដៃចេញពីនារីនោះ ដោយមានមូលហេតុផ្សេងៗ។ ក្នុងករណីនេះ ចៅក្រមមិនអាចបកស្រាយថាអំពើរបស់បុរសនោះថាជាអំពើឆបោក ឬអំពើរំលោភទំនុកចិត្ត ដោយបកស្រាយតាមន័យសទិសភាពទេ តាមរយៈការក្បត់ពាក្យសន្យាថានឹងរៀបការជាដើម។ ក៏ប៉ុន្តែ ចៅក្រមអាចចោទប្រកាន់ពីបទល្មើសផ្សេងជំនួសបាន ក្នុងករណីបានបំពេញធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដូចជាករណីរំលោភជាដើម។

## ៤.២ អានុភាពនៃនីតិព្រហ្មទណ្ឌ

### ៤.២.១ ការអនុវត្តនីតិព្រហ្មទណ្ឌក្នុងកាល ឬពេលវេលា

ការអនុវត្តនីតិព្រហ្មទណ្ឌក្នុងកាល សំដៅទៅលើការចូលជាធរមាននៃច្បាប់ព្រហ្មទណ្ឌ។ តាមគោលការណ៍នេះ ច្បាប់ព្រហ្មទណ្ឌមានអានុភាពអនុវត្តបាន លុះត្រាតែច្បាប់ព្រហ្មទណ្ឌដែលរដ្ឋសភាបានអនុម័ត ហើយបានចូលជាធរមាន ព្រមទាំងបានបន្តរហូតដល់ច្បាប់នេះត្រូវបានកែប្រែ ឬ លុបចោលវិញ នៅពេលដែលច្បាប់ព្រហ្មទណ្ឌថ្មីមកជំនួស។[32]

ចំណែកឯការចូលជាធរមាននៃច្បាប់វិញ យោងតាមរដ្ឋធម្មនុញ្ញដែលប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ បានកំណត់ថា ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានត្រួតពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ (ដប់) ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែ បើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយពេលប្រកាសឱ្យប្រើ។[33]

ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ត្រូវបានអនុវត្តដោយផ្អែកទៅលើគោលការណ៍ចំនួន ២ (ពីរ) គឺ៖

- គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និង
- គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។

---

[31] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[32] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

[33] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ៩៣ ថ្មី។

### ក. គោលការណ៍មិនប្រតិសកម្មនៃនីតិព្រហ្មទណ្ឌ

**គោលការណ៍មិនប្រតិសកម្ម** នៃច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ ហើយមានអានុភាពអនុវត្តសម្រាប់តែអនាគតប៉ុណ្ណោះ គឺមិនមានអានុភាពអនុវត្តទៅលើអតីតកាលនោះទេ។ មានន័យថា យើងមិនអាចយកច្បាប់ព្រហ្មទណ្ឌមួយទៅអនុវត្តចំពោះអំពើដែលកើត ឬប្រព្រឹត្តមុនច្បាប់នេះចូលជាធរមានបានទេ។ គោលការណ៍នេះ ក៏ជាវិបាកកម្មមួយដែរ ពីព្រោះថាវាដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស ពោលគឺ មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសបាន។ ដូច្នេះ តាមរយៈគោលការណ៍នេះ ច្បាប់ព្រហ្មទណ្ឌមានអានុភាពអនុវត្តនៅក្នុងកំឡុងពេលចូលជាធរមានតែប៉ុណ្ណោះ ហើយមិនអាចយកច្បាប់ដែលចូលជាធរមាននៅក្នុងពេលនេះ ទៅអនុវត្តចំពោះអំពើដែលប្រព្រឹត្តនៅក្នុងពេលអតីតកាលបានឡើយ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ គឺជាគោលការណ៍ដ៏សំខាន់មួយ ដែលជាគោលការណ៍គ្រឹះនៃសិទ្ធិមនុស្ស និងសង្គមប្រជាធិបតេយ្យ ក្នុងគោលដៅជាពិសេសធានានូវសិទ្ធិសេរីភាព ក៏ដូចជាសុវត្ថិភាពគតិយុត្តនៃពលរដ្ឋ។ ហេតុដូច្នេះហើយ ជាគោលការណ៍គ្រឹះ គឺគេមិនអនុញ្ញាតឱ្យមានការអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ទៅលើអំពើណាដែលកើតឡើងមុនការចូលជាធរមាននៃច្បាប់នោះទេ។

**ឧទាហរណ៍៖** បុរសឈ្មោះ **ក** បានប្រព្រឹត្តអំពើមួយដែលច្បាប់ពីមុនកំពុងមានអានុភាព ហើយច្បាប់នោះមិនបានចែងថាអំពើនោះជាបទល្មើសទេ ស្រាប់តែក្រោយមក ទើបមានច្បាប់ថ្មីមួយបានចូលជាធរមាន ហើយបានកំណត់ថាអំពើនោះជាបទល្មើស។ ក្នុងករណីនេះ តុលាការមិនអាចធ្វើការចោទប្រកាន់ទៅលើឈ្មោះ **ក** បានទេ ពីព្រោះថាអំពើនោះ ជាអំពើដែលបានប្រព្រឹត្តមុនច្បាប់ថ្មីចូលជាធរមាន ហើយច្បាប់ចាស់មិនបានចែងថាជាបទល្មើសទេ។ បើតាមគោលការណ៍ច្បាប់ គឺពុំមានបទល្មើសទេ បើច្បាប់គ្មានចែង។

### ខ. គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង

**គោលការណ៍ប្រតិសកម្ម** នៃច្បាប់ព្រហ្មទណ្ឌនេះ គឺជាគោលការណ៍មួយដែលច្បាប់ព្រហ្មទណ្ឌអាចអនុវត្តទៅលើអំពើដែលប្រព្រឹត្តមុនច្បាប់នេះចូលជាធរមាន។ គោលការណ៍នេះ រួមមាន៖

- **គោលការណ៍ដែលលុបចោលនូវបទល្មើស** ៖ យោងតាមមាត្រា ៩ នៃក្រមព្រហ្មទណ្ឌ បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយ ត្រូវអនុវត្តភ្លាម។ បានន័យថា អំពើប្រព្រឹត្តមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតទេ ហើយការចោទប្រកាន់ដែលកំពុងប្រព្រឹត្ត ត្រូវបានបញ្ចប់ទាក់ទងទៅនឹងការចោទប្រកាន់។ ប្រសិនបើជាអំពើប្រព្រឹត្តរួចហើយ តែមិនទាន់ត្រូវបានចោទប្រកាន់ ច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស ដែលគេចាត់ទុកថាជាច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ត្រូវមានអានុភាពប្រតិសកម្ម គឺមិនអាចចោទប្រកាន់បានទេ។ ហើយបើកំពុងចោទប្រកាន់វិញ ការចោទប្រកាន់នោះក៏ត្រូវបញ្ចប់ដែរ។ ប្រសិនជាក្នុងករណីដែលបានផ្តន្ទាទោសរួច

ហើយ គឺមិនអាចយកទោសនោះមកអនុវត្តបានទៀតទេ ឬបើកំពុងតែអនុវត្តទោសនោះ ការអនុវត្តនោះត្រូវបញ្ឈប់ មានន័យថាគេយកច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង មកអនុវត្តដោយប្រតិសកម្ម ដើម្បីជាផលផ្ដល់ដល់ជនល្មើស ឬផ្ដល់ផលអនុគ្រោះដល់ជនល្មើស ក្នុងគោលដៅគោរពនូវគោលការណ៍មនុស្សធម៌។

**ឧទាហរណ៍៖** បុរសម្នាក់ បានប្រព្រឹត្តនូវអំពើមួយដែលនៅសម័យកាលនោះគេចាត់ទុកថាជាបទល្មើស។ ក្រោយមក ច្បាប់ថ្មីត្រូវបានអនុម័ត និងបានចូលជាធរមានដោយលុបចោលអំពើនោះថា មិនមែនជាបទល្មើសទៀតទេ។ នៅក្នុងករណីនេះ ប្រសិនបើបុគ្គលនោះត្រូវបានផ្ដន្ទាទោសរួច ហើយអនុវត្តទោសមិនទាន់ចប់ទេនោះ ការអនុវត្តនោះត្រូវបញ្ឈប់ចំពោះរូបគាត់។

- **គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌដែលកំណត់ទោសស្រាលជាង** ៖ បទប្បញ្ញត្តិព្រហ្មទណ្ឌដែលចែងអំពីទោសស្រាលជាង ត្រូវយកមកអនុវត្តភ្លាម ក្នុងគោលដៅផ្ដល់នូវផលអនុគ្រោះដល់ជនល្មើស និងធ្វើឱ្យជនល្មើសចេះកសាងខ្លួនឱ្យក្លាយទៅជាពលរដ្ឋល្អឡើងវិញ ដើម្បីទុកជាគុណប្រយោជន៍សម្រាប់សង្គមជាតិទាំងមូលតទៅថ្ងៃអនាគត។

**ឧទាហរណ៍៖** អំពើលួចមួយ បានកើតឡើងនៅក្នុងច្បាប់សម័យអន្តរកាលឆ្នាំ ១៩៩២~១៩៩៣ មក បានកំណត់ផ្ដន្ទាទោសដាក់គុកចំនួន ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ហើយកំពុងតែធ្វើការចោទប្រកាន់រហូតមកដល់ក្រមព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន ដោយក្រមថ្មីនេះបានកំណត់ត្រឹមតែ ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំតែប៉ុណ្ណោះ។ ដូច្នេះ នៅពេលដែលប្រកាសទោស ចៅក្រមត្រូវយកទោសដែលកំណត់នៅក្នុងក្រមថ្មីនេះ គឺចន្លោះ ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ មកអនុវត្តទៅលើបទលួច ដែលប្រព្រឹត្តមុនកាលក្រមថ្មីនេះចូលជាធរមាន ដោយហេតុថាក្រមព្រហ្មទណ្ឌថ្មីបានកំណត់ទោសចំពោះអំពើលួចស្រាលជាង។[34]

យោងតាមមាត្រា ១១ នៃក្រមព្រហ្មទណ្ឌ ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើ**សុពលភាព**នៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ។ មានន័យថា ចំណាត់ការ ឬកិច្ចការផ្សេងៗ ដែលត្រូវបានអនុវត្តស្របតាមច្បាប់ស្ដីពីនីតិវិធី ហើយដែលបានបំពេញស្របតាមវិធានគតិយុត្ត ដែលមានចែងនៅក្នុងមាត្រាច្បាប់ចាស់រួច និងមានតម្លៃស្របច្បាប់ ព្រមទាំងមានអានុភាពអនុវត្តបាន គឺបទប្បញ្ញត្តិថ្មីដែលត្រូវអនុវត្តភ្លាម មិនមានអានុភាពទៅលើបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រានៃច្បាប់ចាស់ឡើយ។

**ឧទាហរណ៍៖** ក្នុងបទល្មើសមួយ ដែលកំពុងចាត់ការតាមនីតិវិធីនៅក្នុងច្បាប់ចាស់ ស្រាប់តែមានច្បាប់ថ្មីបានចូលជាធរមាន ហើយស្រាលជាងច្បាប់ចាស់។ ក្នុងករណីនេះ នីតិវិធីដែលកំពុងចាត់ការនៅក្នុងច្បាប់ចាស់ គឺត្រូវយកមកអនុវត្តបន្ត ប៉ុន្តែទោសដែលត្រូវផ្ដន្ទាវិញ គឺត្រូវយកទោសដែលស្រាលជាងមកអនុវត្ត គឺតាមច្បាប់ថ្មី។

---

[34] ប្រសាសន៍របស់ឯកឧត្ដម ***ផូវ សំភី*** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

### ៤.២.២ ការអនុវត្តនីតិព្រហ្មទណ្ឌក្នុងលំហ ឬដែនដី

#### ក. គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវមានអានុភាពអនុវត្តចំពោះគ្រប់បទល្មើសទាំងអស់ ដែលប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[35] គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌនេះ គឺជាគោលការណ៍គ្រឹះ ដោយហេតុថា ប្រទេសណាក៏ដូចប្រទេសណាដែរ គឺតែងតែយកច្បាប់ព្រហ្មទណ្ឌរបស់គេមកអនុវត្ត ដើម្បីគ្រប់គ្រងនៅក្នុងដែនដី ក្នុងការធានានូវសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេសនោះ។ ក្នុងករណីនេះ នៅពេលដែលមានអំពើណាមួយកើតឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា គេត្រូវយកច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមកអនុវត្តលើអំពើល្មើសនោះ ក្នុងចិរវេលានៃច្បាប់ព្រហ្មទណ្ឌនៅជាធរមាន បានសេចក្តីថា គ្រប់ជនទាំងអស់ដែលប្រព្រឹត្តបទល្មើសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជននោះមានសញ្ជាតិអ្វីក៏ដោយ។

**ឧទាហរណ៍៖** ជនជាតិបារាំងម្នាក់ បានសម្លាប់ជនជាតិខ្មែរ ឬជនជាតិដទៃទៀតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ បើផ្អែកលើគោលការណ៍ដែនដី ច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវយកមកអនុវត្ត និងត្រូវផ្តន្ទាទោសជននោះតាមច្បាប់កម្ពុជា។

យោងតាមគោលការណ៍នៃប្រព័ន្ធដែនដី តម្រូវឱ្យមានការផ្តន្ទាទោសលើគ្រប់ជនល្មើសទាំងអស់ ទោះបីជននោះជាពលរដ្ឋកម្ពុជាក្តី ឬជាជនបរទេសក្តី។ ប្រសិនបើជនទាំងនោះបានប្រព្រឹត្តអំពើល្មើសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលការផ្តន្ទាទោសចំពោះមុខតុលាការកម្ពុជា លើកលែងតែប្រភេទជនបរទេសមួយចំនួន ដែលច្បាប់ផ្តល់អភ័យឯកសិទ្ធិដោយឡែកតាមអនុសញ្ញាអន្តរជាតិ។ ជនបរទេសទាំងនោះ មានដូចជា៖

- ជនបរទេសដែលបម្រើការនៅស្ថានទូត ដូចជា ឯកអគ្គរដ្ឋទូត, អគ្គរដ្ឋទូត, ប្រេសិត, ភារៈមេធាវី ព្រមទាំងក្រុមគ្រួសារ និងបុគ្គលិកស្ថានទូត ក្នុងរយៈពេលដែលបំពេញបេសកកម្មការទូត។
- ជនបរទេសដែលបម្រើការងារនៅស្ថានកុងស៊ុល ដូចជា អគ្គកុងស៊ុល, កុងស៊ុល និងបុគ្គលិកកុងស៊ុល ព្រមទាំងក្រុមគ្រួសាររបស់គេក្នុងពេលបំពេញបេសកកម្មការទូត។
- ជនបរទេសដទៃទៀត ដូចជា តំណាងអង្គការសហប្រជាជាតិ, តំណាងរដ្ឋាភិបាល, តំណាងអង្គការក្រៅរដ្ឋាភិបាល ក្នុងដំណើរទស្សនៈកិច្ចជាផ្លូវការក្តី ក្រៅផ្លូវការក្តី ឬមានបេសកកម្មពិសេសនៅកម្ពុជាក្តី ដោយផ្អែកលើសន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ។[36]

---

[35] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២។

[36] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

## ខ. ស្ថានភាពទាំងប្រាំនៃបទល្មើសដែលចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

បទល្មើសមួយចំនួន អាចប្រព្រឹត្តមិនមែននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុងនោះទេ ប៉ុន្តែច្បាប់ព្រហ្មទណ្ឌកម្ពុជាចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ស្ថានភាពដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា មានដូចជា៖

- **អំពើណាមួយនៃបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ៖ គឺជាបទប្បញ្ញត្តិដែលអនុវត្តសម្រាប់បទល្មើស ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ បទល្មើស ត្រូវចាត់ទុកថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[37]

**ឧទាហរណ៍៖** ការរំលោភសេពសន្ថវៈ បានប្រព្រឹត្តឡើងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវយកមកអនុវត្ត និងផ្តន្ទាទោសជនល្មើស តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលចែងអំពីបទរំលោភសេពសន្ថវៈ។

- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា** ៖ សំដៅទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាកម្ពុជា។ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ។[38]

**ឧទាហរណ៍៖** នាវាដែលមានសញ្ជាតិកម្ពុជា បានធ្វើដំណើរទៅលើដែនដីនៃរដ្ឋបរទេស ហើយក៏មានបទល្មើសកើតឡើងនៅលើនាវានោះ។ ដូច្នេះ ច្បាប់កម្ពុជាយើងក៏បានចែងយ៉ាងច្បាស់ថា គឺជាសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌកម្ពុជាផងដែរ។

- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស** ៖ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសនៅក្នុងនាវាបរទេស ដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។[39] មានន័យថា ពេលខ្លះបទល្មើសមួយចំនួនប្រព្រឹត្តនៅក្នុងនាវាបរទេស ប៉ុន្តែបើតាមអានុភាពនៃកិច្ចព្រមព្រៀងអន្តរជាតិ សន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិនោះ យើងអាចមានសិទ្ធិចូលទៅត្រួតពិនិត្យមើល ឬអាចត្រូវបានគេស្នើសុំឱ្យជួយអន្តរាគមន៍ ដើម្បីទៅពិនិត្យមើលក្នុងស្ថានភាពនោះ។ នៅពេលដែលយើងចូលទៅពិនិត្យមើល ក្នុងករណីនេះ បទល្មើសនោះគឺស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា។

[37] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៣។

[38] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤។

[39] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥។

- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានក្តកម្ពុជា** ៖ សំដៅទៅដល់បទល្មើសដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជាដែរ គ្រាន់តែបទល្មើសនេះគឺប្រព្រឹត្តនៅក្នុងអាកាសយានក្តកម្ពុជា។ នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយានក្តនោះស្ថិតនៅទីណាក៏ដោយ។[40] អាកាសយានក្តនៅទីនេះ សំដៅដល់យានដែលទៅតាមអាកាសបាន ឬយន្តហោះដែលបានចុះបញ្ជីរួចរាល់ហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ឧទាហរណ៍៖** មានការសម្លាប់មនុស្សនៅលើយន្តហោះមួយ ដែលមានទង់ជាតិកម្ពុជា និងដែលបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា គឺមានន័យថាយន្តហោះនេះមានសញ្ជាតិខ្មែរ។ ក្នុងករណីនេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាព ឬមានសមត្ថកិច្ចដើម្បីដោះស្រាយរឿងក្តីនេះ ឬធ្វើការពិនិត្យអំពីអង្គហេតុ ដើម្បីធ្វើការផ្តន្ទាទោសចំពោះករណីសម្លាប់មនុស្សនៅក្នុងយន្តហោះដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[41]

- **បទល្មើសដែលមានអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ៖ នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះត្រូវបានបំពេញ៖
    - បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង
    - អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។[42]

ដូច្នេះ ក្នុងករណីជាបទលហុ អ្នកផ្តើមគំនិត[43] ឬអ្នកសមគំនិត[44] មិនត្រូវបានផ្តន្ទាទោសដូចបានកំណត់ខាងលើនេះទេ។

### គ. បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្រៅពីការអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាហើយនោះ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីសមត្ថកិច្ច ក៏ដូចជាអានុភាពអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសដែល

---

[40] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦។

[41] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[42] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៧។

[43] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៨។

[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៩។

បានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ តាមរយៈអានុភាពនេះ យើងពិនិត្យឃើញថា បញ្ហានេះគឺទាក់ទងទៅនឹង**សញ្ជាតិ**។

- **សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាក្នុងករណីទាក់ទងនឹងសញ្ជាតិរបស់ជនល្មើស** ៖ ក្រមព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់លាស់អំពីជនល្មើសដែលជាពលរដ្ឋខ្មែរ ប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[45] បទល្មើស ត្រូវបានបែងចែកជាពីរគឺ៖
  - **ចំពោះបទឧក្រិដ្ឋ** ៖ ជនល្មើសដែលជាពលរដ្ឋខ្មែរ ប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើជនល្មើសដែលប្រព្រឹត្តបទល្មើសនេះតែម្តង មានន័យថា ច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចធ្វើការដាក់ទោសទៅលើជននោះបាន។
  - **ចំពោះបទមជ្ឈិម** ៖ ចំពោះពលរដ្ឋខ្មែរ ដែលជាជនល្មើសប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចនឹងត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាបាន លុះត្រាតែបទល្មើសដែលប្រព្រឹត្តនោះ ត្រូវបានប្រទេសក្រៅនោះបានកំណត់ថាគឺជាបទល្មើសដែលត្រូវផ្តន្ទាទោសផងដែរ។ ប៉ុន្តែ ប្រសិនបើប្រទេសក្រៅនោះ មិនបានចែងថាអំពើនោះជាបទល្មើសទេ ក្នុងករណីនេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនអាចអនុវត្តចំពោះបទល្មើសនេះបានទេ។[46]
- **សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាក្នុងករណីទាក់ទងនឹងសញ្ជាតិរបស់ជនរងគ្រោះ** ៖ នៅក្នុងករណីដែលជនរងគ្រោះជាពលរដ្ឋខ្មែរ ហើយត្រូវបានគេប្រព្រឹត្តបទល្មើសមកលើខ្លួននៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា នោះច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តចំពោះអំពើនេះ។ នៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់ថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។[47] ក្នុងករណីនេះ ច្បាប់ព្រហ្មទណ្ឌអាចអនុវត្តបានចំពោះបទឧក្រិដ្ឋ។
- **ការធ្វើបណ្តឹងចោទប្រកាន់** ៖ ទាក់ទងទៅនឹងដំណើរការនៃនីតិវិធីក្នុងការចោទប្រកាន់នេះ បើទោះបីជាជនល្មើសជាពលរដ្ឋខ្មែរ ឬជនរងគ្រោះជាពលរដ្ឋខ្មែរក៏ដោយ គឺអាចធ្វើការចោទប្រកាន់បាន លុះត្រាតែស្ថាប័នអយ្យការធ្វើការប្តឹងចោទ ហើយការប្តឹងនេះធ្វើទៅបានទាល់តែមានបណ្តឹងពីជនរង

---

[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៩។

[46] ប្រសាសន៍របស់ឯកឧត្តម **ប៊ុន ហុន** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[47] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២០។

គ្រោះ ឬ**សិទ្ធិវន្ត** ឬ**បណ្តឹងបរិហារ** ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលប្រព្រឹត្តបទល្មើស។ ក្រមព្រហ្មទណ្ឌបានចែងថា នៅក្នុងករណីដែលមានចែងក្នុងមាត្រា ១៩ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។[48]

- **សមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះបទឧក្រិដ្ឋដែលប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា** ៖ ច្បាប់ព្រហ្មទណ្ឌ មានអានុភាពអនុវត្តទៅលើចំពោះបទល្មើសដែលប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះមានចែងនូវចំណុចចំនួន ៥ (ប្រាំ) ប្រភេទ ដោយផ្អែកលើក្រមព្រហ្មទណ្ឌអំពីសមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក។[49] នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា៖
    - បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា
    - បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា
    - បទល្មើសក្លែងរូបិយវត្ថុ និង ធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
    - បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា និង
    - បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

បទល្មើសទាំង ៥ (ប្រាំ) ខាងលើនេះ សុទ្ធតែជាបទល្មើសឧក្រិដ្ឋដោយឡែក ដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តលើ។

## ផ្នែកទី ២៖ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

### ១. អត្ថន័យនៃធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុសត្យានុម័ត ឬធាតុសម្ភារៈ គឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តក្រោមរូបភាពជាសកម្មភ្កី ឬអកម្មភ្កីដែលមានចរិតគ្រោះថ្នាក់ដល់សង្គម។ ធាតុសត្យានុម័ត ឬធាតុសម្ភារៈនេះ ជាកត្តាមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ដោយហេតុថា ប្រសិនបើមនុស្សមិនប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់ទេនោះ វាក៏គ្មានលទ្ធផលអាក្រក់កើតឡើងដែរ។[50]

[48] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២១។

[49] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២២។

[50] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

អំពើរបស់មនុស្ស វាបញ្ជាក់អំពីឆន្ទៈ និងទិសដៅដែលជាសញ្ញាសម្គាល់មួយយ៉ាងសំខាន់របស់ធាតុសត្យានុម័ត ឬធាតុសម្ភារៈនេះ។ ដើម្បីសម្រេចនូវអំពើល្មើសរបស់ខ្លួន ជនល្មើសប្រើប្រាស់នូវរាល់គ្រប់មធ្យោបាយ ឧបករណ៍ កលល្បិច ប្រព្រឹត្តក្នុងស្ថានភាព និងពេលវេលាដែលគេយល់ឃើញថាអំណោយផលដល់ការប្រព្រឹត្តបទល្មើស។

## ២. ទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម ឬចំណងហេតុផល

ដើម្បីកំណត់ថាអំពើណាមួយជាបទល្មើស លុះត្រាតែមានអំពើស្តែងចេញមកខាងក្រៅដែលមានចរិតគ្រោះថ្នាក់ដល់សង្គម តាមរយៈអំពើជាសត្យានុម័ត។ ដូច្នេះ បើគ្មានអំពើនេះទេ គឺយើងមិនអាចកំណត់នូវអ្វីមួយដែលយើងគ្រាន់តែគិតក្នុងចិត្តនោះឡើយ។

**ឧទាហរណ៍៖** បុគ្គលម្នាក់ គ្រាន់តែគិតក្នុងចិត្តចង់ប្រព្រឹត្តអំពើណាមួយដែលក្រមព្រហ្មទណ្ឌបានចែងថាជាបទល្មើស។ ក្នុងករណីនេះ គេមិនអាចឱ្យជននោះទទួលខុសត្រូវព្រហ្មទណ្ឌ ឬដាក់ទណ្ឌកម្មទៅលើជននោះឡើយ។ ដូច្នេះ ទាល់តែមានអំពើជាសត្យានុម័ត ដែលធ្វើឡើងដោយបុគ្គលនោះ។ ប៉ុន្តែ អំពើនេះមិនត្រូវបានដាក់ទណ្ឌកម្មទេ ប្រសិនបើមិនមានព្យសនកម្ម (ការខូតខាត)។ ដូច្នេះ ទាល់តែមានព្យសនកម្ម ហើយព្យសនកម្មនេះស្តែងចេញពីអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ និងសន្តិសុខសង្គមជាដើម។ ម៉្យាងទៀត ត្រូវតែមានចំណងទាក់ទងរវាងការខូចខាតជាមួយនឹងអំពើ។ មានន័យថា ប្រសិនបើអំពើមួយផ្សេង ហើយការខូចខាតមួយកើតចេញផ្សេងក្រៅពីអំពើនោះ គឺយើងមិនអាចយកអំពើរបស់បុគ្គលម្នាក់ ដែលមិនបានធ្វើឱ្យមានការខូចខាតនោះ មកដាក់ទណ្ឌកម្ម ឬឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ហេតុដូច្នេះ ព្យសនកម្មត្រូវតែមានចំណងទំនាក់ទំនងជាមួយនឹងអំពើ គឺបញ្ជាក់ថាហេតុដែលកើតចេញមកនេះ វាត្រូវតែកើតចេញពីអំពើណាមួយ ឬផលដែលកើតចេញ ត្រូវកើតចេញពីអំពើណាមួយដែលប្រព្រឹត្តឡើងដោយបុគ្គលណាម្នាក់។[51] នៅក្នុងអំពើសត្យានុម័ត វាអាចកើតចេញនូវអំពើសកម្ម និងអំពើអកម្ម។

### ២.១ អំពើសកម្ម

អំពើសកម្ម គឺជាអំពើដែលស្តែងចេញពីសកម្មភាពនៃកាយវិការរបស់ចារី ដែលបានបំពានទៅលើការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌ។ អំពើដែលស្តែងចេញមកខាងក្រៅនេះ គឺបង្ហាញឱ្យឃើញពីអំពើរបស់ជនល្មើសផ្ទាល់ដែលអាចសន្និដ្ឋានបានថាជននោះបានប្រព្រឹត្តបទល្មើស ដែលបង្កគ្រោះថ្នាក់ដល់សង្គម។

**ឧទាហរណ៍៖** បទឃាតកម្ម ដោយជនល្មើសបានប្រើកាំភ្លើងបាញ់តម្រង់ទៅលើជនម្នាក់បណ្តាលឱ្យស្លាប់បាត់បង់ជីវិត។ នេះបង្ហាញនូវសកម្មភាពជាសត្យានុម័ត ដែលបញ្ជាក់ថាជននោះបានប្រព្រឹត្តអំពើល្មើសដោយសម្លាប់មនុស្សពិតប្រាកដមែន។ ក្នុងករណីនេះ ជនល្មើសត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

---

[51] ប្រសាសន៍របស់ឯកឧត្តម **ប៊ុន ហុន** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

### ២.២ អំពើអកម្ម

អំពើអកម្ម គឺជាអំពើមួយប្រភេទដែលជនណាម្នាក់មិនធ្វើទៅតាមការកំណត់ដែលជាកាតព្វកិច្ចរបស់ច្បាប់តម្រូវឱ្យធ្វើ។ អំពើនេះ គឺទាល់តែច្បាប់បានចែងជាក់លាក់ថាកាតព្វកិច្ចណាខ្លះដែលបុគ្គលនៅក្នុងសង្គម ឬបុគ្គលណាខ្លះត្រូវបំពេញ ហើយបើសិនជាមិនបានបំពេញតាមដែលច្បាប់បានកំណត់ទេ បុគ្គលនោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថា ត្រូវតែទទួលខុសត្រូវចំពោះអំពើដែលជាបទល្មើសនោះ។

**ឧទាហរណ៍៖** បទមិនប្ដឹងបរិហារការធ្វើបាបអនីតិជន ដែលមានចែងនៅក្នុងមាត្រា ៥៣០ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា រាល់បុគ្គលណាដែលបានដឹងពីការធ្វើបាប ឬបៀតបៀនខាងផ្លូវភេទលើអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ហើយមិនបានប្ដឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។ នេះគឺជាអំពើអកម្ម ដែលបញ្ជាក់ថាជនម្នាក់នោះបានដឹងថាមានការធ្វើបាបអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ រួចហើយ ប៉ុន្តែគាត់មិនបានប្ដឹងបរិហារអំពីអំពើនេះទៅអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរតុលាការទេ ក្នុងករណីនេះច្បាប់បានចែងថាបុគ្គលដែលបានដឹងត្រូវមានកាតព្វកិច្ចប្ដឹង បើមិនដូច្នោះទេ បុគ្គលនោះត្រូវមានទោសដាក់គុក ឬទោសពិន័យជាប្រាក់ទៅតាមបញ្ញត្តនៃមាត្រា ៥៣០ ខាងលើនេះ។[52]

## ផ្នែកទី ៣៖ ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

### ១. អត្ថន័យនៃធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

អំពើប្រព្រឹត្តមួយ ដែលគ្រាន់តែមានធាតុនីត្យានុកូល ឬធាតុច្បាប់ និងធាតុសត្យានុម័ត ឬធាតុសម្ភារៈនោះ វាមិនគ្រប់គ្រាន់ទេ គឺដាច់ខាតត្រូវតែមានធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រថែមទៀត បើពុំដូច្នោះទេ គេមិនអាចចាត់ទុកថាជាបទល្មើសបានឡើយ។

ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលស្ដែងមកខាងក្រៅតាមរយៈធាតុសត្យានុម័ត ឬធាតុសម្ភារៈ ដូចជាកាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។ គេអាចនិយាយម្យ៉ាងទៀតបានថា ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រនេះ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយនឹងធាតុសត្យានុម័ត ឬធាតុសម្ភារៈ។[53]

ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រនេះ ច្រើនតែសម្ដែងឡើងក្រោមរូបភាពជាកំហុស គោលបំណង និងកត្តាផ្សេងៗ ដែលជំរុញឱ្យប្រព្រឹត្តបទល្មើស។

[52] ប្រសាសន៍របស់ឯកឧត្តម **ប៊ុន ហុន** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[53] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

## ២. កំហុសព្រហ្មទណ្ឌ

កំហុស គឺជាអាកប្បកិរិយារបស់មនុស្សម្នាក់ ដែលបានប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយមានផលវិបាកកើតឡើង។ ផលវិបាកនេះ បង្កឡើងដោយៈ

- ➢ កំហុសដោយចេតនា និង
- ➢ កំហុសដោយអចេតនា។

### ២.១ កំហុសដោយចេតនា

កំហុសដោយចេតនា គឺជាកំហុសរបស់បុគ្គលម្នាក់ ដែលនៅពេលប្រព្រឹត្តបទល្មើស បុគ្គលនោះបានដឹងយ៉ាងច្បាស់ថាអំពើរបស់ខ្លួនជាអំពើដែលច្បាប់ហាមឃាត់ ហើយអំពើនោះនឹងបង្កចរិតគ្រោះថ្នាក់ដល់សង្គម និងចង់ឱ្យផលវិបាកនៃអំពើនោះកើតឡើងជាក់ស្តែងតែម្តង។

**ឧទាហរណ៍៖** បុគ្គល **ក** បានសម្លាប់បុគ្គល **ខ** ដោយចេតនា។ ក្នុងករណីនេះ ធាតុផ្សំអត្តនោម័តគឺ បុគ្គល **ក** ដែលជាចារីបានយល់ច្បាស់ថាអំពើរបស់ខ្លួនជាអំពើខុសច្បាប់ ប៉ុន្តែគាត់នៅតែមានបំណងប្រព្រឹត្ត ដែលជាហេតុបណ្តាលឱ្យបុគ្គល **ខ** ដែលជាជនរងគ្រោះស្លាប់បាត់បង់ជីវិតទៅ។

#### ២.១.១ ប្រភេទនៃចេតនាប្រព្រឹត្តបទល្មើស ឬចេតនាទុច្ចរិត

**ក. ចេតនាទុច្ចរិតទូទៅ**

ចេតនាទុច្ចរិតទូទៅ គឺជាចេតនារបស់ចារីក្នុងការប្រព្រឹត្តអំពើដែលខ្លួនបានដឹងថាច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ មានន័យថា ចារីប្រព្រឹត្តអំពើល្មើស ក្នុងចេតនាបំពានច្បាប់ ឬបំពានទៅលើការហាមឃាត់ផ្នែកព្រហ្មទណ្ឌ។

**ឧទាហរណ៍៖** ការប្រើហិង្សាដោយចេតនារបស់ចារីទៅលើជនរងគ្រោះ ដែលជាបទហិង្សា និងមានចែងនៅក្នុងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

**ខ. ចេតនាទុច្ចរិតពិសេស**

នៅក្នុងករណីចេតនាទុច្ចរិតពិសេស ជនល្មើសមានចេតនាចង់ឱ្យបទល្មើសដែលខ្លួនប្រព្រឹត្តនោះ ផ្តល់ផលពិសេស។ ចេតនាទុច្ចរិតពិសេសនេះ អាចកើតចេញមកពីអំពើមួយទៀត ដែលជនល្មើសបានគ្រោងទុកជាមុន។

**ឧទាហរណ៍៖** ការផ្សាយពត៌មានមិនពិត ឬពត៌មានក្លែងក្លាយក្នុងគោលបំណងបំផ្លិចបំផ្លាញកិត្តិយសជនរងគ្រោះ។[54]

**គ. ចេតនាទុច្ចរិតធ្ងន់ធ្ងរ**

ចេតនាទុច្ចរិតធ្ងន់ធ្ងរ សំដៅទៅលើចេតនារបស់ចារីប្រព្រឹត្តបទល្មើស ដែលមានចេតនាបង្កនូវគ្រោះថ្នាក់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ។

[54] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

**ឧទាហរណ៍៖** ការគិតទុកជាមុន បានស្តែងឱ្យឃើញនូវចេតនាទុច្ចរិតធ្ងន់ធ្ងរមួយ។ យោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ បានឱ្យនិយមន័យថា ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ក្នុងករណីឃាតកម្មធ្វើឡើងដោយមានការគិតទុកជាមុន ជនដែលប្រព្រឹត្តត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[55] ដូច្នេះ អំពើដែលមានចរិតលក្ខណៈធ្ងន់ធ្ងរ នឹងត្រូវទទួលទោសតាមច្បាប់ក៏ធ្ងន់ធ្ងរដែរ។

**ឃ. ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់**

- **ចេតនាទុច្ចរិតច្បាស់លាស់** គឺជាចេតនារបស់ចារីប្រព្រឹត្តបទល្មើស ដែលគោលបំណងរបស់ចារីប្រព្រឹត្តនោះ មានលក្ខណៈដូចគ្នាទៅនឹងលទ្ធផលនៃអំពើ។

**ឧទាហរណ៍៖** នៅពេលដែលចារីចង់សម្លាប់លោក **ក** ចារីបានធ្វើឱ្យលោក **ក** ទទួលមរណភាពដោយស្នាដៃរបស់ខ្លួនផ្ទាល់។ ដូច្នេះ ចារីពិតជាមានចេតនាទុច្ចរិតច្បាស់លាស់ពិតប្រាកដមែន។

- **ចេតនាទុច្ចរិតមិនច្បាស់លាស់** សំដៅទៅលើអំពើប្រព្រឹត្តរបស់ចារី ដែលមានបំណងបង្កព្យសនកម្ម ក៏ប៉ុន្តែចារីពុំបានដឹងច្បាស់ថាលទ្ធផលដែលកើតចេញពីបទល្មើសនោះ មានលក្ខណៈបែបណាទេ។

**ឧទាហរណ៍៖** ចារីបានយកដុំថ្មគប់ទៅលើជនរងគ្រោះ ប៉ុន្តែគាត់មិនដឹងថាតើការគប់នោះ បានបង្កព្យសកម្មទៅលើជនរងគ្រោះបែបណានោះទេ។ ឧបមាថា ចេតនារបស់ចារីគ្រាន់តែចង់ឱ្យជនរងគ្រោះទទួលរងនូវរបួសស្នាមបន្តិចបន្តួចតែប៉ុណ្ណោះ ក៏ប៉ុន្តែជនរងគ្រោះបែរជាស្លាប់បាត់បង់ជីវិតទៅវិញ។ ក្នុងករណីនេះ ចារីត្រូវតែទទួលនូវការផ្តន្ទាទោសតាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ចែងអំពីបទហិង្សាដោយមានស្ថានទម្ងន់ទោសដោយសារមរណភាពរបស់ជនរងគ្រោះ។

**ង. ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ**

- **ចេតនាទុច្ចរិតចំពោះ** គឺជាកំហុសរបស់បុគ្គលម្នាក់ ដោយសារក្នុងពេលប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ជននោះបានដឹងយ៉ាងច្បាស់ថាអំពើរបស់ខ្លួនមានចរិតគ្រោះថ្នាក់ ហើយមើលឃើញច្បាស់ពិតប្រាកដនូវ**បច្ច័យ** គ្រោះថ្នាក់នៃអំពើរបស់ខ្លួន ហើយចារីនៅតែចង់ឱ្យបច្ច័យនោះកើតឡើងទៀត។

**ឧទាហរណ៍៖** ចារីបានវាយរថយន្តរបស់ជនរងគ្រោះឱ្យខូចខាត ដោយសារតែចារីមានទំនាស់ពាក្យសម្តីជាមួយនឹងម្ចាស់រថយន្ត។ ក្នុងករណីនេះ ចារីមានចេតនាទុច្ចរិតចំពោះ។

- **ចេតនាទុច្ចរិតមិនចំពោះ** គឺជាកំហុសរបស់ជនម្នាក់ ដែលពេលប្រព្រឹត្តបទល្មើស ជននោះបានយល់ដឹងពីចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួនដែរ តែខ្លួនពុំបានប៉ងប្រាថ្នាឱ្យបច្ច័យនោះកើតឡើងនោះទេ ប៉ុន្តែអំពើនោះបានធ្វើឱ្យបច្ច័យណាមួយកើតឡើងទៅវិញ។

**ឧទាហរណ៍៖** បុរស **ក** បានកាន់ជំពាមមួយដើម ដើម្បីយកទៅបាញ់ចាប ក្នុងពេលដែលបាញ់នោះ ជំពាមក៏បានភ្លាត់បែរជាបាញ់ចំជនរងគ្រោះបែកក្បាល។ អំពើរបស់ចារីខាងលើ បានដឹងថាការបាញ់របស់ខ្លួនអាចនឹងមានចរិត

[55] សាស្ត្រាចារ្យ **នុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ ២០១២។

គ្រោះថ្នាក់ ឬបង្កព្យសនកម្មដល់អ្នកដទៃបាន ប៉ុន្តែគោលបំណងរបស់ចារីគឺចង់បាញ់ចាបតែប៉ុណ្ណោះ។ ក្នុងករណីនេះ ចារីនៅតែទទួលទោសចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថាខ្លួនបាន បង្ករបួលស្នាមដោយអចេតនាទៅលើជនរងគ្រោះ។

**២.២ កំហុសដោយអចេតនា**

កំហុសដោយអចេតនា គឺសំដៅទៅលើអំពើប្រព្រឹត្តរបស់ចារី ដែលបានប្រព្រឹត្តឡើងដោយសារការខ្វះការប្រុង ប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកដែលច្បាប់បានកំណត់ ហើយក៏ត្រូវទទួលនូវ ការផ្តន្ទាទោសផងដែរ។

យោងតាមក្រមព្រហ្មទណ្ឌមាត្រា ៤ បានចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែ ក្នុង ករណីដែលច្បាប់ចែងទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការ មិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។

សម្រាប់បទល្មើសអចេតនានេះ ធាតុផ្សំអត្តនោម័តគឺសំដៅទៅលើកំហុសអចេតនាដែលពុំមែនជាចេតនា ប្រព្រឹត្តបទល្មើសទេ តែចារីបានប្រព្រឹត្តខុសទៅនឹងវិធានណាមួយដែលគ្រប់គ្រងបង្កើតបានជាបទល្មើស។ កំហុស អចេតនា គឺសំដៅទៅលើ៖

**ក. ការមិនប្រុងប្រយ័ត្ន**

សំដៅទៅលើអំពើទាំងឡាយណា ដែលបណ្តាលមកពីការខ្វះការប្រុងប្រៀបស្មារតីក្នុងការធ្វើសកម្មភាពណា មួយ។

**ឧទាហរណ៍៖** ការបើកបរយានយន្តដែលគិតតែរវើរវាយរឿងផ្សេង ដោយមិនបានផ្តោតអារម្មណ៍លើការបើកបរ គឺជាការខ្វះការប្រុងប្រយ័ត្ន។

**ខ. ការខ្ជីខ្ជា**

សំដៅទៅលើការមិនយកចិត្តទុកដាក់ ឬការធ្វើអ្វីមួយមិនម៉ត់ចត់។

**ឧទាហរណ៍៖** កម្មករម្នាក់បានឡើងជណ្តើរ ដោយកាន់ពូថៅនៅនឹងដៃជាមួយផង ដោយសារតែមិនបានកាន់ ពូថៅនោះឱ្យបានជាប់ ទើបធ្វើឱ្យពូថៅនោះជ្រុះពីដៃធ្លាក់តាមជណ្តើរ ហើយបណ្តាលឱ្យអ្នកថ្មើរជើងម្នាក់ដែលកំពុងដើរ នៅខាងក្រោមស្លាប់បាត់បង់ជីវិត។

**គ. ការធ្វេសប្រហែស**

សំដៅទៅលើការភ្លេចភ្លាំង ឬការបណ្តែតបណ្តោយក្នុងការធ្វើអ្វីមួយ។

**ឧទាហរណ៍៖** ការតាំងដើមផ្កានៅលើផ្ទះ ដោយមិនបានចងលួសឱ្យបានត្រឹមត្រូវ នៅពេលដែលមានខ្យល់ បោកបក់ក៏ធ្លាក់មកលើមនុស្សម្នានៅខាងក្រោម។

**ឃ. ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ**

សំដៅទៅលើការមិនប្រតិបត្តិកាតព្វកិច្ចដែលច្បាប់ ឬបទដ្ឋានគតិយុត្តតម្រូវឱ្យមាន។

**ឧទាហរណ៍៖** ការប្រើប្រាស់ទូរស័ព្ទដៃនៅពេលកំពុងបើកបរ ដែលមានចែងនៅក្នុងមាត្រា ៨ ចំណុចទី ៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

## ២.៣ ការវាយតម្លៃអំពីកំហុសចេតនា និងកំហុសអចេតនា

ដើម្បីអាចវាយតម្លៃថា អំពើណាមួយជាអំពើប្រព្រឹត្តដោយចេតនា ឬដោយអចេតនានោះ យើងអាចកំណត់អំពើទាំងនោះតាមរយៈប្រភេទនៃបទល្មើសនីមួយៗ។

**ក. បទឧក្រិដ្ឋ**

ចំពោះបទឧក្រិដ្ឋ ជាបទល្មើសដែលប្រព្រឹត្តដោយចេតនា។ មានន័យថា នៅក្នុងករណីដែលចារីបានប្រព្រឹត្តបទល្មើសដែលជាបទឧក្រិដ្ឋនោះ គេចាត់ទុកថាចារីមានចេតនាពិតប្រាកដ ក្នុងការបង្កនូវព្យសនកម្មដល់សង្គម និងបានដឹងយ៉ាងច្បាស់ថាអំពើរបស់ខ្លួនជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់។

**ឧទាហរណ៍៖** បុរស **ក** បានចាប់រំលោភនារី **ខ** នៅកន្លែងស្ងាត់មួយបានសម្រេច។ ក្រមព្រហ្មទណ្ឌមាត្រា ២៣៩ បានកំណត់អំពីនិយមន័យ និងទោសចំពោះបុគ្គលដែលបានប្រព្រឹត្តបទរំលោភសេពសន្ថវៈនេះ ដោយផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។ អំពើ ដែលជាបទរំលោភសេពសន្ថវៈខាងលើនេះ ច្បាប់ចាត់ទុកថា ជាបទល្មើសឧក្រិដ្ឋ។[56] ចំពោះធាតុផ្សំអត្តនោម័តវិញ គឺចារីមានចេតនាយ៉ាងពេញលេញ ក្នុងការប្រព្រឹត្តអំពើរបស់ខ្លួនទៅលើជនរងគ្រោះ ដើម្បីសម្រេចបំណងរបស់ចារីនោះគឺ ការរួមភេទ។

**ខ. បទលហុ**

ចំពោះបទលហុគឺផ្ទុយទៅនឹងបទឧក្រិដ្ឋ មានន័យថា បទលហុជាបទល្មើសដែលប្រព្រឹត្តដោយអចេតនា លើកលែងតែច្បាប់ចែងថាជាអំពើប្រព្រឹត្តដោយចេតនា។

**ឧទាហរណ៍៖** បទបរិហារកេរ្តិ៍ជាសាធារណៈ គឺជាបទលហុដែលច្បាប់បានចែងផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។[57] គ្រប់អំពើអះអាងបំផ្លើស ឬទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺគេចាត់ទុកថាជាអំពើប្រព្រឹត្តដោយចេតនាយ៉ាងពិតប្រាកដ ព្រោះថាចារីមានបំណងចងឱ្យលទ្ធផលនៃអំពើរបស់ខ្លួនកើតឡើងដោយធ្វើឱ្យខូចឈ្មោះ ឬកិត្តិយសរបស់ជនរងគ្រោះ។

**គ. បទមជ្ឈិម**

ចំណែកឯបទមជ្ឈិមវិញ ជាបទល្មើសប្រព្រឹត្តដោយចេតនា លើកលែងតែច្បាប់ចែងច្បាស់លាស់ផ្ទុយពីនេះ។ មានន័យថា ក្នុងករណីដែលបទល្មើសជាបទមជ្ឈិម ច្បាប់ក៏បានកំណត់ថាជាអំពើប្រព្រឹត្តដោយចេតនារបស់ជនល្មើស

[56] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៦។

[57] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ និងមត្រា ៣០៥។

ដូចទៅនឹងបទឧក្រិដ្ឋដែរ ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ថាអំពើនោះជាអំពើប្រព្រឹត្តដោយអចេតនា ជនល្មើសដែលប្រព្រឹត្តអំពើដោយអចេតនា ត្រូវទទួលទោសតាមបញ្ញត្តច្បាប់ដែលបានកំណត់ចំពោះបទល្មើសដែលប្រព្រឹត្តដោយអចេតនានោះ។

**ឧទាហរណ៍៖** បទហិង្សាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ២១៧ បានឱ្យនិយមន័យថា អំពើហិង្សាដែលប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។ ច្បាប់កំណត់ថា ជាបទមជ្ឈិម។ ផ្ទុយទៅវិញ បើសិនជាអំពើរបស់ចារីប្រព្រឹត្តដោយអចេតនា ច្បាប់បានកំណត់ថាជាបទល្មើសបង្ករបួសស្នាមដោយអចេតនា និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល តាមបញ្ញត្តនៃមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌប៉ុណ្ណោះ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និង

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

# ជំពូកទី ៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

## ផ្នែកទី ១៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការទទួលរងនូវទណ្ឌកម្មចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។[58] ម្យ៉ាងវិញទៀត គេអាចនិយាយបានថា ការទទួលខុសត្រូវព្រហ្មទណ្ឌជាកាតព្វកិច្ចដើម្បីឆ្លើយតបទៅនឹងអំពើប្រព្រឹត្តនៃបទល្មើស។[59] នេះគឺជាគោលការណ៍មួយដែលយើង កំណត់ពាក់ព័ន្ធជាមួយការទទួលខុសត្រូវព្រហ្មទណ្ឌ ។

យោងតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ បានកំណត់អំពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។ នៅក្នុងគោលការណ៍នេះ គឺសំដៅទៅលើបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួន ដែលខ្លួនបានប្រព្រឹត្ត មានន័យថា បុគ្គលណាប្រព្រឹត្តអំពើណាមួយដែលជាបទល្មើស បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមិនអាចទម្លាក់អំពើដែលខ្លួនធ្វើនោះ ទៅឱ្យអ្នកផ្សេងទៀតទទួលខុសត្រូវជំនួសបានទេ ពីព្រោះថា គោលការណ៍នេះជាគោលការណ៍មួយ ដែលធ្វើយ៉ាងណាឱ្យទាក់ទងជាមួយនឹងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌទៅលើបុគ្គលដែលប្រព្រឹត្តអំពើល្មើសព្រោះថា គោលដៅនៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ គឺដើម្បីធ្វើការកែប្រែបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសនឹងច្បាប់នោះ ឱ្យពួកគាត់ធ្វើសមាហរណកម្មមករួមរស់ក្នុងសង្គមវិញ។ ការទទួលខុសត្រូវព្រហ្មទណ្ឌចែកចេញជាពីរ គឺ៖

### ១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

រូបវន្តបុគ្គល គឺជាបុគ្គលដែលមានរូបពិតៗ ឬជាមនុស្សពិតៗ។ ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ត្រូវបានចែកចេញជាពីរ គឺ៖

- រូបវន្តបុគ្គលជានីតិជន និង
- រូបវន្តបុគ្គលជាអនីតិជន។

#### ១.១ រូបវន្តបុគ្គលជានីតិជន

នីតិជន សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។[60] បុគ្គលនេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញតែម្តង ពីព្រោះថា នៅក្នុងក្រមព្រហ្មទណ្ឌគឺបានចែងនៅក្នុងមាត្រា ៣៨ អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ដូច្នេះចំណុចនេះមានន័យថា ជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ហើយបានប្រព្រឹត្តបទល្មើសណាមួយ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងពេញលេញចំពោះអំពើល្មើសរបស់ខ្លួន។

---

[58] ប្រសាសន៍របស់ឯកឧត្តម **ប៊ុន ហុន** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[59] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

[60] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, លេខរៀង ៧០។

### ១.២ រូបទន្តបុគ្គលជាអនីតិជន

អនីតិជន សំដៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[61] ការទទួលខុសត្រូវរបស់អនីតិជន មានពីរប្រភេទ គឺៈ

**ក. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ទៅដល់ក្រោម ១៨ ឆ្នាំ**

អនីតិជនប្រភេទនេះ នៅពេលដែលបានប្រព្រឹត្តបទល្មើស គឺបុគ្គលនេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ តុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធទៅជាមួយនឹងកាលៈទេសៈនៃបទល្មើសដែលគាត់ប្រព្រឹត្ត និងបុគ្គលិកលក្ខណៈរបស់បុគ្គលនេះ។ ដោយហេតុថា អនីតិជនដែលប្រព្រឹត្តបទល្មើស វិធានការនៅក្នុងការដាក់ទណ្ឌកម្មសម្រាប់អនីតិជនប្រភេទនេះ គឺក្នុងគោលដៅធ្វើការតាមដាន អប់រំ ការពារ ឬការឧបត្ថម្ភផ្សេងៗដល់គាត់។[62] ប្រភេទនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ មានដូចតទៅៈ

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។

ដូច្នេះ ទាក់ទងជាមួយនឹងការទទួលខុសត្រូវរបស់អនីតិជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ទៅដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែស្ថានភាពដែលថាទទួលឱ្យដូចនីតិជនតែម្ដងគឺមិនដូចទេ ព្រោះមានកម្រិតស្រាលជាង។

**ខ. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ**

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំនេះ គឺច្បាប់បានកំណត់ថាមិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ មានន័យថា នៅពេលដែលបុគ្គលដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ បុគ្គលនោះមិនអាចត្រូវបានដាក់ទោសព្រហ្មទណ្ឌទៅលើរូបគាត់បានឡើយ ។

---

[61] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, លេខរៀង ១៨៧។

[62] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩។

## ២. ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គល សំដៅលើក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។[63] ការទទួលខុសត្រូវរបស់នីតិបុគ្គល ត្រូវបានបែងចែកជាពីរ គឺៈ

- នីតិបុគ្គលជារដ្ឋ និង
- នីតិបុគ្គលមិនមែនរដ្ឋ។

### ២.១ នីតិបុគ្គលជារដ្ឋ

ចំពោះបញ្ហាទាក់ទងទៅនឹង**រដ្ឋ** គឺក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានកំណត់យ៉ាងជាក់លាក់ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលថា នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។[64] ដូច្នេះ រដ្ឋគឺជានីតិបុគ្គលមួយដែលច្បាប់មិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ពីព្រោះថា ច្បាប់ព្រហ្មទណ្ឌនៅក្នុងទោសបន្ថែម គឺអាចរំលាយនីតិបុគ្គលមួយចោលបាន។ ដូចនេះ ប្រសិនបើជាឱ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឬប្រទេសមួយចោលបាន ដូចជា ប្រទេសកម្ពុជាយើងជាដើម ពេលនោះ វានឹងប៉ះពាល់ដល់អធិបតេយ្យជាតិយើង ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខានឡើយ។

ចំណែកឯនៅក្នុងមូលទោសវិញនោះ គឺមានទោសមួយប្រភេទហៅថាទោសពិន័យជាប្រាក់ ហើយរាល់ទោសពិន័យជាប្រាក់ សុទ្ធតែត្រូវបង់ចូលថវិការដ្ឋ។[65] ហេតុដូច្នេះហើយ បានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

### ២.២ នីតិបុគ្គលមិនមែនរដ្ឋ

ចំពោះនីតិបុគ្គលមិនមែនរដ្ឋ ឬនីតិបុគ្គលឯកជនវិញ ដើម្បីអាចទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែចូលទៅក្នុងលក្ខខណ្ឌ ដែលនីតិបុគ្គលនេះបានប្រព្រឹត្តបទល្មើសណាមួយ ដោយធ្វើតាមរយៈតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។[66]

**ឧទាហរណ៍៖** ក្រុមហ៊ុនមួយបង្កើតឡើងដែលមានភ្នាក់ងាររបស់គាត់ ឬមួយក៏តំណាងរបស់គាត់ បានទៅធ្វើសកម្មភាពដើម្បីជាប្រយោជន៍ ដូចជា ទៅប្រើប្រាស់នូវគ្រប់មធ្យោបាយនានា រៀបចំដើម្បីធ្វើឱ្យសាធារណៈជនយល់ច្រលំ រួចក៏បង់នូវប្រាក់កាក់ ឬ ទ្រព្យសម្បត្តិផ្សេងៗដែលគាត់យកមកបាន ធ្វើជាប្រយោជន៍សម្រាប់នីតិបុគ្គល។ ដូច្នេះ យើងកំណត់ថាគាត់បានធ្វើអំពើឆបោកដល់សាធារណៈជន អំពើដែលធ្វើឡើងបែបនេះគឺមានន័យថា នីតិបុគ្គលបាន

[63] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, លេខរៀង ៧១។

[64] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤២។

[65] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥២។

[66] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៨ និង មាត្រា ៤២។

ប្រព្រឹត្តបទល្មើស។ ប៉ុន្តែ ដើម្បីឱ្យនីតិបុគ្គលនេះអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ទាល់តែមានច្បាប់ ឬ បទដ្ឋានគតិយុត្តចែងជាក់លាក់ថានីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

ផ្ទុយទៅវិញ ប្រសិនជាមិនមានចែងទេ គឺថាយើងមិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ហើយត្រូវចាំថាមិនមែនអំពើទាំងអស់ដែលធ្វើឡើងមកនោះ គឺសុទ្ធតែឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ដូច្នេះ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺបានចែងនូវបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់នីតិបុគ្គលចំពោះបទល្មើសនីមួយៗនោះ នៅក្នុងច្បាប់យ៉ាងជាក់លាក់តែម្តង ។

## ៣. ឋានៈបុគ្គលដែលចូលរួមនៅក្នុងការប្រព្រឹត្តបទល្មើស

ចំពោះបុគ្គលដែលអាចចូលរួមក្នុងការប្រព្រឹត្តបទល្មើស យើងអាចសង្កេតឃើញថា នៅក្នុងការប្រព្រឹត្តបទល្មើស មានស្ថានភាពខ្លះបុគ្គលម្នាក់អាចនឹងប្រព្រឹត្តដោយខ្លួនឯងផ្ទាល់ ឬដោយគ្មានការទាក់ទងជាមួយបុគ្គលដទៃទៀត។ ប៉ុន្តែ មានបទល្មើសខ្លះទៀតគឺ នៅក្នុងការប្រព្រឹត្តបទល្មើសនោះ មានការចូលរួមពីសំណាក់បុគ្គលដទៃផ្សេងទៀត ដែលអាចជាបុគ្គលដែលចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬដោយប្រយោល។ ចំពោះលក្ខខណ្ឌដែលអាចចាត់ទុកថាជាជនល្មើសបាន លុះត្រាតែៈ

- ជាមនុស្ស
- កំពុងមានជីវិតរស់នៅ
- មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ និង
- មានអាយុតាមការកំណត់របស់នីតិព្រហ្មទណ្ឌ។[67]

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ក៏បានកំណត់អំពីបុគ្គលដែលអាចជាជនល្មើស ឬជាបុគ្គលដែលចូលរួមក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជា ៤ (បួន) ប្រភេទសំខាន់ៗ គឺៈ

### ក. ចារី

ចារី សំដៅលើជនដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ និងត្រូវបានទទួលរងនូវការចោទប្រកាន់ចំពោះអំពើរបស់ខ្លួន មានន័យថា អំពើរបស់ចារីមានលក្ខណៈធាតុផ្សំបទល្មើសគ្រប់គ្រាន់។[68] ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម។ ក្នុងន័យនេះ ចំពោះចារីនៃការប៉ុនប៉ង នឹងត្រូវទទួលខុសត្រូវដូចទៅនឹងចារីនៃបទល្មើសសម្រេចផងដែរ ប៉ុន្តែ ចារីនៃការប៉ុនប៉ង មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទមជ្ឈិមទេ ក្នុងករណីដែលច្បាប់គ្មានចែង។

**ឧទាហរណ៍ៈ** លោក **ក** បានបាញ់សម្លាប់នារី **ខ** ដែលជាជនរងគ្រោះបណ្តាលឱ្យស្លាប់ ដូច្នេះលោក **ក** ត្រូវបានចាត់ទុកថាជាចារី។

---

[67] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

[68] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៥។

ក៏ប៉ុន្តែនៅក្នុងស្ថានភាពខ្លះ បទល្មើសប្រព្រឹត្តដោយមានបុគ្គលច្រើនរូប បានន័យថា អ្នកខ្លះចូលរួមក្នុងឋានៈជាសហចារី អ្នកខ្លះចូលរួមក្នុងឋានៈជាអ្នកផ្ដើមគំនិត និងអ្នកខ្លះទៀតចូលរួមក្នុងឋានៈជាអ្នកសមគំនិត ។

**ខ. សហចារី**

សហចារី គឺជាជនដែលបានចូលរួមប្រព្រឹត្តបទល្មើសរួមគ្នា ដោយបានព្រមព្រៀងគ្នា ហើយបុគ្គលទាំងនោះបានប្រព្រឹត្តបទល្មើសដោយផ្ទាល់។[69] ត្រូវបានចាត់ទុកជាសហចារីផងដែរ ចំពោះបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុកជាមុន។ មានន័យថា ក្នុងករណីដែលច្បាប់បានចែងទុកមុន ចំពោះអំពើប៉ុនប៉ងដែលបុគ្គលច្រើននាក់បានព្រមព្រៀងប្រព្រឹត្តបទល្មើស នឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចនឹងបទល្មើសបានសម្រេចដែរ។

**ឧទាហរណ៍៖** ជនល្មើសមានគ្នាបីនាក់គឺ ឈ្មោះ **ក ខ** និង **គ** បានវាយទៅលើជនរងគ្រោះឈ្មោះ **ឃ** បណ្ដាលឱ្យរងរបួសបែកក្បាលយ៉ាងដំណំនៅនឹងកន្លែងកើតហេតុ។ ក្នុងចំណោមអ្នកទាំងបីនោះ មានម្នាក់បានយកដំបងវាយទៅលើជនរងគ្រោះ បណ្ដាលឱ្យបែកក្បាល។ ក្នុងករណីនេះ អ្នកទាំងបីត្រូវបានគេចោទប្រកាន់ពីបទហិង្សា ដោយកំណត់ថាជនទាំងបីនេះជាសហចារី ប៉ុន្តែមិនមានន័យថាការទទួលនូវទោសដូចគ្នានោះទេ នេះបើតាមគោលការណ៍ឯកត្តកម្មនៃទោស។[70]

**គ. អ្នកផ្ដើមគំនិត**

អ្នកផ្ដើមគំនិត គឺសំដៅលើជនទាំងឡាយណាដែលបានផ្ដើមគំនិតក្នុងការប្រព្រឹត្តបទល្មើស តាមរយៈ ការជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម តាមការណែនាំ ឬការបញ្ជា។[71] មិនតែប៉ុណ្ណោះ ត្រូវបានចាត់ទុកជាអ្នកផ្ដើមគំនិតផងដែរ ចំពោះបុគ្គលណាដែលបង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ ម្យ៉ាងវិញទៀត អ្នកផ្ដើមគំនិតនេះអាចត្រូវបានគេហៅថាជាចារីបញ្ញាផងដែរ ព្រោះថាជននេះ ជាមេគំនិតក្នុងការប្រព្រឹត្តបទល្មើស។ អ្នកផ្ដើមគំនិតនេះនឹងត្រូវទទួលទោសដូចគ្នាទៅនឹងចារីដែរ ក្នុងករណីដែលបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។

**ឧទាហរណ៍៖** លោក **ក** បានបញ្ជាឱ្យលោក **ខ** ទៅសម្លាប់លោក **គ** ដោយសន្យាថា បន្ទាប់ពីសម្រេចកិច្ចការហើយ ខ្លួននឹងប្រគល់លុយមួយចំនួនដើម្បីជាថ្នូរ។ ក្នុងករណីនេះ លោក **ខ** ត្រូវបានគេចាត់ទុកថាជាចារី ដោយហេតុថាលោក **ខ** ជាជនដៃដល់ ឬជាអ្នកប្រព្រឹត្តបទល្មើសដោយផ្ទាល់។ ចំណែកឯលោក **ក** វិញ ត្រូវបានចាត់ទុកថាជាអ្នកផ្ដើមគំនិត ព្រោះថា បើគ្មានគំនិតផ្ដួចផ្ដើមពីលោក **ក** ទេ លោក **ខ** ក៏មិនទៅសម្លាប់លោក **គ** ដែលជាជនរងគ្រោះដែរ។

[69] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៦។

[70] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦។

[71] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៨។

**ឃ. អ្នកសមគំនិត**

អ្នកសមគំនិត សំដៅដល់បុគ្គលដែលបានជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយផ្តល់នូវជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន មានន័យថា អ្នកសមគំនិត ជាជនដែលផ្តល់ជាមធ្យោបាយតាមរយៈណាក៏ដោយ ដើម្បីសម្រួលដល់ការប្រព្រឹត្តបទល្មើសអនុវត្តទៅដោយរលូន។[72]

**ឧទាហរណ៍៖** នៅក្នុងបទល្មើសលួចមួយមានបុគ្គលពីរនាក់ មានឈ្មោះ **ច** និង **ឆ** បានធ្វើសកម្មភាពលួចម៉ូតូរបស់លោក **ញ** ដែលបានចតនៅមុខផ្ទះ ដោយម្នាក់ឈ្មោះ **ឆ** ជាអ្នកឃ្លាំមើលស្ថានភាពជុំវិញ(ផ្លូវ) ដើម្បីឱ្យឈ្មោះ **ច** ធ្វើសកម្មភាពលួចម៉ូតូ ក្នុងកំឡុងពេលដែលគ្មានមនុស្សឆ្លងកាត់នៅទីនោះ។

ក្នុងករណីនេះ ឈ្មោះ **ឆ** នឹងត្រូវបានចាត់ទុកជាអ្នកសមគំនិត ព្រោះថាសកម្មភាពបែបនេះ ជាអំពើដែលជួយសម្រួលឱ្យការប្រព្រឹត្តបទល្មើសបានសម្រេចប៉ុណ្ណោះ។ យ៉ាងណាមិញ ឈ្មោះ **ច** គឺនៅតែជាចារីដដែល ដោយហេតុថាខ្លួនបានធ្វើសកម្មភាពលួចម៉ូតូរបស់លោក **ញ** ដោយផ្ទាល់។

**៤. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស**

ជាទូទៅ បទល្មើសនីមួយៗតែងតែលេចឡើងនូវស្ថានភាពក្នុងការប្រព្រឹត្ត ដែលស្ថានភាពនៃការប្រព្រឹត្តបទល្មើសទាំងនោះ ត្រូវបានចែកចេញជា ៤ (បួន) ដំណាក់កាលធំៗ ដូចតទៅ៖

- ដំណាក់កាលទី ១ គឺជាដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស
- ដំណាក់កាលទី ២ គឺជាដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស
- ដំណាក់កាលទី ៣ គឺជាដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស
- ដំណាក់កាលទី ៤ គឺជាដំណាក់កាលនៃការសម្រេចនូវបទល្មើស ឬបើបទល្មើសមិនបានសម្រេចក្លាយទៅជាការប៉ុនប៉ង (បទល្មើសប៉ុនប៉ង) ។

គួរបញ្ជាក់ផងដែរថា នៅក្នុងដំណាក់កាលទាំង ៤ (បួន) ខាងលើនេះ ច្បាប់មិនមែនផ្តន្ទាទោសនៅគ្រប់ដំណាក់កាលទាំងអស់នោះទេ។[73] ដូច្នេះ ដើម្បីយល់អំពីបញ្ហាទាំងនេះ យើងធ្វើការបកស្រាយឱ្យបានលម្អិតអំពីដំណាក់កាលនីមួយៗនៃការប្រព្រឹត្តបទល្មើស។

**ក. ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស**

នៅក្នុងដំណាក់កាលដំបូងនេះ ច្បាប់ព្រហ្មទណ្ឌមិនបានផ្តន្ទាទោសទេ ដោយហេតុថា មនុស្សម្នាក់ៗមានសិទ្ធិរបស់ខ្លួនក្នុងការគិតពិចារណា ទោះបីជាការគិតនោះស្តែងឡើងក្នុងន័យប្រព្រឹត្តបទល្មើស ដោយមានគំនិតទុច្ចរិត និង

[72] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៩។

[73] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

បានគិតអំពីស្ថានភាពថាប្រព្រឹត្តបទល្មើសក៏ដោយ។ មានន័យថា ជាទូទៅលុះត្រាតែមានបទល្មើសស្តែងចេញជារូបរាងមកខាងក្រៅ ហើយបង្កឱ្យមានព្យសនកម្ម ឬក៏មានគ្រោះថ្នាក់ដល់សង្គម ទើបអាចត្រូវផ្តន្ទាទោស។

**ឧទាហរណ៍៖** នៅក្នុងកម្មវិធីជប់លៀងមួយកន្លែង បុគ្គល **ក** មានជម្លោះពាក្យសម្តីជាមួយបុគ្គល **ខ**។ ក្នុងកំឡុងពេលនោះ បុគ្គល **ក** បានដើរចេញពីកន្លែងនោះទៅផ្ទះវិញទាំងកំហឹង ព្រោះថាបុគ្គល **ក** មានគ្នាតែពីរនាក់ ចំណែកឯបុគ្គល **ខ** មានគ្នាច្រើននាក់ ដោយពួកគេបានវាយទៅលើគ្នីគ្នារបស់បុគ្គល **ក**។ នៅពេលដែលបុគ្គល **ក** បានមកដល់ផ្ទះវិញ គាត់ក៏បានគិតថាតើគាត់ត្រូវរកវិធីដើម្បីសងសឹកបុគ្គល **ខ** ឬក៏មិនសងសឹក។ បន្ទាប់ពីបានគិតថានឹងសងសឹក ឬមិនសងសឹកបុគ្គល **ខ** ហើយ គាត់ក៏បានសម្រេចចិត្តថានឹងសងសឹក។

ដូច្នេះ ដំណាក់កាលនេះមិនត្រូវបានផ្តន្ទាទោសដោយច្បាប់នោះទេ ព្រោះថាគ្មានអំពើណាមួយស្តែងចេញរូបរាងចេញមកខាងក្រៅជាសម្ភារៈដើម្បីកំណត់នោះទេ។

### ខ. ដំណាក់កាលត្រៀមរៀបចំប្រព្រឹត្តបទល្មើស

ដំណាក់កាលទី ២ នេះ ជាដំណាក់កាលដែលជនណាម្នាក់បានត្រៀមក្នុងការប្រព្រឹត្តបទល្មើស តាមគ្រប់មធ្យោបាយ។ មានន័យថា ដើម្បីប្រព្រឹត្តបទល្មើសមួយបានតាមការគ្រោងទុកនោះ លុះត្រាតែបានរៀបចំនូវមធ្យោបាយគ្រប់គ្រាន់ជាមុនសិន។

**ឧទាហរណ៍៖** ដើម្បីសងសឹងបុគ្គល **ខ** បុគ្គល **ក** បានទៅទិញកាំបិតផ្គាក់នៅឯផ្សារ ហើយគាត់អង្គុយសំលៀងកាំបិតដែលទិញមកនោះឱ្យស្រួលបួល រួចគាត់ទៅពិនិត្យរាល់សកម្មភាពនៃការចេញចូលរបស់បុគ្គល **ខ** ដូចជាពេលវេលាចេញចូលទៅធ្វើការជាដើម។ ដូច្នេះយើងឃើញថា ស្ថានភាពបែបនេះគឺជាការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ព្រោះគាត់ត្រៀមដោយទិញកាំបិត ដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គល **ខ** នោះវិញ ។ គាត់ទិញកាំបិត ហើយសំលៀងកាំបិតដើម្បីឱ្យការប្រព្រឹត្តបទល្មើសនោះអាចមានប្រសិទ្ធភាព និង រៀបចំលក្ខណៈប្រព្រឹត្តបទល្មើសតាមការគ្រោងទុករបស់គាត់ ។ នេះគឺជាដំណាក់កាលត្រៀមរៀបចំប្រព្រឹត្តបទល្មើស។

ដូច្នេះ ច្បាប់បានចាត់ទុកថា ដំណាក់កាលនេះគឺពុំទាន់បង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសឡើយ ដោយសារតែគ្មានជនរងគ្រោះដែលត្រូវទទួលរងនូវព្យសនកម្ម(ការខូចខាត) ហើយសង្គមយើងក៏មិនទាន់បានទទួលរងនូវផលប៉ះពាល់ផងដែរ។ ម្យ៉ាងទៀត នៅក្នុងស្ថានភាពប្រភេទនេះ រូបរាងចេញមកខាងក្រៅក៏មិនទាន់ច្បាស់ រីឯការសម្រេចចិត្តថ្វីត្បិតតែមាន ក៏ប៉ុន្តែបុគ្គល **ក** អាចសម្រេចចិត្តផ្លាស់ប្តូរនូវការប្រព្រឹត្តបទល្មើសរបស់ខ្លួនផងដែរ ពីព្រោះគាត់អាចសំលៀងកាំបិតរួចហើយ គាត់មិនយកកាំបិតនោះទៅប្រព្រឹត្តបទល្មើសទេ គឺបែរជាយកកាំបិតនោះទៅធ្វើសកម្មភាពរស់នៅប្រចាំថ្ងៃដូចជា ការកាប់ឈើជាដើម។

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកជាមុន អំពើត្រៀមប្រព្រឹត្តបទល្មើសណាមួយ នឹងត្រូវទទួលនូវទោសទណ្ឌ ដោយហេតុថាបទល្មើសទាំងនោះមានចរិតលក្ខណៈគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូចជា បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋ

ប្រល័យពូជសាសន៍[74] បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[75] និងបទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម[76] ជាដើម។

**គ. ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស**

នៅក្នុងដំណាក់កាលនេះ ជាដំណាក់កាលចាប់ផ្តើមធ្វើសកម្មភាព បានន័យថា បុគ្គលដែលមានបំណងប្រព្រឹត្តបទល្មើសនោះបានរៀបចំដើម្បីធ្វើសកម្មភាព ក្នុងការសម្រេចឱ្យបាននូវបទល្មើស។

**ឧទាហរណ៍៖** បុគ្គល **ក** ដដែល បានយកកាំបិតដែលសំលៀងរួចទៅចាំពួនស្ទាក់ដើម្បីធ្វើការវាយប្រហារទៅលើបុគ្គល **ខ**។ ការណ៍ដែលយកកាំបិតទៅ ហើយរង់ចាំធ្វើការវាយប្រហារនៅក្នុងស្ថានភាពនេះ គឺគេចាប់ផ្តើមគិតពិចារណាថាបានឈានចូលទៅក្នុងដំណាក់កាលថ្មីមួយទៀត ដែលតាមទ្រឹស្តីគេឱ្យឈ្មោះថាជាដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស មានន័យថា នៅពេលដែលជនរងគ្រោះបានជិះម៉ូតូមកដល់កន្លែងគាត់ពួនស្ទាក់នោះ គាត់ក៏ដកកាំបិតដើម្បីធ្វើការកាប់ប្រហារទៅលើជននោះតែម្តង។

ក្នុងដំណាក់កាលនេះ ច្បាប់បានកំណត់ថាមានទោស ប្រសិនបើចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនដោយចេតនា និងមិនមានទោសទេ ប្រសិនបើចារីបោះបង់អំពើរបស់ខ្លួនដោយស្ម័គ្រចិត្ត ដោយគោរពតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលក្ខខណ្ឌទី ២ នៃការប៉ុនប៉ង។

**ឃ. ដំណាក់កាលនៃការសម្រេចបទល្មើស ឬមិនបានសម្រេចនូវបទល្មើស (ការប៉ុនប៉ង)**

បទល្មើសបានសម្រេច គឺជាបទល្មើសទាំងឡាយណាដែលផលវិបាក ឬលទ្ធផលចុងក្រោយបានបំពេញតាមគោលបំណង ឬគោលដៅដែលជនល្មើសចង់បាន។[77] មានន័យថា អំពើរបស់ជនល្មើសទទួលបានលទ្ធផលជាវិជ្ជមានតាមការគិត ឬការគ្រោងទុកជាមុនរបស់ជននោះ។

**ឧទាហរណ៍៖** បន្ទាប់ពីបានពួនស្ទាក់រង់ចាំជនរងគ្រោះអស់រយៈពេលណាមួយហើយ ជនល្មើសក៏បានសម្លាប់ជនរងគ្រោះដោយយកកាំបិតកាប់ទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់តាមការគិតរបស់ចារី។

ក្នុងករណីនេះ យើងហៅថាជាបទល្មើសបានសម្រេច។ ផ្ទុយទៅវិញ ប្រសិនបើជនល្មើសបានកាប់ជនរងគ្រោះរួចហើយ ស្រាប់តែជនរងគ្រោះមិនស្លាប់ទៅវិញ បទល្មើសនេះហៅថាជាបទល្មើសមិនបានសម្រេច។

បទល្មើសមិនបានសម្រេច គឺជាអំពើប្រព្រឹត្តដោយចេតនា ក៏ប៉ុន្តែអំពើនោះមិនបានចប់នៅឡើយ ដោយមូលហេតុផ្សេងៗមកបង្អាក់សកម្មភាពនោះ។ ក្នុងន័យនេះគឺ អំពើរបស់ជនល្មើសទទួលបានលទ្ធផលជាអវិជ្ជមាន មាន

[74] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៨៥។

[75] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៩០។

[76] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៩៦។

[77] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

ន័យថា លទ្ធផលរបស់ជនល្មើសមិនទទួលបានតាមការគិត ឬការគ្រោងទុករបស់ជននោះទេ។ បទល្មើសមិនបានសម្រេចនេះ ជាមូលហេតុនាំឱ្យមានការចោទប្រកាន់ពីបទប៉ុនប៉ង។

## ៥. ការប៉ុនប៉ង

### ៥.១ លក្ខខណ្ឌនៃការប៉ុនប៉ង

ការប៉ុនប៉ង គឺជាសកម្មភាពសំដៅទៅលើការប្រព្រឹត្តអំពើដែលជាបទល្មើស ដែលស្តែងឡើងក្រោមរូបភាពជាការចាប់ផ្តើមប្រព្រឹត្ត និងមិនបានបញ្ឈប់ការប្រព្រឹត្តដោយចេតនា ឬអវត្តមាននៃការបញ្ឈប់ដោយចេតនា។ ដើម្បីកំណត់ថា បទល្មើសមួយថាជាបទល្មើសប៉ុនប៉ងដែលត្រូវផ្តន្ទាទោសបាន លុះត្រាតែមានលក្ខខណ្ឌ ២ (ពីរ) យ៉ាងគឺៈ

#### ក. លក្ខខណ្ឌទី ១

ការចាប់ផ្តើមប្រតិបត្តិ មានន័យថា ចារីបានចាប់ផ្តើមប្រព្រឹត្តអំពើរបស់ខ្លួនដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ ជនល្មើសបានចាប់ផ្តើមប្រព្រឹត្តបទល្មើសរបស់ខ្លួន ដោយប្រើប្រាស់នូវគ្រប់មធ្យោបាយទុច្ចរិតដើម្បីបង្កជាព្យសនកម្មដល់ជនរងគ្រោះ។ ប៉ុន្តែ ការចាប់ផ្តើមប្រព្រឹត្តបទល្មើសតែប៉ុណ្ណឹងមិនទាន់អាចចាត់ទុកថាជាអំពើប៉ុនប៉ងដែលត្រូវផ្តន្ទាទោស ឬជាបទល្មើសប៉ុនប៉ងនោះទេ គឺទាល់តែបានបំពេញលក្ខខណ្ឌទី ២។

#### ខ. លក្ខខណ្ឌទី ២

ការមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។[78] មានន័យថា ជនល្មើសមិនបានបញ្ឈប់អំពើល្មើសរបស់ខ្លួនដោយស្ម័គ្រចិត្ត ឬដោយចេតនាទេ គ្រាន់តែអំពើនោះត្រូវបានបញ្ឈប់ដោយកាលៈទេសៈផ្សេងតែប៉ុណ្ណោះ។ ក្នុងករណីនេះ ជនល្មើសត្រូវតែទទួលទោសព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ ប្រសិនបើជនល្មើសសុខចិត្តបោះបង់ចោលអំពើល្មើសរបស់ខ្លួនដោយស្ម័គ្រចិត្ត ឬដោយចេតនានោះ ជននោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្តនេះត្រូវគោរពតាមលក្ខខណ្ឌពីរគឺៈ

- (១) ការបញ្ឈប់ត្រូវធ្វើដោយចេតនា ពោលគឺត្រូវកើតឡើងដោយឆន្ទៈរបស់ជនល្មើស មិនមែនកើតឡើងដោយការគាបសង្កត់ ឬបង្ខំពីមជ្ឈដ្ឋានខាងក្រៅទេ ដូចជា ក្នុងកំឡុងពេលដែលជនល្មើសបានត្រៀមលក្ខណៈថានឹងប្រព្រឹត្ត និងមុនពេលប្រព្រឹត្តអំពើរបស់ខ្លួនទៅលើជនរងគ្រោះ ជនល្មើសបានគិតឡើងវិញថា ប្រសិនបើខ្លួនប្រព្រឹត្តអំពើដូចជាការសម្លាប់មនុស្ស វាជាអំពើអមនុស្សធម៌ ហើយខ្លួននឹងទទួលទោសចំពោះអំពើនេះទៀត។ ដោយហេតុនេះហើយ គាត់ក៏បានសម្រេចចិត្តថានឹងបញ្ឈប់អំពើរបស់ខ្លួនទៅលើជនរងគ្រោះ។ នៅក្នុងស្ថានភាពបែបនេះ ច្បាប់កំណត់ថា មិនធ្វើការផ្តន្ទាទោសដល់ជននោះទេ។

[78] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៧។

- (២) ការបញ្ឈប់នេះត្រូវកើតឡើងមុនបទល្មើសបានសម្រេច មានន័យថា ការបញ្ឈប់នេះត្រូវកើតឡើងមុនអំពើគ្រោះថ្នាក់ដល់សង្គមកើតមានឡើង។ បើពុំដូច្នោះទេ ការបញ្ឈប់នេះពុំមែនជាការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្តទេ គឺជាការស្តាយក្រោយដោយសកម្ម។ ការស្តាយក្រោយនេះ គ្មានអានុភាពលុបលាងបទល្មើសបានឡើយ ប៉ុន្តែអាចត្រូវបានទទួលរងនូវស្ថានសម្រាលទោស[79] ដូចជាការលួចម៉ូតូរបស់គេនៅពេលយប់ បន្ទាប់ពីបានរយៈពេលមួយថ្ងៃក្រោយមក ដោយមូលហេតុអាណិតអាសូរទៅដល់ជនរងគ្រោះ ជនល្មើសក៏បានយកម៉ូតូនោះទៅសងគេវិញ។

ផ្ទុយទៅវិញ ប្រសិនបើការបញ្ឈប់របស់ជនល្មើសដោយស្ថានភាពក្រៅឆន្ទៈ ឬមានការអាក់ខានដោយសារតែមានកាលៈទេសៈពីខាងក្រៅបានទៅបង្អាក់មិនឱ្យប្រព្រឹត្តបទល្មើសកើត ជនល្មើសត្រូវទទួលការចោទប្រកាន់ពីការប៉ុនប៉ង ដូចជាមុនពេលដែលជនល្មើសប្រព្រឹត្តបទល្មើសនោះ ស្រាប់តែមាននគរបាលយុត្តិធម៌ធ្វើការយាមល្បាត ឬត្រួតពិនិត្យនៅកន្លែងនោះ។ ដោយខ្លាចប៉ូលិសដឹង ជនល្មើសក៏បានដកថយមិនធ្វើសកម្មភាពទៅវិញ។

**៥.២ ទណ្ឌកម្មនៃការប៉ុនប៉ង**

យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ក្នុងករណីការប៉ុនប៉ងដែលអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះគឺ គ្រប់ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ត្រូវតែទទួលរងនូវការផ្តន្ទាទោសដូចគ្នាទៅនឹងបទឧក្រិដ្ឋដែរ។ ប៉ុន្តែ ចំពោះបទមជ្ឈិមវិញ ដើម្បីអាចផ្តន្ទាទោសលើករណីប៉ុនប៉ងក្នុងបទមជ្ឈិមបាន លុះត្រាតែមានច្បាប់ចែងចង្អុលច្បាស់លាស់ថា ការប៉ុនប៉ងនោះគឺត្រូវផ្តន្ទាទោស។ មានន័យថា លុះត្រាតែមានច្បាប់កំណត់ទុកជាមុនថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមត្រូវផ្តន្ទាទោសនៅក្នុងច្បាប់យ៉ាងជាក់លាក់។

**ឧទាហរណ៍៖** នៅក្នុងបទល្មើសលួចដែលមានចែងនៅក្នុងមាត្រា ៣៥៣ និងមាត្រា ៣៥៦ គឺជាប្រភេទនៃបទល្មើសមជ្ឈិម ដូច្នេះដើម្បីឱ្យការប៉ុនប៉ងក្នុងបទលួចត្រូវផ្តន្ទាទោសបានទៅតាមមាត្រាទាំងពីរខាងលើនេះ លុះត្រាតែច្បាប់បានចែងយ៉ាងជាក់ច្បាស់ ដូចជាមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់ថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។

ចំណែកឯការប៉ុនប៉ងប្រព្រឹត្តបទលហុ គឺច្បាប់បានកំណត់ថា មិនទទួលការផ្តន្ទាទោសទេ។[80] បានសេចក្តីថាការប៉ុនប៉ងប្រព្រឹត្តបទលហុ ច្បាប់មិនឱ្យទទួលទណ្ឌកម្មព្រហ្មទណ្ឌទេ។

**ឧទាហរណ៍៖** បុរសជិះម៉ូតូម្នាក់ ដោយហេតុថាគ្មានមនុស្សឆ្លងកាត់ គាត់បានសម្រេចចិត្តឆ្លងកាត់ផ្លូវក្នុងករណីភ្លើងក្រហម។ ក្នុងកំឡុងពេលដែលគាត់បម្រុងនឹងឆ្លងកាត់នោះ ស្រាប់តែគាត់បានបញ្ឈប់សកម្មភាពដោយការឆ្លងរបស់គាត់ទៅវិញ ព្រោះគាត់បានឃើញថាមានប៉ូលិសចរាចរណ៍នៅមុខចាំចាប់អ្នកដែលមិនគោរពច្បាប់ចរាចរណ៍។

[79] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៣។

[80] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៧។

## ផ្នែកទី ២៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ជាទូទៅ ជនណាប្រព្រឹត្តបទល្មើស ជននោះត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ ប៉ុន្តែ មានករណីខ្លះ បុគ្គលណាមួយដែលប្រព្រឹត្តអំពើដែលជាបទល្មើស មានចែងក្នុងច្បាប់ជាធរមាន បុគ្គលនោះក៏អាចរួចផុតពីការទទួលខុសត្រូវចំពោះអំពើនោះបានដែរ។ សំណួរសួរថា តើមានមូលហេតុអ្វីខ្លះ ដែលជនម្នាក់ប្រព្រឹត្តអំពើដែលជាបទល្មើសហើយ បែរជាមិនទទួលខុសត្រូវព្រហ្មទណ្ឌទៅវិញ?

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការមិនឆ្លើយតបទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្ត។ ដើម្បីអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបាន លុះត្រាតែមានមូលហេតុដូចខាងក្រោម៖

### ១. មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬភាពមិនអាចទម្លាក់កំហុសបាន

មូលហេតុអត្តនោម័តនេះ សំដៅលើបុគ្គលដែលជាជនដែលប្រព្រឹត្តបទល្មើស ពោលគឺជាការប៉ះពាល់ដោយផ្ទាល់ទៅនឹងសតិបញ្ញាស្មារតីរបស់ជននោះ ឬប៉ះពាល់ដល់ការសម្រេចចិត្តដោយឯករាជ្យរបស់ចារីនៃបទល្មើស។ មូលហេតុនេះ គេអាចហៅថាជាមូលហេតុដែលមិនអាចទម្លាក់កំហុសបាន ដែលអាចនាំឱ្យចារីរួចផុតពីការទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ។ ថ្វីត្បិតតែមូលហេតុខាងលើនេះ ជាមូលហេតុដែលទាក់ទងផ្ទាល់ទៅនឹងចារីពិតមែន ក៏ប៉ុន្តែ ប្រសិនបើមានអ្នកផ្តើមគំនិត អ្នកសមគំនិត អ្នកនោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[81] មូលហេតុដែលទាក់ទងទៅនឹងចារីនេះ មានដូចជា៖

#### ១.១ មូលហេតុវិបល្លាសស្មារតី

វិបល្លាសស្មារតី សំដៅលើស្ថានភាពមួយដែលបុគ្គលម្នាក់មានវិបត្តិផ្នែកបញ្ញាស្មារតី វិកលចរិត សតិមិនល្អ ដែលពុំអាចដឹងខុសត្រូវលើទង្វើរបស់ខ្លួនបានដូចមនុស្សធម្មតាក្នុងរយៈពេលណាមួយ។ ជនណាដែលប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[82] ផ្ទុយទៅវិញ បើជននោះកើតវិបល្លាសស្មារតីដែលគ្រាន់តែកាត់បន្ថយនូវការដឹងខុសដឹងត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ដើម្បីអាចកំណត់បានថា ជននេះកើតវិបល្លាសស្មារតី ឬគ្រាន់តែអន់ថយនូវការយល់ដឹងខុសត្រូវនោះ ត្រូវមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ពីគ្រូពេទ្យជំនាញ ដើម្បីឱ្យតុលាការធ្វើការពិនិត្យ និងពិចារណាពីបញ្ហានេះក្នុងការកំណត់ទោស មានន័យថា តុលាការអាចផ្តល់នូវស្ថានសម្រាលចំពោះជនដែលបានប្រព្រឹត្តបទល្មើស ដោយបាត់បង់នូវការយល់ដឹងខ្លះបាន។ ប៉ុន្តែ ច្បាប់មិនលើកលែងចំពោះជនដែលកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ ហើយ

[81] ប្រសាសន៍របស់ឯកឧត្តម **ផូវ សំភី** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

[82] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣១។

បានប្រព្រឹត្តបទល្មើសទេ បានសេចក្តីថា ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបានឡើយ ។

**ឧទាហរណ៍៖** បុរសស្រវឹងស្រាម្នាក់ បានដើរតាមផ្លូវទៅផ្ទះវិញ ក៏ស្រាប់តែឃើញស្រីស្អាតម្នាក់កំពុងតែអង្គុយលក់នំនៅជាប់នឹងផ្លូវ ដោយសារតែស្រវឹងស្រា ទើបធ្វើឱ្យគាត់គ្រប់គ្រងស្មារតីមិនបាន ក៏បានចាប់រំលោភស្រីស្អាតម្នាក់នោះ។ ក្នុងករណីនេះ ជនល្មើសមិនអាចអះអាងថាខ្លួនមានវិបល្លាសស្មារតីក្នុងបទល្មើសរំលោភបានទេ ព្រោះគាត់បាត់បង់ស្មារតីដោយសារតែគ្រឿងស្រវឹងតែប៉ុណ្ណោះ។ ក្នុងករណីនេះ ជនល្មើសនឹងត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

### ១.២ មូលហេតុដោយសារអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ

ការបង្ខំ ជាភាពលុបបំបាត់ចោលនូវសេរីភាពរបស់ជនល្មើស មានន័យថា ជនល្មើសមិនអាចធ្វើអ្វីក្រៅពីប្រព្រឹត្តបទល្មើសឡើយ ពោលគឺជនល្មើសស្ថិតនៅក្រោមការគាបសង្កត់ ឬការបង្ខិតបង្ខំណាមួយដែលមិនអាចទប់ទល់បាន។[83]

យោងតាមក្រមព្រហ្មទណ្ឌមាត្រា ៣៦ បានកំណត់អំពីអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ សំដៅទៅដល់បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាននោះ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។ ការបង្ខំ អាចស្តែងឡើងតាមរយៈការបង្ខំផ្លូវកាយ និងការបង្ខំផ្លូវចិត្ត។

#### ក. ការបង្ខំផ្លូវកាយ

ការបង្ខំផ្លូវកាយ សំដៅលើស្ថានភាពមួយដែលជនល្មើសត្រូវបានរងនូវការបង្ខំដោយកាលៈទេសៈខាងក្រៅ និងដោយមិនអាចទប់ទល់បាន អាចជាកម្លាំងខាងក្រៅ ឬករណីធម្មជាតិជាដើម។

**ឧទាហរណ៍៖** ទាហានម្នាក់ត្រូវបានទទួលច្បាប់ឈប់សម្រាកចំនួន ២ (ពីរ) ថ្ងៃ ហើយដល់ពេលថ្ងៃដែលគាត់ជិះឡានក្រុងទៅបន្ទាយទាហានវិញនោះ ក៏ស្រាប់តែមានករណីមួយកើតឡើងដូចជា មានបាតុកម្មបណ្តាលឱ្យមានការបិទផ្លូវ ក៏ធ្វើឱ្យឡានក្រុងមិនបានបន្តដំណើរទៅមុខ ឬករណីដាច់ផ្លូវ ដែលមិនអាចឆ្លងកាត់តាមនោះបានជាដើម។ ដោយសារតែមូលហេតុនេះហើយ ទើបគាត់ទៅដល់ទីតាំងមិនទាន់ពេលវេលា។ បើយោងតាមច្បាប់ទាហាន គាត់នឹងទទួលទោសដែលជាបទល្មើសរត់ចោលជួរ។ ប៉ុន្តែ ដោយសារនេះជាស្ថានភាពដែលមិនអាចមើលឃើញបានជាមុន និងមិនអាចជៀសវាងបាន ហើយគាត់ក៏មិនអាចទប់ទល់បានទៀត ព្រោះគ្មានមធ្យោបាយផ្សេងទៀត ដូច្នេះ គាត់មិនទទួលខុសត្រូវចំពោះបទល្មើសនោះទេ។

[83] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

**ខ. ការបង្ខំផ្លូវចិត្ត**

គឺជាស្ថានភាពមួយដែលចារីស្ថិតនៅក្រោមការគំរាមកំហែងដោយតតិយជន ដែលជាអានុភាពនៃកម្លាំង ឬការបង្ខំទៅលើផ្លូវចិត្តរបស់ចារី ជាពិសេសគឺការគំរាមកំហែងដែលទាក់ទងដោយផ្ទាល់ទៅលើចិត្តសាស្ត្ររបស់ចារីនៃបទល្មើស មានន័យថា ចារីប្រព្រឹត្តបទល្មើសដែលមិនមែនជាឆន្ទៈផ្ទាល់របស់ខ្លួនឡើយ។

**ឧទាហរណ៍៖** ការគំរាមកំហែងថានឹងសម្លាប់ចារី ឬសម្លាប់សាច់ញាតិរបស់ចារី ដើម្បីធ្វើឱ្យចារីប្រព្រឹត្តបទល្មើសណាមួយដូចជា ការវាយ សម្លាប់នរណាម្នាក់ ឬឱ្យធ្វើអ្វីមួយតាមគោលបំណងរបស់តតិយជនជាដើម។

### ១.៣ មូលហេតុទាក់ទងនឹងអនីតិភាព

ជាទូទៅ ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ដែលបានបញ្ញត្តថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។[84] មានន័យថា បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសណាមួយដែលច្បាប់បានចែងទុកជាមុន នឹងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន លុះត្រាតែបុគ្គលនោះមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ដូច្នេះ ជាគោលការណ៍ ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ក៏ប៉ុន្តែជា**អញ្ញត្រកម្ម** នៅក្នុងករណីពិសេសមួយចំនួន តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនដែលជាជនល្មើសនោះតម្រូវ ដូចជាបទល្មើសមានលក្ខណៈឃោរឃៅ ឬមួយប្រព្រឹត្តជាប្រចាំ ឬក៏អនីតិជននោះមានអាយុ ១៤ (ដប់បួន) ឆ្នាំក៏ពិតមែន ប៉ុន្តែមានការរីកធំធាត់ និងមានការយល់ដឹងដូចជាមនុស្សពេញវ័យដែរ។

ដូច្នេះ តុលាការអាចប្រកាសទោស ក៏ប៉ុន្តែទោសដែលត្រូវប្រកាសចំពោះអនីតិជនដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំនោះ មានលក្ខណៈស្រាលជាងទោសដែលត្រូវប្រកាសសម្រាប់នីតិជន។ យ៉ាងណាមិញ តុលាការមិនអាចប្រកាសទោសចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ បានឡើយ។

## ២. មូលហេតុស្តីពីអំពើយុត្តិកម្ម

មូលហេតុដែលគេចាត់ទុកថាចេញក្រៅពីបុគ្គលនៃចារី ហើយដែលធ្វើឱ្យចារីរួចផុតពីការទទួលខុសត្រូវ និងនាំឱ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក៏រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាទៅនឹងចារីផងដែរ គឺជា**អំពើយុត្តិកម្ម** ដែលត្រូវបានរៀបរាប់ដូចខាងក្រោម៖

[84] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨។

### ២.១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

ចំពោះការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរនេះ ក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលច្បាប់បានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។[85] ហេតុដូច្នេះ អំពើក៏ក្លាយទៅជាអំពើស្របច្បាប់ទៅវិញ ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌសោះឡើយ។

**ឧទាហរណ៍៖** ការប្រព្រឹត្តអំពើតាមបញ្ញត្តច្បាប់ដូចជា មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិក្នុងការឃាត់ខ្លួនជនណាម្នាក់ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ដូច្នេះ អំពើរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួនជនដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសនេះ មិនមែនជាការរំលោភបំពានទៅលើជននោះទេ។ ម៉្យាងវិញទៀត បើយោងតាមមាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានផ្តល់សិទ្ធិទៅឱ្យជនគ្រប់រូប អាចចាប់ខ្លួនជនល្មើសបាន ហើយប្រគល់ជននោះទៅមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ។

ចំពោះករណីទាក់ទងនឹងការបញ្ជារបស់អាជ្ញាធរស្របច្បាប់វិញ យោងតាមបញ្ញត្តនៃក្រមព្រហ្មទណ្ឌខាងលើដដែល កថាខណ្ឌទី ២ បានកំណត់ថា បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ មានន័យថា អំពើទាំងឡាយណាដែលអាជ្ញាធរដែលមានអំណាចតាមផ្លូវច្បាប់ តាមមុខការ និងតួនាទីរបស់ខ្លួនយ៉ាងជាក់លាក់បានបញ្ជាឱ្យធ្វើ ជនដែលធ្វើតាមបញ្ជានោះមិនទទួលខុសត្រូវចំពោះអំពើនោះឡើយ។

**ឧទាហរណ៍៖** ក្នុងករណីការធ្វើចរាចរណ៍ ដោយឃើញថាមានការកកស្ទះខ្លាំងពេក ប៉ូលិសចរាចរណ៍បានធ្វើសញ្ញាចរាចរណ៍ដោយផ្ទុយទៅនឹងភ្លើងសញ្ញាចរាចរណ៍។ ក្នុងករណីនេះ ប្រជាពលរដ្ឋដែលធ្វើតាមបញ្ជារបស់ប៉ូលិសចរាចរណ៍ មិនត្រូវបានផាកពិន័យចំពោះការរំលោភភ្លើងសញ្ញាក្រហមនោះទេ។

### ២.២ ការការពារស្របច្បាប់ និងសច្ចធារណ៍នៃការការពារស្របច្បាប់

ចំពោះករណីនៃការការពារស្របច្បាប់ គឺធ្វើឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅក្នុងករណីនេះ ខុសពីការអនុវត្តតាមច្បាប់ ឬតាមបញ្ជារបស់**អាជ្ញាធរណម្នានរូប** ដែលចាត់ទុកថាមិនប្រព្រឹត្តបទល្មើស។ ផ្ទុយទៅវិញ នៅក្នុងករណីការការពារស្របច្បាប់ គឺមានន័យថាប្រព្រឹត្តបទល្មើស ប៉ុន្តែមិនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយក៏មិនទទួលទោសព្រហ្មទណ្ឌដែរ បើទោះបីជាមានបទល្មើសកើតឡើងក៏ដោយ។ បើយោងតាមមាត្រា ៣៣ វាក្យខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌចែងថា បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ដោយឡែក យោងតាមមាត្រាដដែល វាក្យខណ្ឌទី ២ បានចែងបញ្ជាក់ថា ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ ៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឈមមុខនឹងការឈ្លានពានមួយ ដែលមិនត្រឹមត្រូវ ពោលគឺត្រូវតែមានការឈ្លានពានជា

[85] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣២។

មុន ហើយបទល្មើសដែលយើងប្រព្រឹត្តគឺ ដើម្បីទប់ទល់ទៅនឹងការឈ្លានពាននោះ ត្រូវតែចាំបាច់ បានន័យថា បើសិនជាយើងអាចជៀសវាងបានតាមមធ្យោបាយផ្សេង គឺគេចាត់ទុកថាមិនចាំបាច់ឡើយ។ ដូច្នេះ យើងមានតែផ្លូវមួយគត់ដើម្បីប្រព្រឹត្តបទល្មើសតទល់ជាមួយនឹងការឈ្លានពានដែលបានកើតឡើងនោះ ឬក៏យើងអាចនិយាយម្យ៉ាងទៀតបានថា គ្មានជម្រើសចុងក្រោយ ឬជម្រើសណាមួយទេក្រៅពីការតបតទៅវិញនោះ ។

- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងនៅក្នុងពេលជាមួយគ្នា មានន័យថា ការការពារនោះត្រូវតែតបតមកវិញភ្លាមៗតែម្តង។
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។ បានសេចក្តីថា ការណ៍ដែលយើងប្រើប្រាស់នូវមធ្យោបាយការពារនោះគឺ ត្រូវសមាមាត្រទៅតាមទំហំគ្រោះថ្នាក់នៃការឈ្លានពាន។

**ឧទាហរណ៍៖** លោក **មករា** ត្រូវបានលោក **កុម្ភៈ** ប្រើហិង្សាទៅលើគាត់។ ក្នុងពេលនោះដែរ ដោយគ្មានមធ្យោបាយក្នុងការរត់គេចខ្លួនពីលោក **កុម្ភៈ** ដោយហេតុផ្លូវទាល់ច្រក លោក **មករា** បានប្រទះឃើញមានដំបងនៅជិតខ្លួន ក៏បានវាយបកទៅវិញបណ្តាលឱ្យលោក **កុម្ភៈ** បែកក្បាល ហើយលោក **មករា** ក៏បានឆក់ឱកាសរត់ពីកន្លែងនោះបាត់ទៅ។ ក្នុងករណីនេះ លោក **មករា** មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះនេះជាអំពើការពារខ្លួនដែលជាអំពើទប់ទល់ទៅនឹងការឈ្លានពានដោយលោក **កុម្ភៈ**។

សរុបជារួមមក លក្ខខណ្ឌនៃការការពារស្របច្បាប់ទាំងបីខាងលើនេះ គឺត្រូវតែផ្គុំគ្នា ឬក៏ត្រូវតែបំពេញឱ្យគ្រប់ទាំងអស់។

មានករណីមួយទៀត ដែលនៅក្នុងក្របខណ្ឌនៃការការពារស្របច្បាប់ បានសន្មតថាជាការការពារស្របច្បាប់តែម្តង ក្រមព្រហ្មទណ្ឌបានកំណត់ថាជា**សច្ចធារណ៍** នៃការការពារស្របច្បាប់ យោងតាមមាត្រា ៣៤ បានចែងថា ត្រូវសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅ៖

- បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។ មានន័យថា ការចូលនៅក្នុងពេលយប់ទៅកន្លែងដែលមានមនុស្សរស់នៅ តាមរយៈការប្រើប្រាស់សោរក្លែង ឬក៏ការកាប់គាស់ទម្លុះទម្លាយដោយប្រើប្រាស់នូវឧបករណ៍ផ្សេងៗ អនុញ្ញាតឱ្យម្ចាស់ទីកន្លែងប្រើប្រាស់មធ្យោបាយទប់ទល់ដើម្បីរុញច្រានអ្នកនោះឱ្យចេញវិញបាន។
- បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ ដែលអនុវត្តដោយហិង្សា។ ការណ៍ដែលយើងស្ថិតនៅក្នុងស្ថានភាពដែលមានចោរប្លន់ ឬក៏ចោរមកលួចដោយប្រើហិង្សា ដោយប្រើប្រាស់អាវុធ គឺយើងអាចប្រើប្រាស់មធ្យោបាយដើម្បីទប់ទល់តបទៅវិញបាន។ សច្ចធារណ៍ ឬក៏

ការសន្មតថាជាការការពារស្របច្បាប់នេះ គឺពុំមានលក្ខណៈដាច់ខាតទេ បានន័យថា អាចត្រូវបានរំលាយដោយភស្តុតាងផ្ទុយ។ ហេតុដូច្នេះហើយបានជាគេថា ទោះបីជាយើងស្ថិតនៅក្នុងស្ថានភាពនៃការសន្មតថាជាការការពារស្របច្បាប់ក៏ដោយ ក៏មិនអនុញ្ញាតឱ្យយើងប្រើប្រាស់នូវមធ្យោបាយតទល់នោះ ដោយមានវិសមាមាត្រជាមួយនឹងអំពើដែលឈ្លានពានឡើយ ហើយដែលយើងបានយល់ដឹងយ៉ាងច្បាស់លាស់ទៀតផង។

**២.៣ ស្ថានភាពចាំបាច់**

ស្ថានភាពចាំបាច់ សំដៅលើស្ថានភាពទាំងឡាយណាដែលបុគ្គលម្នាក់ សម្រេចចិត្តប្រព្រឹត្តបទល្មើស ដើម្បីគេចផុតពីមហន្តរាយដែលហៀបនឹងកើតឡើងចំពោះខ្លួនឯង ឬអ្នកដទៃ។ ដើម្បីកំណត់ថា អំពើមួយប្រព្រឹត្តឡើងក្នុងស្ថានភាពចាំបាច់ ច្បាប់បានកំណត់អំពីលក្ខខណ្ឌនៅក្នុងករណីនេះ ដូចតទៅ៖

- បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។[86]

ក្នុងករណីស្ថានភាពចាំបាច់នេះ មានលក្ខណៈខុសគ្នាពីការការពារស្របច្បាប់ ដោយស្ថានភាពចាំបាច់គ្មានការឈ្លានពានមិនត្រឹមត្រូវនោះទេ និងអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ ដោយសារតែនៅក្នុងស្ថានភាពចាំបាច់ ចារីមានសេរីភាពក្នុងការជ្រើសរើសថាប្រព្រឹត្ត ឬមិនប្រព្រឹត្ត។ ចំណែកឯអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំវិញ គឺចារីគ្មានជម្រើសអ្វីក្រៅពីប្រព្រឹត្តបទល្មើសឡើយ។

**ឧទាហរណ៍៖** អ្នកថ្មើរជើងម្នាក់បានកំពុងដើរដោយភ្លេចខ្លួន ឬដោយសារតែគាត់កំពុងចាប់អារម្មណ៍មើលទេសភាព គាត់ពុំបានដឹងថាមានរថយន្តបើកមកពីក្រោយខ្នងគាត់ ហើយមានតតិយជនម្នាក់ បានរត់ទៅចាប់កន្ត្រាក់ ឬរុញច្រាន ឬក៏ធាក់ជននោះឱ្យដួលដើម្បីឱ្យជននោះបានគេចផុតពីគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ ដូច្នេះ ដោយសារតែស្ថិតនៅក្នុងស្ថានភាពចាំបាច់ ហើយផលប្រយោជន៍ដែលត្រូវការពារ ធ្ងន់ធ្ងរជាងផលប្រយោជន៍នៃការលះបង់ ទើបតតិយជនរូបនោះ រុញអ្នកថ្មើរជើងបណ្តាលឱ្យរងរបួស ដែលអាចជាការបង្ករបួសស្នាម ឬហិង្សា។ សរុបមក ចារីដែលប្រព្រឹត្តបទល្មើសនៅក្នុងស្ថានភាពចាំបាច់ ច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។

## ផ្នែកទី ៣៖ ការអនុវត្តទោស

### ១. ស្ថានភាពទូទៅនៃទោសព្រហ្មទណ្ឌ

#### ១.១ អត្ថន័យនៃទោសព្រហ្មទណ្ឌ

ទោស គឺជាទណ្ឌកម្មដែលកំណត់ដោយសង្គម ទៅលើចារីដែលប្រព្រឹត្តបទល្មើសដោយផ្អែកលើច្បាប់។ ទោស ត្រូវបានគេបែងចែកដាច់ស្រឡះពីសំណងរដ្ឋប្បវេណី និងដាច់ស្រឡះពីទណ្ឌកម្មវិន័យ។ គោលការណ៍នៃការ

[86] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥។

បែងចែកនេះ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ទោសត្រូវបានគេប្រើប្រាស់ក្នុងនាមសង្គម និងដើម្បីការពារផលប្រយោជន៍សាធារណៈ គឺបម្រើផលប្រយោជន៍ដល់សង្គមទាំងមូល។ ចំណែកឯសំណងរដ្ឋប្បវេណី ក៏ដូចជាទណ្ឌកម្មវិន័យ គឺសំដៅការពារផលប្រយោជន៍របស់ក្រុមណាមួយ ទោះបីក្រុមនោះជាបុគ្គលក្តី ឬជាសមូហភាពក្តី។[87]

ដូច្នេះ ទោសគឺជាវិធានបង្ក្រាបយ៉ាងតឹងរ៉ឹងបំផុតរបស់រដ្ឋ ដែលត្រូវបានបញ្ញត្តហើយជាការស្រេចនៅក្នុងច្បាប់ព្រហ្មទណ្ឌ ពោលគឺអាស្រ័យដោយអង្គការតុលាការជាអ្នកសម្រេចផ្តន្ទាទោសជនល្មើស។

### ១.២ គោលបំណងនៃទោសព្រហ្មទណ្ឌ

ការដាក់ទោសទៅលើជនល្មើសនេះ គឺក្នុងគោលបំណងពុំមែនត្រឹមតែបង្ក្រាបជនល្មើសតែប៉ុណ្ណោះទេ គឺនៅមានគោលបំណងអប់រំ កែប្រែបុគ្គលទាំងនោះឱ្យក្លាយទៅជាមនុស្សមានផលប្រយោជន៍សម្រាប់ច្បាប់ឱ្យបានត្រឹមត្រូវ និងរាំងស្កាត់បទល្មើសថ្មីៗមិនឱ្យកើតមានឡើង។ គោលបំណងនៃការដាក់ទោសនេះ ត្រូវបានបែងចែកជា ៣ (បី) គឺៈ

#### ក. គោលបំណងនៃការធ្វើឱ្យរួញរា ឬគោលបំណងនៃការការពារទុកជាមុន

ការដាក់ទោស ធ្វើឱ្យសម្រេចទិសដៅពីរយ៉ាងគឺ ធ្វើឱ្យរួញរាចំពោះបុគ្គលណាមួយ (ការភ័យខ្លាចចំពោះការទទួលទោស ជាមូលហេតុធ្វើឱ្យគេបញ្ឈប់ការប្រព្រឹត្តបទល្មើសពាក់កណ្តាលទីបាន) និងធ្វើឱ្យរួញរាជាទូទៅ (ដូចជាជនប្រព្រឹត្តបទល្មើសដែលត្រូវបានគេដាក់ទោសនោះ គឺជាឧទាហរណ៍សម្រាប់ឱ្យអ្នកដទៃទៀតធ្វើការពិចារណាឱ្យបានវែងឆ្ងាយ មុននឹងប្រព្រឹត្តបទល្មើសជាយថាហេតុ)។

#### ខ. គោលបំណងនៃការធ្វើសំណងជាប្រាក់

ការដាក់ទោសលើការខូចខាត ដែលត្រូវបានកម្រិតលើមូលដ្ឋាននៃ**ពិរុទ្ធភាព**របស់ជនល្មើស និងលើមូលដ្ឋាននៃការខូចខាតដែលសង្គមបានទទួលរងគ្រោះ គឺបានសេចក្តីថាជាការដាក់ទោសលើជនល្មើសត្រូវផ្អែកលើពិរុទ្ធភាព ពោលគឺចាប់បង្ខំជនល្មើសឱ្យធ្វើសំណងជួសជុលការអន្តរាយដល់សង្គម។ ការធ្វើយ៉ាងនេះ គឺក្នុងគោលបំណងធ្វើឱ្យការឈឺចាប់របស់ជនរងគ្រោះ និងមតិសាធារណៈបានរំងាប់ស្ងប់ស្ងាត់ទៅវិញ។

#### គ. គោលបំណងនៃការអប់រំកែប្រែ

គោលបំណងនៃការដាក់ទោសនេះ មិនមែនសំដៅទៅលើការធ្វើទារុណកម្មលើរូបរាងកាយជនល្មើសនោះទេ គោលបំណងចំបងគឺសំដៅទៅលើការអប់រំ កែប្រែជនល្មើសឱ្យកែប្រែអត្តចរិតពីមនុស្សកោងកាចឃោឃៅឱ្យទៅជាមនុស្សមានផលប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

---

[87] សាស្ត្រាចារ្យ **ហ៊ាង ឡេង**, នីតិព្រហ្មទណ្ឌទូទៅ, សម្រាប់និស្សិតឆ្នាំទី ២។

### ១.៣ ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ

#### ក. ចរិតលក្ខណៈនីត្យានុកូលនៃទោស

ទោសទាំងអស់ត្រូវតែមានចែងនៅក្នុងច្បាប់ ប៉ុន្តែច្បាប់មិនបានចែងទោសបញ្ញត្តដោយរបៀបតឹងរ៉ឹងទេ ពោលគឺជានិច្ចកាលតែងតែទុកចន្លោះ ដើម្បីឱ្យចៅក្រមធ្វើការពិចារណាដោយផ្អែកលើស្ថានភាពទម្ងន់ទោស ឬស្ថានភាពសម្រាលទោស ក្នុងការកំណត់ទណ្ឌកម្មឱ្យបានសមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជនល្មើស។

#### ខ. ចរិតលក្ខណៈនៃការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសដោយតុលាការទេ។[88]

មានន័យថា បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស ហើយដែលត្រូវបានអនុវត្តទោសចំពោះអំពើរបស់ខ្លួនបាន លុះត្រាតែទោសនោះត្រូវបានប្រកាសដោយតុលាការ។ ម្យ៉ាងវិញទៀត តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្តទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។[89]

### ១.៤ ផលវិបាកនៃទោសព្រហ្មទណ្ឌ

ការផ្តន្ទាទោសទៅលើទណ្ឌិត គឺជាលក្ខណៈចាំបាច់មួយដែលធ្វើឱ្យទណ្ឌិតមានការឈឺចាប់ខាងផ្លូវកាយ ផ្លូវចិត្ត ព្រមទាំងមានការបន្ទោស ទោះបីតិច ឬច្រើនក៏ដោយ ដាច់ខាតត្រូវតែមានករណីខាងលើនេះ។

#### ក. ការឈឺចាប់

ការដាក់ទោសទៅលើទណ្ឌិត ជាហេតុនាំឱ្យមានការលំបាកខាងផ្លូវកាយ ដូចជាកន្លែងសម្រាកមិនស្រួលជាដើម។ ចំណែកឯការលំបាកខាងផ្លូវចិត្តមានដូចជា ការនឹករឭកដល់ក្រុមគ្រួសារ ព្រួយបារម្ភពីប្រពន្ធកូនជាដើម។

#### ខ. ការបន្ទោស

ការបន្ទោស គឺជាការស្អប់ខ្ពើមពីសំណាក់សាធារណៈជន ដូចជាការចំអកឡកឡឺយទៅលើទណ្ឌិត ឬទៅលើក្រុមគ្រួសាររបស់គេ ពោលគឺសាធារណៈជនមានទស្សនៈថា អ្នកធ្លាប់ជាប់ពន្ធនាគារ សុទ្ធតែជាមនុស្សមិនល្អ ធ្លាប់បំពារបំពានលើច្បាប់ជាដើម។

---

[88] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦។

[89] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦។

## ២. ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។[90] ដូច្នេះ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដែលច្បាប់ព្រហ្មទណ្ឌបានចែងថាមានទោសនោះ បុគ្គលនោះនឹងត្រូវទទួលរងនូវទណ្ឌកម្មចំពោះអំពើរបស់ខ្លួន។ ប៉ុន្តែ តុលាការប្រកាសទោសដោយផ្អែកលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។[91] ចំពោះការទទួលទណ្ឌកម្មសម្រាប់រូបវន្តបុគ្គល ត្រូវបានបែងចែកជាពីរគឺៈ

- ការទទួលទណ្ឌកម្មសម្រាប់នីតិជន និង
- ការទទួលទណ្ឌកម្មសម្រាប់អនីតិជន។

### ២.១ មូលទោស

មូលទោស សំដៅទៅលើទោសសំខាន់ចម្បងជាងគេ ដែលតុលាការអាចប្រកាសទោសតែឯង ដើម្បីផ្តន្ទាទោសចំពោះបទល្មើសណាមួយ។[92] មូលទោស ត្រូវបានបែងចែកជាពីរគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ការកំណត់នៃទោសនីមួយៗ ជាគោលការណ៍តាមបញ្ញត្តនៃក្រមព្រហ្មទណ្ឌ បានកំណត់អប្បបរមា និងអតិបរមានៃទោសនីមួយៗ មានន័យថា អប្បបរមានៃទោសដាក់ពន្ធនាគារ អតិបរមានៃទោសដាក់ពន្ធនាគារ អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់។ អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចត្រូវបានបន្ថយ ឬបន្ថែមក្នុងលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ដូចជាករណីដែលមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសចំពោះបទល្មើសដែលជននោះបានប្រព្រឹត្ត។

ចំពោះទោសដាក់ពន្ធនាគារ គឺការអនុវត្តត្រូវធ្វើនៅពន្ធនាគារ មានន័យថា ជនម្នាក់ក្រោយពេលសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារហើយ គេយកជននោះទៅដាក់គុក។ ក្រមព្រហ្មទណ្ឌបានកំណត់អំពីរបៀបក្នុងការគណនាអំពីចិរវេលានៃទោសដាក់ពន្ធនាគារ និងកំណត់អំពីលក្ខខណ្ឌនៃការបញ្ចប់ទោសថែមទៀតផង។

ក្រមព្រហ្មទណ្ឌបានចែងអំពីចិរវេលានៃទោសដាក់ពន្ធនាគារ ដែលបានកំណត់ដូចខាងក្រោមៈ

- ប្រសិនបើទោសដាក់ពន្ធនាគារកំណត់ដាក់រយៈពេល ១ (មួយ) ថ្ងៃ ដូច្នេះច្បាប់កំណត់ថា ១ (មួយ) ថ្ងៃនេះគឺមានរយៈពេល ២៤ (ម្ភៃបួន) ម៉ោង។

---

[90] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៤។

[91] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦។

[92] ប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធិ** ជាអនុប្រធានការងារចូលរួមរៀបចំតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅក្នុងទូរទស្សន៍ជាតិកម្ពុជាឆ្នាំ ២០១០។

- បើជនម្នាក់ ត្រូវបានតុលាការសម្រេចដាក់ពន្ធនាគារ ១ (មួយ) ខែ របៀបក្នុងការគណនា ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ។ ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។
- បើសិនជនម្នាក់ ត្រូវបានតុលាការដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ របៀបនៃការគណនាត្រូវគិត ១២ (ដប់ពីរ) ខែ។[93]

ទន្ទឹមនឹងនេះ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីលក្ខខណ្ឌនៃការបញ្ចប់ទោសផងដែរ។ ជាទូទៅ នៅពេលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារជនណាម្នាក់ហើយ នៅក្នុងករណីនេះ ជននោះត្រូវទទួលរងទោសឱ្យបានគ្រប់ចំនួន ដូចជា ៣ (បី) ឆ្នាំ ត្រូវទទួលរងឱ្យបានគ្រប់ចំនួន ៣ (បី) ឆ្នាំ ប៉ុន្តែមានករណីពិសេសខ្លះ ដែលក្នុងនោះការបញ្ចប់ទោសដាក់ពន្ធនាគារអាចចប់មុនបាន ក្នុងករណីដែលការបញ្ចប់ទោសនោះចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ដូច្នេះ ទណ្ឌិតនោះត្រូវបានដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីការគិតរាប់បញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចូលទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួលផងដែរ។

ចំពោះទោសពិន័យជាប្រាក់វិញ ការពិន័យជាប្រាក់ត្រូវគិតជាប្រាក់រៀល ដែលជារូបិយវត្ថុជាតិ ហើយផលដែលបានចេញពីការពិន័យជាប្រាក់នេះ ត្រូវបង់ចូលទៅក្នុងថវិការដ្ឋ។[94] ទោសពិន័យជាប្រាក់នេះ ខុសពីទោសដែលសម្រេចផ្តន្ទាទោសឱ្យសងជម្ងឺចិត្ត។ ទោសពិន័យ ជាប្រភេទនៃទោសព្រហ្មទណ្ឌ គឺខុសពីទោសទណ្ឌកម្មផ្សេងទៀត ដែលចៅក្រមប្រកាសផ្តន្ទាទោសដូចជា ជនម្នាក់បានប្រព្រឹត្តបទល្មើស ចៅក្រមបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារផង ហើយសម្រេចឱ្យជនជាប់ចោទនោះបង់ជម្ងឺចិត្តទៅឱ្យជនរងគ្រោះទៀតផង។ សំណងជម្ងឺចិត្ត ត្រូវបង់ទៅឱ្យជនរងគ្រោះ និងត្រូវគិតគូរទៅតាមទំហំនៃព្យសនកម្ម ប៉ុន្តែប្រាក់ពិន័យវិញ គឺចៅក្រមមិនអាចធ្វើអ្វីខុសពីការកំណត់របស់ច្បាប់ទេ មានន័យថា ច្បាប់បានកំណត់ជាស្រេចអំពីអប្បបរមា និងអតិបរមាដែលត្រូវរងចំពោះការពិន័យ។

**ក. មូលទោសដែលអនុវត្តចំពោះនីតិជន**

នីតិជន ជាជនដែលមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។

ដើម្បីកំណត់ទោសទៅលើបទល្មើសណាមួយបាន លុះត្រាតែយើងមើលទៅលើលក្ខណៈសម្គាល់នៃបទល្មើសនីមួយៗ។ ដើម្បីអាចសម្គាល់ថាបទល្មើសមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុនោះ យើងត្រូវពិនិត្យទៅលើមូលទោស។

យោងតាមក្រមព្រហ្មទណ្ឌ មាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ បានកំណត់អំពីរបៀបក្នុងការសម្គាល់ថាបទល្មើសមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុបាន តាមរយៈទោសដាក់ពន្ធនាគារ ក្នុងករណី៖

---

[93] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៩។

[94] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥២។

- ទោសដាក់ពន្ធនាគារនោះជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ប៉ុន្តែលើសពី ៥ (ប្រាំ) ឆ្នាំឡើងទៅ ដល់ក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ នៅក្នុងករណីនេះ ច្បាប់បានកំណត់ថាជាបទឧក្រិដ្ឋ។
- ទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ ដល់ក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ក្រមព្រហ្មទណ្ឌចាត់ទុកថាបទល្មើសនោះជាបទមជ្ឈិម។
- ចំពោះបទលហុ មានលក្ខខណ្ឌវិនិច្ឆ័យពីរគឺ ការមើលទៅលើទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានអតិបរមាក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ និងទោសត្រឹមតែពិន័យជាប្រាក់។

**ខ. មូលទោសដែលអនុវត្តចំពោះអនីតិជន**

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[95]

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ តុលាការអាចប្រកាសទណ្ឌកម្មទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។[96]

កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់នោះ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវកាត់បន្ថយពាក់កណ្តាល
- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ
- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានោះលើសពី ១ (មួយ) ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិខាងលើមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។[97] ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ តុលាការមិនអាចប្រកាសទោសចំពោះអំពើរបស់អនីតិជននោះបានឡើយ។

[95] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨។

[96] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩។

[97] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦០។

សម្រាប់អនីតិជន ដែលត្រូវបានជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[98]

**២.២ ទោសបន្ថែម**

ទោសបន្ថែម សំដៅដល់ប្រភេទនៃទោសមួយដែលបន្ថែមទៅលើមូលទោស មានន័យថា ជាទូទៅ នៅពេលចៅក្រមប្រកាសមូលទោសហើយ ក្នុងករណីដែលមានច្បាប់ចែងអំពីការផ្តន្ទាទោសបន្ថែមចំពោះបទល្មើសនោះ ទោសបន្ថែមអាចត្រូវបានប្រកាស។

**ក. ទោសបន្ថែមសម្រាប់អនុវត្តចំពោះនីតិជន**

តុលាការអាចប្រកាសទោសបន្ថែមទៅលើជនដែលប្រព្រឹត្តបទល្មើស ដែលជានីតិជនមួយ ឬច្រើនបាន។ ទោសបន្ថែមដែលអាចអនុវត្តចំពោះនីតិជន មានដូចជា៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ
- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ
- ការព្យួរលិខិតបើកបរ
- ការហាមឃាត់ចំពោះការស្នាក់នៅ
- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស

[98] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៦។

- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណៈជន ឬដែលប្រើប្រាស់ដោយសាធារណៈជន
- ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស
- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារពត៌មាន
- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។[99]

ទោសបន្ថែមនេះ ត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌ ហើយក៏បានកំណត់អំពីថិរវេលានៃការអនុវត្តចំពោះទោសបន្ថែមនេះផងដែរ។ ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[100]

**ខ. ទោសបន្ថែមសម្រាប់អនុវត្តចំពោះអនីតិជន**

ទោសបន្ថែមដែលអនុវត្តចំពោះអនីតិជន មានលក្ខណៈខុសពីទោសបន្ថែមដែលអនុវត្តចំពោះនីតិជន។ ក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងជាក់លាក់អំពីទោសបន្ថែម ដែលអាចអនុវត្តចំពោះអនីតិជន មានដូចតទៅៈ

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការហាមឃាត់ការកាន់កាប់ ឬការយកមកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។[101]

### ២.៣ ទោសជំនួស

ទោសជំនួស ជាប្រភេទទោសមួយដែលចៅក្រមអាចជ្រើសរើសយកទៅប្រើប្រាស់ ដើម្បីជំនួសឱ្យមូលទោស មានន័យថាទោសនេះ ត្រូវបានយកទៅប្រើប្រាស់ជំនួសឱ្យមូលទោស។ នៅពេលដែលចៅក្រម ឬតុលាការប្រកាសប្រើប្រាស់ទោសជំនួសនេះ ចៅក្រមមិនប្រកាសមូលទោសទេ គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ យោងតាមក្រមព្រហ្មទណ្ឌ ទោសជំនួសត្រូវបានចែកចេញជាពីរប្រភេទគឺ ទោសការងារសហគមន៍ និងទោសស្ដីបន្ទោស។

- **ទោសការងារសហគមន៍**

---

[99] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៣។

[100] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤។

[101] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦១។

ទោសការងារសហគមន៍ គឺសំដៅលើកាតព្វកិច្ចមួយដែលត្រូវបំពេញនូវការងារមួយដែលគ្មានកម្រៃ និងជាប្រយោជន៍រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។

- **ទោសស្តីបន្ទោស**

ទោសស្តីបន្ទោស ជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាល ហើយចៅក្រមមិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទេ ដូច្នេះចៅក្រមអាចប្រកាសទោសនេះបានទុកជាការព្រមានអំពីកំហុសខុសឆ្គងដែលជនជាប់ចោទបានប្រព្រឹត្ត និងដើម្បីកុំឱ្យជននោះប្រព្រឹត្តបទល្មើសតទៅទៀត។

**ក. ទោសជំនួសដែលអនុវត្តចំពោះនីតិជន**

តុលាការ អាចប្រកាសទោសការងារសហគមន៍ទៅលើនីតិជនបាន។ រយៈពេលនៃការបំពេញកាតព្វកិច្ចនៃទោសការងារសហគមន៍ចំពោះនីតិជននេះ ត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង ប៉ុន្តែមិនឱ្យលើសពី ១ (មួយ) ឆ្នាំ។

ដើម្បីអាចប្រកាសទោសនេះបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការនេះ។ ទោសការងារសហគមន៍នេះ អាចត្រូវបានប្រកាសដោយតុលាការ ក្នុងករណីដែលជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំតែប៉ុណ្ណោះ។[102]

ចំណែកឯទោសស្តីបន្ទោសវិញ អាចត្រូវបានប្រកាសដោយតុលាការ ក្នុងករណីដែលជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ និងត្រូវគោរពលក្ខខណ្ឌដូចជា៖

- ភាពចលាចលសណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[103]

**ខ. ទោសជំនួសដែលអនុវត្តចំពោះអនីតិជន**

តុលាការអាចប្រកាសទោសការងារសហគមន៍សម្រាប់អនីតិជនបាន លុះត្រាតែអនីតិជននោះមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោងបានទេ។ ទោសការងារសហគមន៍នេះ ត្រូវតែសម្របសម្រួលទៅលើអនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល អប់រំ កែប្រែ ដើម្បីសម្រួលដល់អនីតិជនចូលរួមរស់នៅក្នុងសង្គមវិញ។ តុលាការមិនអាចប្រកាសទោសការងារសហគមន៍ទៅលើអនីតិជនដែលមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ បានឡើយ។

[102] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២។

[103] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦។

ចំពោះទោសស្តីបន្ទោសវិញ លក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោសនេះ គឺបានកំណត់ខាងលើនូវចំណុច ទោសជំនួសអនុវត្តចំពោះនីតិជនរួចមកហើយ។

ក្នុងករណីដែលតុលាការប្រកាសទោសជំនួស ដែលជាទោសការងារសហគមន៍ ឬទោសស្តីបន្ទោសជំនួសឱ្យមូលទោសនោះ តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។[104]

**៣. ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌ បានកំណត់អំពីការទទួលខុសត្រូវរបស់នីតិបុគ្គលដោយចែងថា នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។[105] មានន័យថា នីតិបុគ្គលដែលជារដ្ឋ មិនត្រូវបានប្រកាសនូវទោសចំពោះអំពើណាមួយឡើយ ប៉ុន្តែនីតិបុគ្គលដែលមិនមែនជារដ្ឋ ត្រូវទទួលខុសត្រូវចំពោះអំពើណាមួយ ហើយក៏មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។ ទោសដែលនីតិបុគ្គលអាចត្រូវបានប្រកាស មានដូចជា៖

- ទោសពិន័យក្នុងឋានៈជាមូលទោស និង
- ទោសសន្លែម។

**៣.១ ទោសពិន័យក្នុងឋានៈជាមូលទោស**

ចំពោះនីតិបុគ្គលនេះ ទោសដែលត្រូវទទួលរងគឺត្រឹមតែជាទោសពិន័យក្នុងឋានៈជាមូលទោសតែប៉ុណ្ណោះ ដោយហេតុថា តុលាការមិនអាចយកនីតិបុគ្គលទៅដាក់ពន្ធនាគារបាននោះទេ។ ហេតុដូច្នេះ ទោសពិន័យក្នុងឋានៈជាមូលទោសនេះ នីតិបុគ្គលត្រូវអនុវត្តទៅតាមបទល្មើសនីមួយៗដែលក្រមព្រហ្មទណ្ឌបានកំណត់។

**៣.២ ទោសបន្ថែម**

ទោសបន្ថែម អាចត្រូវបានបន្ថែមទៅលើទោសពិន័យក្នុងឋានៈជាមូលទោស សម្រាប់អនុវត្តចំពោះនីតិបុគ្គល មានដូចតទៅ៖

- ការរំលាយចោល
- ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ
- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការហាមឃាត់ចំពោះការអំពាវនាវសាធារណៈដល់ការសន្សំសំចៃ

[104] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨។

[105] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤២។

- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ
- ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់
- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត
- ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារពត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។[106]

ទោសបន្ថែម អាចត្រូវបានប្រកាសដោយតុលាការបាន លុះត្រាតែច្បាប់បានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសនីមួយៗ។

[106] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៨។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវប្រធានបទស្ដីពីបទល្មើសព្រហ្មទណ្ឌរួចមក យើងអាចសង្កេត និងសន្និដ្ឋានបានថា បទល្មើសព្រហ្មទណ្ឌ គឺជាបទល្មើសទាំងឡាយណាដែលមានលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គម ហើយដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ និងត្រូវបានចាត់ថ្នាក់ជាបីប្រភេទ (បទឧក្រិដ្ឋ, បទមជ្ឈិម និងបទលហុ) ទៅតាមទម្ងន់របស់វា។ មិនតែប៉ុណ្ណោះ បើទោះបីជាច្បាប់បានកំណត់ថាបទល្មើសត្រូវបានចាត់ថ្នាក់ជាបីប្រភេទក៏ដោយ ក៏នៅមានចំណាត់ថ្នាក់នៃបទល្មើសបន្ទាប់បន្សំផ្សេងទៀតដែរ ដូចជា ចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើស ចំណាត់ថ្នាក់ដោយផ្អែកលើបែបបទនៃការប្រព្រឹត្តបទល្មើស ឬបទល្មើសដែលគ្មានអាជ្ញាយុកាលជាដើម។ ការធ្វើចំណាត់ថ្នាក់នៃបទល្មើសបែបនេះ គឺដើម្បីងាយស្រួលចំពោះស្ថាប័នមានសមត្ថកិច្ច ក្នុងការចោទប្រកាន់ ដោយហេតុថា បទល្មើសនីមួយៗមានចរិតលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គមខុសៗគ្នា គឺខ្លះមានលក្ខណៈស្រាល ខ្លះមានលក្ខណៈធ្ងន់ល្មម និងខ្លះទៀតមានលក្ខណៈធ្ងន់ធ្ងរ។ ហេតុដូច្នេះ ការប្រកាសទោសចំពោះបទល្មើសនីមួយៗ ក៏ប្រែប្រួលទៅតាមចរិតគ្រោះថ្នាក់នៃបទល្មើសទាំងនោះ ហើយដែលក្រមព្រហ្មទណ្ឌបានចែងយ៉ាងជាក់លាក់ទៀតផង។

ជាទូទៅ ដើម្បីកំណត់ថាអំពើមួយជាបទល្មើសបាន លុះត្រាតែមានច្បាប់ចែងទុកជាមុនថាអំពើនោះជាបទល្មើសដែលត្រូវផ្ដន្ទាទោស។ លើសពីនេះទៅទៀត អំពើមួយអាចចាត់ទុកថាជាបទល្មើស និងត្រូវបានចោទប្រកាន់លុះត្រាតែអំពើនោះបានបំពេញនូវធាតុផ្សំទាំងបីជាមុនសិន (ធាតុនីត្យានុកូល ឬធាតុច្បាប់, ធាតុសត្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ) បើពុំដូច្នោះទេ ចៅក្រមមិនអាចប្រកាសទោសចំពោះជននោះបានឡើយ។ ថ្វីត្បិតតែអំពើមួយត្រូវបានទទួលរងនូវការចោទប្រកាន់ក៏ដោយ តុលាការអាចប្រកាសទោសចំពោះជនជាប់ចោទបានដោយថ្លឹងថ្លែងទៅលើចរិតលក្ខណៈនៃបទល្មើស សភាវផ្លូវចិត្តនៃជនល្មើស ក៏ដូចជាបុគ្គលិកលក្ខណៈនៃជននោះជាដើម។ ជាក់ស្ដែង បុគ្គលដែលប្រព្រឹត្តបទល្មើស គឺមិនអាចទទួលរងនូវទណ្ឌកម្មដូចគ្នានោះទេ ពីព្រោះក្រមព្រហ្មទណ្ឌបានកំណត់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ថា បុគ្គលដែលអាចទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនបាន ត្រូវតែមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ផ្ទុយទៅវិញ ជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ក៏អាចត្រូវបានតុលាការប្រកាសផ្ដន្ទាទោសចំពោះអំពើដែលខ្លួនបានប្រព្រឹត្តផងដែរ ប្រសិនបើបុគ្គលិកលក្ខណៈរបស់ជននោះតម្រូវ។ ប៉ុន្តែ ការអនុវត្តចំពោះជនប្រភេទនេះជាវិធាននៃការតាមដានអប់រំ ការពារ និងឧបត្ថម។ ចំណែកឯជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំវិញ គឺមិនអាចត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ ឬត្រូវបានប្រកាសទោសដោយតុលាការណាមួយឡើយ។ មិនតែប៉ុណ្ណោះ នីតិបុគ្គលដែលមិនមែនជារដ្ឋ ក៏អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ចំពោះអំពើប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

យ៉ាងណាមិញ បើទោះបីជាជនដែលបានប្រព្រឹត្តបទល្មើសដែលច្បាប់បានកំណត់ថាជាបទល្មើស ហើយនឹងត្រូវទទួលរងនូវទណ្ឌកម្មចំពោះអំពើរបស់ខ្លួនក៏ដោយ មានករណីខ្លះ ជននោះក៏អាចរួចផុតពីការទទួលទោសព្រហ្មទណ្ឌបានដែរ ដូចជាករណីទាក់ទងទៅនឹងបុគ្គលដែលប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬជាអំពើយុត្តិកម្ម។

ដោយឡែក ចំពោះការអនុវត្តទោសក៏មានលក្ខណៈខុសគ្នាដែរ ដោយយោងទៅតាមប្រភេទនៃបទល្មើសនីមួយៗ និងទៅតាមប្រភេទនៃជនល្មើស (ជានីតិជន ឬអនីតិជន)។ ថ្វីត្បិតតែទោស ដែលតុលាការប្រកាសទៅលើទណ្ឌិត អាចមានលក្ខណៈធ្ងន់ ឬស្រាលទៅតាមទម្ងន់នៃបទល្មើសក៏ដោយ ការដាក់ទណ្ឌកម្មនេះ គឺមានគោលបំណងចម្បងជាងគេនោះគឺកែប្រែជននោះឱ្យក្លាយទៅជាមនុស្សល្អ និងអាចចូលទៅរួមរស់នៅក្នុងសង្គមវិញ ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ។ ចំពោះការដាក់ទោសនេះដែរ ជនដែលប្រព្រឹត្តបទល្មើសអាចអនុវត្តទោសបាន លុះត្រាតែទោសនោះត្រូវបានប្រកាសដោយតុលាការ។

សរុបជារួមមក ប្រធានបទស្តីពីបទល្មើសព្រហ្មទណ្ឌនេះ ពិតជាមានសារៈសំខាន់ណាស់ ដែលជាភាពងាយស្រួលក្នុងការកំណត់នូវប្រភេទនៃបទល្មើសនីមួយៗ និង ធ្វើឱ្យដំណើរការនៃការចោទប្រកាន់ប្រកបដោយភាពរលូនស្របតាមបទប្បញ្ញត្តិស្តីពីនីតិវិធី ជាពិសេសនោះគឺ ដើម្បីធានានូវសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងសុវត្ថិភាពនៅក្នុងសង្គម ក៏ដូចជាផ្តល់នូវភាពយុត្តិធម៌ចំពោះភាគីផងដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ និងបានបកស្រាយនូវចំណុចនីមួយៗ សបញ្ជាក់ឱ្យឃើញថា ប្រធានបទស្តីពីបទល្មើសព្រហ្មទណ្ឌ ពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំង ចំពោះការកំណត់នូវបទល្មើសព្រហ្មទណ្ឌ និងងាយស្រួលក្នុងការអនុវត្តនៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចនីតិវិធីពិតប្រាកដមែន។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលមានបទល្មើសណាមួយកើតឡើង ជនដែលបានប្រព្រឹត្តបទល្មើសដែលច្បាប់បានចែងទុកជាមុន នឹងត្រូវទទួលទណ្ឌកម្មចំពោះអំពើរបស់ខ្លួន បើទោះបីជាជននោះមានឋានៈ ឬបុណ្យសក្តិបែបណាក៏ដោយ។ មកទល់នឹងបច្ចុប្បន្ន ការអនុវត្តនីតិវិធីក្នុងការចោទប្រកាន់របស់អង្គការអយ្យការទៅលើជនល្មើស ក៏ដូចជាការប្រកាសនូវទោសទៅលើទណ្ឌិតដោយស្ថាប័នតុលាការ គឺប្រព្រឹត្តទៅដោយភាពរលូនល្អហើយ ប៉ុន្តែ ក៏អាចនឹងមានចន្លោះខ្វះខាតនៅពេលដែលកំពុងអនុវត្តកិច្ចនីតិវិធី និងការអនុវត្តជាក់ស្តែងផងដែរ។ ដូចជា យើងបានដឹងរួចមកហើយថា ប្រទេសកម្ពុជាយើងមានបទល្មើសកើតឡើងជារៀងរាល់ថ្ងៃ ហើយបទល្មើសនីមួយៗនោះទៀតសោតមានលក្ខណៈប្លែកៗ ពីសម័យកាលមួយទៅសម័យកាលមួយ ហើយបទល្មើសខ្លះ មានចរិតគ្រោះថ្នាក់ដល់សង្គមក៏ពិតមែន ប៉ុន្តែច្បាប់មិនបានចែងជាក់លាក់ថាអំពើនោះជាបទល្មើសឡើយ។ ហេតុដូច្នេះ តុលាការមិនអាចប្រកាសទោសចំពោះអំពើដែលជនណាម្នាក់បានប្រព្រឹត្តដោយគ្មានច្បាប់ចែងបានទេ នេះបើយោងតាមគោលការណ៍នៃក្រមព្រហ្មទណ្ឌផ្ទាល់តែម្តង។ ម្យ៉ាងវិញទៀត ចំពោះការចោទប្រកាន់ពីបទល្មើសណាមួយ ស្ថាប័នមានសមត្ថកិច្ចគឺព្រះរាអាជ្ញាត្រូវតែពិនិត្យឱ្យបានច្បាស់ថាបទល្មើសនោះ មានភស្តុតាងគ្រប់គ្រាន់ថាជនណាមួយនោះបានប្រព្រឹត្តបទល្មើសមែន និងត្រូវបានច្បាប់កំណត់ទុកថាជាបទល្មើសយ៉ាងពិតប្រាកដ។ ដូចគ្នានេះដែរ ចំពោះការផ្តន្ទាទោសវិញ តុលាការត្រូវថ្លឹងថ្លែងឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងកំណត់ពីពិរុទ្ធភាពរបស់ជនល្មើស មុននឹងសម្រេចផ្តន្ទាទោសជននោះ ទៅតាមកម្រិតនៃអំពើ ដោយគ្មានភាពលំអៀង និងយុត្តិធម៌។ ផ្ទុយទៅវិញ បើសិនជាអំពើមួយដែលមិនមែនជាបទល្មើសហើយត្រូវបានតុលាការប្រកាសផ្តន្ទាទោសនោះ ទង្វើបែបនេះនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះជនដែលត្រូវបានគេចោទប្រកាន់ ក៏ដូចជាសង្គមទាំងមូល ដោយហេតុថាជាអំពើប៉ះពាល់ទៅដល់សិទ្ធិសេរីភាពរបស់បុគ្គលដែលច្បាប់ជាតិ និងអន្តរជាតិបានការពារ។

ហេតុនេះហើយ ដើម្បីឱ្យដំណើរការនៃកិច្ចនីតិវិធីក្នុងការចោទប្រកាន់ ក៏ដូចជាការផ្តន្ទាទោសជនល្មើសចំពោះអំពើទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សង្គមប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ត្រូវតែចាត់វិធានការដូចជា៖

- រៀបចំនូវកម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗទាក់ទងទៅនឹងវិស័យច្បាប់ ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង
- លុបបំបាត់អំពើពុករលួយ ដើម្បីឱ្យមានភាពយុត្តិធម៌សម្រាប់ជនល្មើស និងជនរងគ្រោះ ក៏ដូចជា

គោរពនូវសិទ្ធិសេរីភាពរបស់ជនគ្រប់រូប

- បង្កើតនូវតុលាការជំនាញឱ្យបានគ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការដោះស្រាយរឿងក្តីនីមួយៗ ប្រកបដោយភាពរលូន មិនស្មុគស្មាញ និងឆាប់រហ័ស
- ផ្សព្វផ្សាយច្បាប់ឱ្យកាន់តែទូលំទូលាយ តាមគ្រប់មធ្យោបាយ ដើម្បីឱ្យប្រជាពលរដ្ឋស្វែងយល់កាន់តែច្បាស់ថាអំពើណាខ្លះដែលច្បាប់ចាត់ទុកថាជាបទល្មើស និងត្រូវផ្តន្ទាទោស
- មន្ត្រីតុលាការត្រូវគោរពនូវវិន័យ និងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់កំណត់ ដោយមិនត្រូវក្បត់នឹងសតិសម្បជញ្ញៈរបស់ខ្លួន
- ពង្រឹងនូវកិច្ចនីតិវិធី និងបច្ចេកទេសសម្រាប់អនុវត្តផ្ទាល់
- កំណត់ពីពិរុទ្ធភាព មុននឹងការសម្រេចផ្តន្ទាទោស
- ការប្រកាសទោស ត្រូវធ្វើឡើងប្រកបដោយយុត្តិធម៌ មិនលំអៀង
- ពង្រឹងសមត្ថភាពស្ថាប័ន អង្គភាពលើវិស័យច្បាប់ ធានាប្រសិទ្ធិភាពក្នុងការគ្រប់គ្រងកម្លាំងតាមឋានានុក្រមការងារឱ្យកាន់តែមានតម្លាភាព
- ជម្រុញ និងលើកទឹកចិត្តចំពោះមន្ត្រីណាដែលមានស្នាដៃ ក្នុងការអនុវត្តមុខងាររបស់ខ្លួន
- បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអាចស្វែងយល់ និងជាធនធានក្នុងការអភិវឌ្ឍសង្គមជាតិ
- ត្រូវមានការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងច្បាស់លាស់មុននឹងធ្វើការចោទប្រកាន់
- ត្រូវធ្វើកំណែទម្រង់ច្បាប់ទៅតាមកាលៈទេសៈនៃសង្គម ពីព្រោះថាអាចនឹងមានបទល្មើសថ្មីៗកើតឡើងនាពេលអនាគត ដែលច្បាប់មិនបានចែងទុក
- ពង្រឹងនូវការសិក្សាផ្នែកឧក្រិដ្ឋវិទ្យា ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវស្ថានភាពនៃបទល្មើស មូលហេតុ និងលក្ខខណ្ឌនៃបទល្មើស ក៏ដូចជាដើម្បីលុបបំបាត់នូវបទល្មើសដែលធ្លាប់មាន និងទប់ស្កាត់នូវបទល្មើសដែលអាចកើតឡើងនាពេលអនាគត
- គិតផលប្រយោជន៍រួម ជាជាងផលប្រយោជន៍ផ្ទាល់ខ្លួន ទើបប្រទេសមានសន្តិភាព និងមានភាពអភិវឌ្ឍប្រកបដោយចីរភាព។

# ឯកសារយោង

# ឯកសារយោង

- **បទដ្ឋានគតិយុត្តជាតិ**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣
  - ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ៣០ វិច្ឆិកា ២០០៩
  - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ១០ សីហា ២០០៧
  - ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ០៨ កុម្ភៈ ១៩៩៣
  - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ៨ ធ្នូ ២០០៧
  - ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ២១ មីនា ២០១៧
  - ច្បាប់ស្តីពីឯកពន្ធភាព ២១ តុលា ២០០៦
  - ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២ មករា ២០១២
  - ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១៦ ខែកក្កដា ឆ្នាំ ២០១៤
  - ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ១៦ ខែកក្កដា ឆ្នាំ ២០១៤
- **បទដ្ឋានគតិយុត្តអន្តរជាតិ**
  - សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១០ ធ្នូ ១៩៤៨
- **ឯកសារជាសៀវភៅ និងឯកសារផ្សេងៗទៀត**
  - វចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត**
  - វចនានុក្រមច្បាប់អង់គ្លេស~ខ្មែរ បោះពុម្ពផ្សាយនៅឆ្នាំ ១៩៩៧
  - វចនានុក្រមបារាំង~ខ្មែរ
  - សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **ហ៊ាង ឡេង**
  - សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **រុណ ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ ២០១២
  - សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ របស់សាស្ត្រាចារ្យ **កៅ សីហា** ឆ្នាំ ២០១៣
  - សៀវភៅឧក្រិដ្ឋវិទ្យា របស់លោកបណ្ឌិត **ស៊ិន រិទ្ធ** ឆ្នាំ ២០១១
  - ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ តាមរយៈទូរទស្សន៍ជាតិ ឆ្នាំ ២០១០
  - សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី ១ ឆ្នាំ ២០១១
  - សន្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ៣

រដ្ឋសភា
ចូល
លេខ........
ថ្ងៃទី........ឆ្នាំ២០១៤.ម៉ោង........
បញ្ជូនទៅ........

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនិងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៨/០០២/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
LE MINISTERE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យនៃអំណាច តុលាការស្រប តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តទៅលើចៅក្រម និងព្រះរាជអាជ្ញា ទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ ។

**មាត្រា ៣.-**

វាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មានន័យដូចខាងក្រោម៖

-ចៅក្រម សំដៅដល់ចៅក្រមអាសនៈ រួមមានជាអាទិ៍ ចៅក្រមជំនុំជម្រះក្តី និងចៅក្រមស៊ើបសួរ ។

-ព្រះរាជអាជ្ញា សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង អគ្គព្រះរាជអាជ្ញា ។

-អង្គចៅក្រម សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា ។

## ជំពូកទី ២
## ការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### ផ្នែកទី ១
### សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ៤.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ និងរួមមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាសមាជិក |
| ២-ប្រធានតុលាការកំពូល | ជាសមាជិក |

៣-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក

៤-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៥-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៦-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៧-សមាជិក ០១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងចំណោមព្រះរាជអាជ្ញាពេញសិទ្ធិទាំងអស់

៨-សមាជិក ០១ (មួយ) រូប ជាចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់

៩-សមាជិក០១ (មួយ) រូប ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ឬព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌

១០-សមាជិក ០១ (មួយ) រូប ជាចៅក្រមពេញសិទ្ធិនៃសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស

១១-សមាជិក ០១(មួយ) រូប ជាព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងទូទាំងប្រទេស ។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាំងអស់ខាងលើ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រចំពោះកិច្ចការនេះ ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានក្នុងចំណុចទី ៨ ដល់ចំណុចទី ១១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ៥.-**

សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវបន្តមុខងាររហូតដល់ពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង ។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបាន ។ ការបោះឆ្នោតជ្រើសតាំង

ទាំងអស់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើខាងលើ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឲ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ។

## មាត្រា ១៩.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះមតិជាចាំបាច់ ដើម្បីផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ ។ យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវផ្តល់យ៉ាងយូរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងករណីប្រញាប់ រយៈពេលនេះ អាចបន្ថយមកត្រឹម ១០ (ដប់) ថ្ងៃ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា ។

# ផ្នែកទី ២
# សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា

## មាត្រា ២០.-

ក្នុងមុខការដាក់វិន័យចំពោះចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ។ ក្នុងមុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ក្រោមអធិបតីភាពនៃអគ្គ-ព្រះរាជអាជ្ញាអមតុលាការកំពូល ។ ក្នុងករណីទាំងនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមក្នុងក្រុមប្រឹក្សាវិន័យទេ ។

ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមប្រជុំក្នុងក្រុមប្រឹក្សាវិន័យនេះ ។

ចៅក្រម ឬព្រះរាជអាជ្ញាដែលជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយដែលមានសំណុំរឿងវិន័យពាក់ព័ន្ធនឹងខ្លួន មិនអាចចូលរួមប្រជុំក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេចលើសំណុំរឿងវិន័យនោះបានឡើយ ។

ក្នុងមាត្រា ៤ នៃច្បាប់នេះ សមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តការងាររបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ រហូតដល់ពេលដែលសមាសភាពថ្មីត្រូវបានតែងតាំងជាផ្លូវការដោយព្រះរាជក្រឹត្យ ។ ក្នុងករណីនេះគោលការណ៍ វិសមិតភាព ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ។

### មាត្រា ២៨.-

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវរៀបចំឲ្យមានការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងចាប់ពីចំណុចទី ៨ ដល់ចំណុចទី ១១ នៃមាត្រា ៤ នៃច្បាប់នេះក្នុងអំឡុងពេល០៣ (បី) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតលើកទី ១ សម្រាប់ការជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ២៩.-

សម្រាប់អំឡុងពេលដែលក្រុមអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ពុំទាន់ត្រូវបានតែងតាំងតាមបញ្ញត្តិនៃមាត្រា ២១ នៃច្បាប់នេះ ប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រប អាចចាត់ឲ្យចៅក្រម ឬព្រះរាជអាជ្ញាដែលបម្រើការងារនៅតាមសាលា ជម្រះក្តី និងនៅតាមអង្គការអយ្យការអមសាលាជម្រះក្តី ដើម្បីឲ្យចុះធ្វើការស្រាវជ្រាវ និងស៊ើបអង្កេត លើសំណុំរឿងវិន័យបាន ។

### មាត្រា ៣០.-

បទប្បញ្ញត្តិនៃមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

### មាត្រា ៣១.-

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានប្រកាស

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

ឲ្យប្រើដោយព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

កាល.១៤០៧.៨៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ: [illegible] ស.ណ

**សំណៅដែលមានតម្លៃដូចការចេញផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខា[illegible]រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ឧបសម្ព័ន្ធទី ៤

រដ្ឋសភា
ចូល លេខ [illegible] ថ្ងៃទី [illegible] ឆ្នាំ២០១៤ ម៉ោង [illegible]
បញ្ជូនទៅ [illegible]

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៦

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៧/០០១/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិរួម

**មាត្រា ១.-**

ច្បាប់នេះ កំណត់ពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងគោលការណ៍ផ្សេងៗ ទៀតទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ ។

**មាត្រា ៣.-**

វាក្យសព្ទបច្ចេកទេសក្នុងច្បាប់នេះ មានន័យដូចតទៅ ៖

- ចៅក្រម សំដៅដល់ចៅក្រមអាសនៈ រួមមាន ជាអាទិ៍ ចៅក្រមជម្រះក្តី និងចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញា
- អង្គចៅក្រម សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា ។

**មាត្រា ៤.-**

បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ ។

**មាត្រា ៥.-**

នៅក្នុងអាជីពរបស់ខ្លួន ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ ។

**មាត្រា ៦.-**

ចៅក្រម និងព្រះរាជអាជ្ញា ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារក្នុងករណីចាំបាច់តាមសំណូមពររបស់សាមីខ្លួន ។



## មាត្រា ៥១.–

ចៅក្រមទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ ។

## មាត្រា ៥២.–

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុចាប់ពី ១៥ (ដប់ប្រាំ) ថ្ងៃ ឡើងទៅត្រូវទទួលវិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬដាក់ឲ្យនៅទំនេរគ្មានបៀវត្ស ដោយគិតពីថ្ងៃបោះបង់ការងារ ឬថ្ងៃអវត្តមានគ្មានការអនុញ្ញាតនោះ ។ បើការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុលើសពី ៣០ (សាមសិប) ថ្ងៃ ហើយចៅក្រមនោះនៅតែមិនត្រឡប់មកបំពេញការងារវិញក្រោយការដាក់កំហិតចំនួនពីរដងនោះ ត្រូវលុបឈ្មោះចេញពីក្របខណ្ឌ ។

## មាត្រា ៥៣.–

ចៅក្រមដែលកំពុងបំពេញមុខងារនៅតាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលទាក់ទងនឹងមុខងាររបស់ខ្លួន ។

ការរំលោភលើបញ្ញត្តិនៃមាត្រានេះ ត្រូវទទួលទោសវិន័យ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទព្រហ្មទណ្ឌប្រសិនបើមាន ។

បទប្បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តចំពោះការផ្ដល់ព័ត៌មានធម្មតាទាក់ទងនឹងដំណើរការនៃរឿងក្ដីនៅតាមសាលាជម្រះក្ដីក្នុងលក្ខខណ្ឌមិនបំពានដល់ការសម្ងាត់វិជ្ជាជីវៈដែលកំណត់ដោយច្បាប់ ។ ការផ្ដល់ព័ត៌មាននេះ ត្រូវធ្វើឡើងតាមរយៈមន្ត្រីនៃអង្គភាពរដ្ឋបាលនៃសាលាជម្រះក្ដី ។

# ផ្នែកទី ១០
# ទណ្ឌកម្មវិន័យ

## មាត្រា ៥៤.–

កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

ចៅក្រមអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងករណីដែលចៅក្រមនោះកំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៥៥.-

ទណ្ឌកម្មខាងវិន័យមាន ២ (ពីរ) ថ្នាក់គឺ ៖

១-ទណ្ឌកម្មថ្នាក់ទី ១ (មួយ)

ក- ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២ (ពីរ) ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ ។

២-ទណ្ឌកម្មថ្នាក់ទី ២ (ពីរ)

ក- ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១ (មួយ) ឆ្នាំ

គ- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

ង-ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្តេញចេញពីក្របខណ្ឌ ។

ទណ្ឌកម្មថ្នាក់ទី ២ (ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## មាត្រា ៥៦.-

ក្នុងករណីមានការបញ្ឈប់ពីមុខងារដោយបង្ខំ ឬការបណ្តេញចេញពីក្របខណ្ឌដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ជានៃបេឡាសោធននិវត្តន៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ផ្នែកទី ១២ (ការចូលនិវត្តន៍) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត បន្ទាប់ពីការធ្វើសមាហរណកម្មចូលទៅក្នុងក្របខណ្ឌចៅក្រម និងព្រះរាជអាជ្ញា។

ក្នុងពេលរង់ចាំការធ្វើសមាហរណកម្មខាងលើ ការចូលនិវត្តន៍របស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវអនុវត្តដោយអនុលោមតាមបទដ្ឋានគតិយុត្តដែលមានមុនពេលច្បាប់នេះត្រូវបានអនុវត្ត។

**មាត្រា ១១០.-**

ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំដំបូង បន្ទាប់ពីច្បាប់នេះចូលជាធរមាន បទប្បញ្ញត្តិនៃមាត្រា ៤៩ និងមាត្រា ៩៥ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ លើកលែងតែការកំណត់ចំនួនចៅក្រមនៅតុលាការកំពូល ។

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូង បន្ទាប់ពីច្បាប់នេះចូលជាធរមាន ចៅក្រមនៃសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ដែលដល់អាយុចូលនិវត្តន៍ អាចអនុញ្ញាតឲ្យបន្តការងារ តាមការស្នើសុំរបស់សាមីខ្លួន។ ការបន្តការងារនេះមានរយៈពេល ០១ (មួយ) ឆ្នាំ ម្តង ប៉ុន្តែមិនឲ្យលើសពី០៣ (បី) ដង ឡើយ។ ការអនុញ្ញាតឲ្យបន្តការងារនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *១៦* ខែ *កក្កដា* ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*នស/រកម. ០៧១៤/០១៦*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ: ៥៦៧ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ៧ ឆ្នាំ២០១៤

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ពេជ សុខា**